សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Économiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# សិទ្ធិអ្នកនិពន្ធ ~ ការវិវាទសិទ្ធិ និងយន្តការដោះស្រាយ ការរំលោភសិទ្ធិអ្នកនិពន្ធនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ក. រឿន ស្រីម៉ុម**
**ក. អ៊ុំ ស្រីធី**

សាស្ត្រាចារ្យណែនាំ
លោក **ទេព សុខ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
**Université Royale de Droit et des Sciences Économiques**
**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# សិទ្ធិអ្នកនិពន្ធ ~ ការវិវាទសិទ្ធិ និងយន្តការដោះស្រាយ ការរំលោភសិទ្ធិអ្នកនិពន្ធនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ: **ក. រឿន ស្រីម៉ុម**
**ក. អ៊ុំ ស្រីទី**

សាស្ត្រាចារ្យណែនាំ
លោក **ទេព សុខ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្ដីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **រឿន ស្រីម៉ុម** និងនាងខ្ញុំឈ្មោះ **អ៊ុំ ស្រីនី** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

សូមសម្ដែងនូវសេចក្ដីគោរពដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ៖

**លោកឪពុក អ្នកម្ដាយ** ដែលលោកទាំងពីរបានបង្កើត ចិញ្ចឹមបីបាច់ថែរក្សា អប់រំ ទូន្មាន ប្រៀនប្រដៅកូនប្រកបដោយព្រហ្មវិហារធម៌ទាំងបួន។ ជំនួសឲ្យការនឿយហត់ពីការងារ លោកតែងតែផ្ដល់សេចក្ដីស្រលាញ់ ថ្នាក់ថ្នម យកចិត្តទុកដាក់ និងព្រួយបារម្ភពីសុខទុក្ខរបស់កូនជានិច្ច។ នៅពេលដែលកូនចម្រើនដល់វ័យទទួលការអប់រំ លោកក៏បានបញ្ជូនកូនទៅសាលារៀនដោយមិនគិតពីការចំណាយ លោកបានខិតខំទាំងកំលាំងកាយ និងកំលាំងចិត្ត ដោយមិនខ្លាចការនឿយហត់ ដើម្បីទំនុកបំរុងកូនអោយទទួលបាននូវចំណេះដឹងដ៏មានតម្លៃដែលមិនអាចកាត់ថ្លៃបាន។

**ឯកឧត្តមសាកលវិទ្យាធិការ លុយ ចណ្ណា** សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង រួមទាំងសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានចំណាយនូវកំលាំងកាយ កំលាំងចិត្តក្នុងការបង្ហាត់បង្រៀន និងផ្ដល់ជាឯកសារ ក៏ដូចជាការរៀបចំដំណើរការនៃការសិក្សា និងការសរសេរសារណាដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររបស់យើងខ្ញុំផងដែរ។

សាស្ត្រាចារ្យ **ទេព សុខ** ដែលជាសាស្ត្រាចារ្យដឹកនាំផ្ទាល់ ក្នុងការសរសេរសារណាបញ្ចាប់ថ្នាក់បរិញ្ញាបត្រមួយនេះ។ លោកបានបង្ហាត់បង្រៀន ផ្ដល់ដំបូន្មានល្អៗ និងលើកទឹកចិត្តយើងខ្ញុំអោយខិតខំប្រឹងធ្វើកិច្ចការនេះ ព្រមទាំងចែករំលែកបទពិសោធន៍ជាច្រើនដល់យើងខ្ញុំទៀតផង។ ជាពិសេសលោកបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការផ្ដល់នូវសេចក្ដីណែនាំ និងកែលម្អចំនុចខ្វះខាតដែលកើតមានឡើងក្នុងដំណើរការសរសេរសារណានេះ។

ជាចុងក្រោយ យើងខ្ញុំទាំងពីរសូមលើកហត្ថប្រណមបួងសួងដល់ទេវតា និងវត្ថុសក្ដិសិទ្ធិទាំងអស់ដែលមានក្នុងលោក សូមតាមជួយបីបាច់ថែរក្សា លោកឪពុក អ្នកម្ដាយ លោកសាស្ត្រាចារ្យ និងមិត្តភក្តិទាំងអស់អោយជួបប្រទះនូវពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ ព្រមទាំងទទួលបានជោគជ័យរាល់ភារកិច្ច។

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចអស់រយៈពេល៤ឆ្នាំកន្លងមក យើងខ្ញុំទាំងពីរមានការចាប់អារម្មណ៍យ៉ាងខ្លាំងលើនីតិកម្មសិទ្ធិបញ្ញា ជាពិសេសសិទ្ធិអ្នកនិពន្ធ ដោយហេតុថាការយល់ដឹងរបស់ប្រជាពលរដ្ឋទៅលើសិទ្ធិអ្នកនិពន្ធពុំទាន់មានភាពទូលំទូលាយ ចំណែកឯបុគ្គលដែលពាក់ព័ន្ធផ្ទាល់ មានដូចជាអ្នកនិពន្ធ ឬម្ចាស់សិទ្ធិក៏កំពុងតែជួបប្រទះនូវបញ្ហារំលោភសិទ្ធិ ដែលពិបាកនឹងដោះស្រាយផងដែរ ជាងនេះទៅទៀត ឯកសារដែលពាក់ព័ន្ធដើម្បីធ្វើការស្រាវជ្រាវក៏ពុំសូវមានច្រើន។

ដោយសារវាជាសញ្ញាណអវិជ្ជមានមួយសម្រាប់អ្នកសិក្សា ក៏ដូចជារូបខ្ញុំផ្ទាល់ក្នុងការស្វែងយល់បន្ថែមបញ្ហានេះ យើងខ្ញុំសម្រេចជ្រើសយកប្រធានបទស្តីពី **សិទ្ធិអ្នកនិពន្ធ - ការវិវាទសិទ្ធិ និងយន្តការដោះស្រាយការរំលោភសិទ្ធិនៅកម្ពុជា** ដើម្បីធ្វើការស្រាវជ្រាវ និងចងក្រងជាឯកសារដោយមិនមានការរួញរា។ តាមរយៈការស្រាវជ្រាវមួយនេះ យើងខ្ញុំសង្ឃឹមថា យើងខ្ញុំនឹងទទួលបាននូវចំណេះដឹងថ្មីៗសម្រាប់ខ្លួនឯង ព្រមទាំងចែករំលែកទៅឲ្យមិត្តអ្នកអាន ក៏ដូចជាប្អូនៗនិស្សិតជំនាន់ក្រោយ។

យើងខ្ញុំពិតជាមានមោទកភាព ចំពោះការខិតខំប្រឹងប្រែងប្រកបដោយភាពអំណត់ និងតស៊ូរបស់ក្រុមយើងខ្ញុំក្នុងការបង្កើតសៀវភៅមួយក្បាលនេះឡើង ព្រោះការស្រាវជ្រាវនេះជាការស្រាវជ្រាវថ្មីមួយស្របពេលដែលការយល់ដឹងប្រជាជនកម្ពុជានៅមានកម្រិត និងកង្វះនូវការអនុវត្តសិទ្ធិប្រកបដោយប្រសិទ្ធិភាព។ ជាងនេះទៅទៀតសៀវភៅនេះ ត្រូវបានបង្កើតឡើងក្នុងខណៈពេលដែលយើងខ្ញុំមានការលំបាកក្នុងការស្វែងរកឯកសារ និងសរសេរឲ្យបានត្រឹមត្រូវតាមក្បួនខ្នាត។ សមិទ្ធផលមួយនេះត្រូវបានសរសេររំលេចអំពីទ្រឹស្តីដែលមានចែងក្នុងច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ដែលចេញដោយក្រសួង ស្ថាប័នពាក់ព័ន្ធ សៀវភៅរបស់អ្នកនិពន្ធផ្សេងៗ និងឯកសារយោងជាច្រើនទៀត ព្រមទាំងបានរំលេចនូវស្ថានភាពជាក់ស្តែងដែលកើតមានក្នុងសង្គមបច្ចុប្បន្ន។

ជាចុងក្រោយ យើងខ្ញុំទាំងពីរសូមធ្វើការអភ័យទោសនូវរាល់កំហុសឆ្គងនានា រួមមានទាំងពាក្យពេចន៍ អក្ខរាវិរុទ្ធ និងរាល់ចំណុចខ្វះខាតទាំងឡាយដែលកើតមានឡើងដោយអចេតនា ព្រោះការយល់ដឹង និងបទពិសោធន៍របស់យើងខ្ញុំនៅមានកម្រិតនៅឡើយ។ យើងខ្ញុំទាំងពីរនាក់រីករាយទទួលយកនូវ ការរិះគន់ក្នុងន័យស្ថាបនាពីលោក លោកស្រីសាស្ត្រាចារ្យ និងមិត្តអ្នកអានទាំងអស់ដើម្បីឲ្យសារណានេះកាន់តែមានភាពល្អប្រសើរឡើង។

# ឧទ្ទិសស្នាដៃ

នាងខ្ញុំឈ្មោះ **រឿន ស្រីម៉ុម** និងនាងខ្ញុំឈ្មោះ **អ៊ុំ ស្រីធី** សូមឧទ្ទិសស្នាដៃ ដែលកើតចេញពីការស្រាវជ្រាវលើប្រធានបទ **សិទ្ធិអ្នកនិពន្ធ-ការរំលោភសិទ្ធិ និងយន្តការដោះស្រាយការរំលោភសិទ្ធិនៅកម្ពុជា** នេះជូនចំពោះ៖

- លោកឪពុក **លី រឿន** និងអ្នកម្ដាយ **យាត យឿង**
- លោកឪពុក **ព្រំ អួន** និងអ្នកម្ដាយ **លាស់ គឹមនាង**

លោកទាំងពីរមានគុណូបការៈយ៉ាងធំធេងលើកូនទាំងទ្វេ ព្រមទាំងជួយទំនុកបម្រុងកូនឲ្យបានសិក្សារហូតមកដល់សព្វថ្ងៃនេះ។

- លោក លោកស្រីសាស្ត្រាចារ្យទាំងអស់ ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយ និងចិត្តក្នុងការបង្ហាត់បង្រៀន និងស្វែងរកឯកសារនានា ដើម្បីឲ្យយើងខ្ញុំទទួលបាននូវចំណេះដឹងយ៉ាងពិតប្រាកដ។
- បញ្ញាវន្ត អ្នកប្រាជ្ញទាំងឡាយ ដែលខំចំណាយពេលវេលាក្នុងការស្រាវជ្រាវ និងចំណាយថវិកាផ្ទាល់ខ្លួន ដើម្បីចងក្រង តែងនិពន្ធស្នាដៃអក្សរសាស្ត្រគ្រប់ប្រភេទ ដើម្បីទុកជាឯកសារសម្រាប់អ្នកសិក្សាជំនាន់ក្រោយ។
- អ្នកសិក្សារួមជំនាន់ដែលបានជួយផ្ដល់ជាយោបល់ និងកែតម្រូវលើចំណុចខ្វះខាតដែលកើតមានឡើងក្នុងដំណើរការសរសេរសារណានេះ។
- ឪពុកម្ដាយគ្រប់រូបដែលលះបង់ធនធាន ក្នុងការបញ្ជូនបុត្រធីតារបស់ខ្លួនឲ្យទៅសាលារៀន ព្រោះមានតែចំណេះវិជ្ជាទេ ដែលអាចជួយចម្លងកូនៗឲ្យផុតពីនរកនៃភាពអវិជ្ជា និងអាចអភិវឌ្ឍសង្គមគ្រួសារ ព្រមទាំងប្រទេសជាតិទាំងមូល។

សូមឲ្យមនសិការមួយនេះ ស្ថិតនៅជាប់ជានិច្ចក្នុងដួងព្រលឹងពលរដ្ឋខ្មែរគ្រប់រូប!
សូមឲ្យព្រះរាណាចក្រកម្ពុជា មានសន្តិភាព ស្ថេរភាព និងជារាជាណាចក្រអច្ឆរិយៈដរាបរៀងទៅ!
សូមឲ្យកូនខ្មែរគ្រប់រូប ខិតខំសិក្សា រៀនសូត្រ ស្វាធ្យាយ ដើម្បីយកចំណេះដឹងមកបម្រើប្រទេសជាតិ និងអភិវឌ្ឍន៍ប្រទេសប្រកបដោយចីរភាព។

# មាតិកា

**សេចក្តីផ្តើម**...........................................................................................................................១


## ជំពូកទី ១

## ស្នាដៃអ្នកនិពន្ធ និងកិច្ចការពារស្នាដៃអ្នកនិពន្ធ

**១.១. ស្នាដៃអ្នកនិពន្ធ** ...........................................................................................................៤
១.១.១. ប្រវត្តិសង្ខេបនៃការកកើតច្បាប់សិទ្ធិអ្នកនិពន្ធនៅកម្ពុជា.............................................៤
១.១.២. សញ្ញាណគតិយុត្តនៃស្នាដៃ និងអ្នកនិពន្ធស្នាដៃ ........................................................៥
១.១.៣. សញ្ញាណនៃកិច្ចសន្យា..............................................................................................៨
១.១.៤. អនុភាពនៃកិច្ចសន្យា ...............................................................................................៩
១.១.៥. ប្រភេទនៃស្នាដៃ.......................................................................................................១០
១.២. កិច្ចការពារស្នាដៃអ្នកនិពន្ធ ........................................................................................ ១១
១.២.១. លក្ខខណ្ឌទម្រង់នៃការការពារ................................................................................ ១១
១.២.២. លក្ខខណ្ឌគ្រឹះនៃការការពារ ....................................................................................១៣


## ជំពូកទី ២

## ការអនុវត្តលើសិទ្ធិអ្នកនិពន្ធ

២.១. ប្រភេទនៃសិទ្ធិដែលទទួលបានពីស្នាដៃ .................................................................. ១៦
២.១.១. សិទ្ធិសីលធម៌.......................................................................................................... ១៦
២.១.២. សិទ្ធិបេតិកភណ្ឌរបស់អ្នកនិពន្ធ .............................................................................២០
២.១.៣. អញ្ញត្រកម្មនៃសិទ្ធិបេតិកភណ្ឌ..............................................................................២២
២.១.៤. ការចាត់ចែងលើសិទ្ធិបេតិកភណ្ឌ.............................................................................២៤
២.២. ការការពារសិទ្ធិអ្នកនិពន្ធ .........................................................................................២៨
២.២.១. លក្ខខណ្ឌទទួលបានសិទ្ធិការពារលើស្នាដៃ................................................................២៩
២.២.២. ការរក្សាសិទ្ធិ Copyright© ......................................................................................២៩


## ជំពូកទី ៣

## ការរំលោភសិទ្ធិអ្នកនិពន្ធ និងយន្តការដោះស្រាយ

៣.១. ការរំលោភសិទ្ធិអ្នកនិពន្ធ ..........................................................................................៣១

៣.១.១. រូបភាពនៃអំពើរំលោភសិទ្ធិអ្នកនិពន្ធ ........ ៣១
៣.១.២. ទណ្ឌកម្មពិន័យ និងព្រហ្មទណ្ឌនៃអំពើរំលោភសិទ្ធិអ្នកនិពន្ធ ........ ៣២
៣.២. ការចាត់វិធានការការពារសិទ្ធិអ្នកនិពន្ធ ........ ៣៣
៣.២.១. វិធានការជូនដំណឹង ........ ៣៣
៣.២.២. វិធានការបណ្តោះអាសន្ន ........ ៣៤
៣.២.៣. វិធានការតាមមាត់ច្រកព្រំដែន ........ ៣៥
៣.២.៤. វិធានការតាមផ្លូវតុលាការ ........ ៣៩
៣.២.៥. អង្គភាពគ្រប់គ្រងសិទ្ធិរួម ........ ៤១
**សេចក្តីសន្និដ្ឋាន** ........ ៤៣
**អនុសាសន៍** ........ ៤៥
**ឯកសារពិគ្រោះ**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ការសិក្សាសិទ្ធិអ្នកនិពន្ធនៅកម្ពុជា មានសារៈសំខាន់ខ្លាំងណាស់ចំពោះនិស្សិតខ្មែរគ្រប់រូប និងអ្នកអនុវត្តន៍ច្បាប់ទាំងអស់ដែលត្រូវតែយល់ដឹងថា **"អ្វីទៅជាសិទ្ធិអ្នកនិពន្ធនៅកម្ពុជា"** ទើបអាចថែរក្សាតម្លៃអ្នកនិពន្ធ និងលើកកម្ពស់ការសិក្សាស្រាវជ្រាវ ព្រមទាំងធ្វើអោយប្រទេសរីកចម្រើន។ ប្រទេសជាតិមួយមានការរីកចម្រើនដរាបណាមានអ្នកនិពន្ធ អ្នកសិក្សាស្រាវជ្រាវដែលចេះថែរក្សាតម្លៃស្នាដៃទាំងអស់នោះឲ្យបានគង់វង្ស ជៀសផុតពីការលួចចម្លងស្នាដៃដោយខុសច្បាប់។

ស្នាដៃអ្នកនិពន្ធ សំដៅដល់ស្នាដៃបង្កើតថ្មីដែលកើតចេញពីគំនិតរបស់បុគ្គលម្នាក់ ឬច្រើននាក់ រួមមាន៖ ស្នាដៃអក្សរសាស្ត្រ សិល្បៈ តូរ្យតន្ត្រី នាដកម្ម និងស្នាដៃអេឡិចត្រូនិច។ អ្នកនិពន្ធស្នាដៃជាអ្នកទទួលបាននូវសិទ្ធិជាម្ចាស់កម្មសិទ្ធិផ្តាច់មុខទៅលើស្នាដៃនោះ ហើយជាសិទ្ធិដែលជនគ្រប់រូបទទួលស្គាល់។ សិទ្ធិនេះរួមមានសិទ្ធិបេតិកភណ្ឌ និងសិទ្ធិសីលធម៌។

អ្នកនិពន្ធមានសិទ្ធិក្នុងការប្រើប្រាស់ស្នាដៃរបស់ខ្លួន ឬអនុញ្ញាតឲ្យគេប្រើប្រាស់ស្នាដៃនោះជំនួសខ្លួន។ តតិយជនអាចប្រើប្រាស់ស្នាដៃរបស់អ្នកនិពន្ធបាន លុះត្រាតែមានការអនុញ្ញាតពីអ្នកនិពន្ធ។ ការប្រើប្រាស់ស្នាដៃធ្វើឡើងក្រោមរូបភាពដូចមានចែងក្នុងច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ពោលគឺការផលិតឡើងវិញ ការផ្សព្វផ្សាយជាសាធារណៈ និងការបង្កើតស្នាដៃបន្ត។

តាមការរៀបរាប់នៃបទប្បញ្ញត្តិខាងលើ សិទ្ធិបេតិកភណ្ឌរបស់អ្នកនិពន្ធជាសិទ្ធិអាចផ្ទេរបាន និងស្តែងឡើងក្រោមរូបភាពពីរគឺ ផ្ទេរតាមរយៈកិច្ចសន្យា និងផ្ទេរតាមរយៈច្បាប់។ ម៉្យាងវិញទៀតសិទ្ធិនេះ គឺជាសិទ្ធិដែលមានអាជ្ញាយុកាលកំណត់ក្នុងការទទួលបានកិច្ចការពារ។ លើសពីនេះទៀតការធ្វើអាជីវកម្មលើសិទ្ធិបេតិកភណ្ឌនៃអ្នកនិពន្ធ ត្រូវបានច្បាប់កម្រិតដើម្បីជៀសវាងការរំលោភសិទ្ធិ។

ជាការពិតណាស់នៅក្នុងសង្គមខ្មែរនាពេលបច្ចុប្បន្ន ការប្រកបរបរធ្វើជាអ្នកនិពន្ធតែម្យ៉ាងគឺមិនអាចផ្គត់ផ្គង់ជីវភាពឲ្យបានធូរធារនោះទេ ប៉ុន្តែអ្វីដែលជាកត្តាចម្បងក្នុងការជម្រុញឲ្យកវីនិពន្ធទាំងឡាយនៅតែបន្តការសរសេររបស់ខ្លួន គឺទឹកចិត្តស្រលាញ់វប្បធម៌ និងអរិយធម៌ជាតិ។ ទឹកចិត្តរបស់កវីនិពន្ធពិតជាមានអត្ថន័យជ្រៀលជ្រៅបំផុត និងមានគុណូបការៈដ៏ធំធេងដល់ប្រទេសជាតិដែលមនុស្សគ្រប់រូបគួរយកចិត្តទុកដាក់ និងគោរពកោតសរសើរ។ ជាក់ស្តែងនៅពេលបច្ចុប្បន្ននេះអ្វីដែលអ្នកនិពន្ធទទួលបាន គឺមានតែការព្រួយបារម្ភ និងភាពសោកស្តាយចំពោះស្នាដៃរបស់ខ្លួនដែលខំបង្កើតឡើងតែត្រូវបានជនខិលខូចលួចយកទៅធ្វើជាផលប្រយោជន៍ផ្ទាល់ខ្លួន។ ពីមួយថ្ងៃទៅមួយថ្ងៃជម្ងឺបាក់ទឹកចិត្ត បានបណ្តាលឲ្យអ្នកនិពន្ធបោះបង់ចោលការតែងនិពន្ធរបស់ខ្លួន ឬអ្នកដែល

មានចំណេះដឹងជ្រៅជ្រះលើផ្នែកអ្វីមួយ លែងហ៊ានចងក្រងតាក់តែងជាស្នាដៃ ដូចជាអត្ថបទសិក្សា តន្ត្រី ទំនុកភ្លេង ទំនុកបទចម្រៀងជាដើម។

តើកត្តាអ្វីខ្លះធ្វើឲ្យអ្នកនិពន្ធជាច្រើន មានជម្ងឺបាក់ទឹកចិត្តមិនចង់បង្កើតស្នាដៃថ្មីទៀត?

ជាការពិតណាស់ មេរោគដ៏ធំបំផុតដែលបង្កជាជម្ងឺបាក់ទឹកចិត្តដល់អ្នកនិពន្ធភាគច្រើនគឺការរំលោភបំពានលើសិទ្ធិអ្នកនិពន្ធ។ តើការរំលោភបំពានសិទ្ធិអ្នកនិពន្ធស្តែងឡើងយ៉ាងដូចម្តេច? ការរំលោភបំពានលើសិទ្ធិអ្នកនិពន្ធស្តែងឡើងតាមរយៈសកម្មភាពដូចជា ការថតចម្លង ការយកគំរូ និងការយកលំនាំតាម ឬយកទៅច្នៃធ្វើជាស្នាដៃរបស់ខ្លួន ដោយមិនមានការអនុញ្ញាតពីអ្នកនិពន្ធ។ ទង្វើអសីលធម៌បែបនេះបង្កផលប៉ះពាល់យ៉ាងខ្លាំងដល់អ្នកនិពន្ធ និងការរីកចម្រើនរបស់ប្រទេសជាតិ ពីព្រោះអ្នកនិពន្ធត្រូវបាត់បង់ផលកម្រៃពីស្នាដៃរបស់ខ្លួន បាត់បង់កេរ្តិ៍ឈ្មោះ ដែលជះឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំងដល់ស្ថានភាពរស់នៅរបស់ពួកគេ។ ជាពិសេស ប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះអ្នកនិពន្ធណាដែលយកការតែងនិពន្ធជាអាជីពតែមួយរបស់ខ្លួន។ អ្វីដែលខាតបង់ធំបំផុតសម្រាប់ប្រទេសជាតិនោះប្រហែលជាលែងមានអ្នកនិពន្ធដែលខិតខំស្រាវជ្រាវស្នាដៃថ្មីៗ ឬការបង្កើតថ្មីសម្រាប់ប្រទេសជាតិ និងមនុស្សជំនាន់ក្រោយ។

ដើម្បីការពារសិទ្ធិអ្នកនិពន្ធ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើសេចក្តីព្រាងច្បាប់ស្តីពី "សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល" តាមសំណើររបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដាក់ជូនរដ្ឋសភាអនុម័ត ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣។

កាស្រាវជ្រាវនេះមានគោលបំណង ពន្យល់អំពីអត្ថន័យនៃសិទ្ធិអ្នកនិពន្ធ ស្វែងរកសញ្ញាណនៃការរំលោភសិទ្ធិ ដំណោះស្រាយ និងទណ្ឌកម្មចំពោះការរំលោភសិទ្ធិអ្នកនិពន្ធ ជាពិសេសស្វែងយល់ពីការវិត្តនៃសិទ្ធិអ្នកនិពន្ធនៅកម្ពុជា។ ពលរដ្ឋកម្ពុជាគ្រប់រូបត្រូវចូលរួមគោរពសិទ្ធិអ្នកនិពន្ធ រួមទាំងការពារនូវផលិតផលវប្បធម៌ ស្នាដៃនិពន្ធ អ្នកសម្តែង ផលិតករ និងអង្គភាពពាក់ព័ន្ធនានា។ ការសិក្សាអំពីសិទ្ធិអ្នកនិពន្ធនេះបានដកស្រង់ចេញពីទ្រឹស្តីដែលមានចែងក្នុងច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ដែលចេញដោយក្រសួង ស្ថាប័នពាក់ព័ន្ធ សៀវភៅរបស់អ្នកនិពន្ធ និងឯកសារជាច្រើនផ្សេងៗទៀត ព្រមទាំងបានរំលេចនូវស្ថានភាពជាក់ស្តែង ដែលកើតមាននៅក្នុងសង្គមខ្មែរបច្ចុប្បន្ន។

លទ្ធផលដែលកើតចេញពីការស្រាវជ្រាវនេះ នឹងចូលរួមចំណែកក្នុងការផ្តល់ជាចំណេះដឹងទាក់ទងសិទ្ធិអ្នកនិពន្ធនៅប្រទេសកម្ពុជា ដែលបានអនុលោមតាមច្បាប់ស្តីពីសិទ្ធអ្នកនិពន្ធ និងសិទ្ធិ

ប្របាក់ប្របហែលឆ្នាំ២០០៣ ក៏ដូចជាចូលរួមចំណែកលើកស្ទួយវិស័យអ្នកនិពន្ធ និងកាត់បន្ថយការរំលោភសិទ្ធិអ្នកនិពន្ធ ដែលតែងតែកើតមានឡើងដោយចេតនាក្តី និងអចេតនាក្តី។

វិសាលភាពនៃការស្រាវជ្រាវនេះផ្តោតលើ ស្នាដៃអ្នកនិពន្ធ សិទ្ធិអ្នកនិពន្ធ ការរំលោភសិទ្ធិ និងយន្តការដោះស្រាយសិទ្ធិអ្នកនិពន្ធនៅកម្ពុជា ចាប់ពីឆ្នាំ២០០៣ ដល់ឆ្នាំ២០១៩ រួមជាមួយវិធាននានាដែលអនុវត្តន៍នៅក្នុងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដែលជាសាមីក្រសួងត្រូវទទួលបន្ទុកលើសិទ្ធិអ្នកនិពន្ធនៅក្នុងប្រទេសកម្ពុជា។ គួរបញ្ជាក់ផងដែរថា ការការពារសិទ្ធិអ្នកនិពន្ធនៅកម្ពុជាត្រូវប្រើប្រាស់ទាំងយន្តការច្បាប់ជាតិ និងយន្តការច្បាប់អន្តរជាតិ ក្នុងការដោះស្រាយចំពោះការរំលោភសិទ្ធិអ្នកនិពន្ធ ប៉ុន្តែក្នុងការសរសេរសារណានេះ ក្រុមយើងខ្ញុំសូមលើកយកតែយន្តការច្បាប់ជាតិមួយប៉ុណ្ណោះដើម្បីធ្វើការបកស្រាយដោយសារពេលវេលា និងមធ្យោបាយស្រាវជ្រាវមានដែនកំណត់។

តើអ្វីជាសិទ្ធិអ្នកនិពន្ធ? តើស្នាដៃអ្វីខ្លះដែលត្រូវបានទទួលការការពារពីច្បាប់? តើអំពើបែបណាដែលចាត់ទុកជាការរំលោភសិទ្ធិអ្នកនិពន្ធ? តើកម្ពុជាមានយន្តការដោះស្រាយបែបណាចំពោះជនល្មើសលើសិទ្ធិអ្នកនិពន្ធ? សំណួរទាំងអស់នេះនឹងស្រាយបំភ្លឺក្នុងប្រធានបទស្តីពី **សិទ្ធិអ្នកនិពន្ធ ការវិវាទសិទ្ធិ និងយន្តការដោះស្រាយការរំលោភសិទ្ធិនៅកម្ពុជា** ដែលនឹងត្រូវធ្វើការបង្ហាញក្នុងបីដំណាក់កាលដូចខាងក្រោមនេះ៖

**ជំពូកទី១ ស្នាដៃអ្នកនិពន្ធ និងកិច្ចការពារស្នាដៃអ្នកនិពន្ធ**

**ជំពូកទី២ ការអនុវត្តសិទ្ធិអ្នកនិពន្ធ**

**ជំពូកទី៣ ការរំលោភសិទ្ធិអ្នកនិពន្ធ និងយន្តការដោះស្រាយ**

# ជំពូកទី១
# ស្នាដៃអ្នកនិពន្ធ
# និង
# កិច្ចការពារស្នាដៃអ្នកនិពន្ធ

# ជំពូកទី ១
# ស្នាដៃអ្នកនិពន្ធ និងកិច្ចការពារស្នាដៃអ្នកនិពន្ធ

## ១.១. ស្នាដៃអ្នកនិពន្ធ

### ១.១.១. ប្រវត្តិសង្ខេបនៃការកើតច្បាប់សិទ្ធិអ្នកនិពន្ធនៅកម្ពុជា

សិទ្ធិអ្នកនិពន្ធ គឺជាគន្លឹះដ៏សំខាន់មួយសម្រាប់ការអភិវឌ្ឍសង្គមជាតិ និងជាមជ្ឈមណ្ឌល ឧស្សាហកម្មវប្បធម៌ សម្ភារៈសិល្បៈ សៀវភៅសិក្សា សៀវភៅវិទ្យាសាស្ត្រ ភាពយន្ត រូបភាព ចម្រៀង និងវីដេអូ...។ សព្វថ្ងៃនេះការរីកចម្រើនផ្នែកបច្ចេកទេសឌីជីថល កំពុងតែមានការវិវឌ្ឍយ៉ាងខ្លាំងតាម រយៈការផ្សព្វផ្សាយលើបណ្តាញអ៊ិនធឺណែត ដែលធ្វើឱ្យពិភពលោកមានការចាប់អារម្មណ៍។

មជ្ឈមណ្ឌលវប្បធម៌អាស៊ីប៉ាស៊ីហ្វិកសម្រាប់អង្គការយូណេស្កូហៅកាត់ថា ACCU ក៏បាន ជម្រុញឲ្យមានចំណេះដឹងស្តីពី សិទ្ធិអ្នកនិពន្ធទៅក្នុងបណ្តាប្រទេសអាស៊ានផងដែរ។ ចាប់តាំងពីការ បង្កើតឡើងនូវកូនសៀវភៅដែលមានចំណងជើងថា "**សៀវភៅសិទ្ធិអ្នកនិពន្ធអាស៊ាន**" ជាភាសា អង់គ្លេសនៅឆ្នាំ២០០៤ មជ្ឈមណ្ឌលវប្បធម៌អាស៊ីប៉ាស៊ីហ្វិកសម្រាប់អង្គការយូណេស្កូ បានរៀបចំ សិក្ខាសាលាថ្នាក់ជាតិនៅប្រទេសវៀតណាម ឥណ្ឌូនេស៊ី ម៉ុងហ្គោលី ភូមា និងប្រទេសបង់ក្លាដេស ដើម្បីផ្សព្វផ្សាយព័ត៌មានជាមូលដ្ឋាននៃសិទ្ធិអ្នកនិពន្ធ ក្នុងគោលបំណងជម្រុញឲ្យមានចំណេះដឹង អំពីសិទ្ធិអ្នកនិពន្ធ និងជួយបោះពុម្ពកូនសៀវភៅនេះជាភាសាជាតិរបស់ប្រទេសនោះ។

ព្រះរាជាណាចក្រកម្ពុជា បានឆ្លងកាត់សង្គ្រាមស៊ីវិលជាងពីរទសវត្សរ៍កន្លងមកហើយដូច្នេះ ហេដ្ឋារចនាសម្ព័ន្ធនៃប្រទេសត្រូវបានបំផ្លាញ មិនត្រឹមតែវិស័យសេដ្ឋកិច្ច អប់រំ ធនធានមនុស្ស ប៉ុណ្ណោះទេថែមទាំងវិស័យច្បាប់ក៏ត្រូវបានបំផ្លាញផងដែរ។ ប៉ុន្តែជាភ័ព្វសំណាងបន្ទាប់ពីព្រះរាជា ណាចក្រកម្ពុជាបានរៀបចំការបោះឆ្នោតដោយសេរីនឹងត្រឹមត្រូវដោយ UNTAC ឆ្នាំ១៩៩៣ មកសភា ជាតិ និងរាជរដ្ឋាភិបាលកម្ពុជាបានព្យាយាមកសាង និងអនុម័តច្បាប់ជាបណ្តើរៗដើម្បីជាប្រយោជន៍ ក្នុងការអភិវឌ្ឍ និងស្តារប្រទេសជាតិឡើងវិញ ។ ទន្ទឹមនឹងនេះការរំលោភបំពានច្បាប់នៅតែកើត មានជាពិសេសច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល។ បញ្ហានេះក៏ជាកត្តាធ្វើឲ្យរាំងស្ទះ ដល់ការអភិវឌ្ឍប្រទេសជាតិដែរ។ ដោយឃើញស្ថានភាពដ៏ចម្បងនេះ រាជរដ្ឋាភិបាលកម្ពុជាបាន កំណត់អោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ទទួលបន្ទុកធ្វើសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលឡើង ដែលច្បាប់នេះត្រូវបានចូលជាធរមាននៅឆ្នាំ២០០៣ វាស្របតាម កិច្ចព្រមព្រៀង TRIPS និងច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលអន្តរជាតិ។

### ១.១.២. សញ្ញាណគតិយុត្តនៃស្នាដៃ និងអ្នកនិពន្ធស្នាដៃ

#### ក. និយមន័យនៃស្នាដៃអ្នកនិពន្ធ

**ស្នាដៃអ្នកនិពន្ធ** គឺជាផលិតផលខាងវិស័យអក្សរសាស្ត្រ វិទ្យាសាស្ត្រ សិល្បៈ តូរ្យតន្ត្រី ដែលកើតចេញពីការច្នៃប្រឌិតបង្កើតឡើងដោយគំនិតប្រាជ្ញា ឬមនោសញ្ចេតនា[1]។

អ្នកតាក់តែងច្បាប់នៅកម្ពុជា បានកំណត់នូវស្នាដៃជាកម្មវត្ថុនៃកិច្ចការពារតាមរយៈសិទ្ធិអ្នកនិពន្ធមានជាអាទិ៍[2]៖

- សៀវភៅគ្រប់ប្រភេទ ឬឯកសារផ្សេងៗទៀតស្តីពីអក្សរសាស្ត្រ សិល្បៈ វិទ្យាសាស្ត្រ និង ការអប់រំ។
- ស្នាដៃនាដកម្ម និងនាដកម្ម-តូរ្យតន្ត្រី។
- ស្នាដៃរបាំសម័យ ឬយកតាមលំនាំស្នាដៃបុរាណ ឬប្រពៃណី។
- ការសម្តែងសៀក និងការសម្តែងកាយវិការ។
- ការតែងបទភ្លេងដោយមាន ឬគ្មានទំនុកច្រៀង។
- ស្នាដៃសោតទស្សន៍។
- ស្នាដៃជាផ្ទាំងគំនូរ ផ្ទាំងចម្លាក់ ឬស្នាដៃផ្សេងៗទៀតខាងសិល្បៈសូន្យរូប ឬសិល្បៈអនុវត្ត។
- ស្នាដៃថតរូប និងស្នាដៃទាំងឡាយដែលសម្រេចបានដោយមានជំនួយបច្ចេកទេស ដូចគ្នានិងការថតរូប។
- ស្នាដៃស្ថាបត្យកម្ម។
- ផែនទី ប្លង់ គំនូសវាស ឬស្នាដៃស្តែងចេញជារូបទាក់ទងនឹងភូមិសាស្ត្រ ឋានលេខា ឬវិទ្យាសាស្ត្រនានា។
- កម្មវិធីកុំព្យូទ័រ និងគម្រោងឯកសារសមោធានទាក់ទងនឹងកម្មវិធីនោះ។
- ផលិតផលផ្នែកសិប្បកម្ម តម្បាញ ឬម៉ូតសម្លៀកបំពាក់ផ្សេងៗ។

☞ ប៉ុន្តែមានស្នាដៃមួយចំនួនទៀតមិនអនុញ្ញាតឲ្យទទួលបានកិច្ចការពារតាមរយៈសិទ្ធិអ្នកនិពន្ធឡើយរួមមាន៖ អត្ថបទច្បាប់ និងបទដ្ឋានគតិយុត្តរបស់រដ្ឋដែលត្រូវបានអនុម័តដោយសភាជាតិ បទដ្ឋានគតិយុត្ត ឬលិខិតរដ្ឋបាលចេញដោយរាជរដ្ឋាភិបាល និងអាជ្ញាធរសាធារណៈរបស់រដ្ឋ។ ចំពោះស្នាដៃប្រភេទនេះ បុគ្គលណាក៏មានសិទ្ធិថតចម្លងដើម្បីយកមកសិក្សាស្វែងយល់ផងដែរ។

[1] មាត្រា ២-ក នៃច្បាប់សិទ្ធិអ្នកនិពន្ធ ឆ្នាំ២០០៣

[2] មាត្រា ៧ នៃច្បាប់សិទ្ធិអ្នកនិពន្ធ ឆ្នាំ២០០៣

### ខ. គុណវុឌ្ឍិជាអ្នកនិពន្ធ

តើបុគ្គលបែបណាដែលអាចមានឋានៈជា អ្នកនិពន្ធ ឬម្ចាស់ស្នាដៃ?

ជាគោលការណ៍ ឋានៈជាអ្នកនិពន្ធត្រូវបានប្រគល់ទៅឲ្យអ្នកដែលបានបង្កើតស្នាដៃ។ ច្បាប់នៃប្រទេសកម្ពុជាបានកំណត់និយមន័យថា "អ្នកនិពន្ធ" គឺជាជនដែលបានបង្កើតស្នាដៃ។ យោងតាមនិយមន័យនេះមានតែរូបវន្តបុគ្គលម្នាក់ប៉ុណ្ណោះទើបអាចមានឋានៈជាអ្នកនិពន្ធបាន។ ឋានៈជាអ្នកនិពន្ធ អាចផ្តល់ទៅឲ្យរូបវន្តបុគ្គលម្នាក់(ហៅថា "អ្នកនិពន្ធ") ឬច្រើននាក់(ហៅថា "សហអ្នកនិពន្ធ")[3]។ ស្នាដៃដែលបានបង្កើតឡើយដោយសហអ្នកនិពន្ធហៅថា ស្នាដៃសហការ។

តើនីតិបុគ្គលអាចមានឋានៈជាអ្នកនិពន្ធបានដែរឬទេ? នីតិបុគ្គល គឺជាបុគ្គលអរូបិយពុំមានគំនិត មនោសញ្ចេតនា ឬអវៈយវៈដើម្បីបង្កើតស្នាដៃនោះទេផ្ទុយទៅនឹងនិយមន័យនៃស្នាដៃដែលបានកំណត់ខាងលើ ដូចនេះនីតិបុគ្គលពុំមានគុណវុឌ្ឍិជាអ្នកនិពន្ធឡើយ។ ប៉ុន្តែនីតិបុគ្គលអាចជាម្ចាស់ស្នាដៃ នៅពេលដែលអ្នកបង្កើតស្នាដៃបានប្រគល់សិទ្ធិជាម្ចាស់ស្នាដៃទៅឲ្យនីតិបុគ្គនោះ។

### គ. ស្នាដៃត្រូវតែជាផលិតផលនៃគំនិតប្រាជ្ញា

ដោយសារតែស្នាដៃជាផ្នែកមួយនៃកម្មសិទ្ធិបញ្ញា និងជាផលិតផលនៃការខិតខំប្រឹងប្រែងត្រិះរិះព្យាយាមខាងបញ្ញាក្នុងការបង្កើតនូវគំនិតថ្មី ដូចនេះស្នាដៃត្រូវតែទទួលបានការការពារនឹងទទួលស្គាល់លើស្នាដៃដែលបានបង្កើតនោះ។ ស្នាដៃអ្នកនិពន្ធត្រូវតែមានភាពដាច់ស្រឡះអំពីផលនៃរបកគំហើញ(ការរកឃើញថ្មី) ផលនៃការជួបប្រទះដោយចៃដន្យណាមួយ ឬផលដែលបានប្រើប្រាស់នូវឧបករណ៍បច្ចេកទេសនានាដើម្បីចូលរួមបង្កើតស្នាដៃនោះឡើង។

### ឃ. ស្នាដៃពុំត្រូវជាផលនៃរបកគំហើញ ឬការប្រទះឃើញដោយចៃដន្យ

ស្នាដៃអ្នកនិពន្ធគឺជាកម្មវត្ថុ និងក៏ជាប្រភពផ្ទាល់នៃសិទ្ធិអ្នកនិពន្ធដែលត្រូវតែកើតចេញពីការខិតខំប្រឹងប្រែងផ្ទាល់របស់អ្នកនិពន្ធ។ គ្រប់អ្នកនិពន្ធទាំងអស់តែងប្រាថ្នាចង់បានសិទ្ធិលើស្នាដៃនោះដែលកើតចេញពីការបង្កើត និងច្នៃប្រឌិតរបស់ខ្លួន ពោលគឺមិនមែនកើតចេញពីភាពចៃដន្យ ឬយករបកគំហើញស្នាដៃដែលមានអត្ថិភាពស្រាប់មួយនោះទេ។ ដូចករណីអ្នកបុរាណវិទ្យាម្នាក់ប្រឹងប្រែងប្រើប្រាស់កម្លាំងញើសឈាម និងប្រាជ្ញារបស់ខ្លួនទៅតាមស្វែងរកទីបុរាណដ្ឋានផ្សេងៗ ដើម្បីទទួលបានសិទ្ធិជាអ្នកនិពន្ធ ប៉ុន្តែជាអកុសលសិទ្ធិជាម្ចាស់លើបុរាណដ្ឋាន គំនូរ ឬវិធីសាស្ត្រនោះពុំត្រូវបានផ្តល់ទៅឲ្យអ្នករកឃើញនោះទេ ព្រោះថាកម្មវត្ថុនៃសិទ្ធិនេះពុំអាចចាត់ទុកថាជាស្នាដៃរបស់អ្នកនិពន្ធបានឡើយ។

[3] មាត្រា ១១ នៃច្បាប់សិទ្ធិអ្នកនិពន្ធ៖ "ឋានៈជាអ្នកនិពន្ធ គឺជាឋានៈរបស់បុគ្គលម្នាក់ ឬច្រើននាក់ជាម្ចាស់កម្មសិទ្ធិលើស្នាដៃដែលសាមីខ្លួនបានបង្កើតឡើង ហើយស្នាដៃនោះត្រូវបានផ្សព្វផ្សាយជាសាធារណៈលើកលែងតែមានភស្តុតាងផ្ទុយ"។

### ខ. ស្នាដៃត្រូវតែមានរូបរាងជាក់លាក់

❖ **ស្នាដៃអ្នកនិពន្ធត្រូវតែមានរូបរាងជាក់លាក់**

ស្នាដៃត្រូវលេចចេញជារូបរាងជាក់លាក់ អាចឲ្យសាធារណជនយល់ និងទទួលស្គាល់ក្នុងន័យជាស្នាដៃខាងអក្សរសិល្ប៍ វិទ្យាសាស្ត្រ តូរ្យតន្ត្រី និងសិល្បៈដូចដែលច្បាប់បានបញ្ញត្តិត្រង់ មាត្រា ៧ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ។ ក្នុងន័យនេះស្នាដៃអ្នកនិពន្ធ ពុំមែនគ្រាន់តែជាតម្រុយណាមួយដែលមិនទាន់លេចចេញជារូបរាងជាក់លាក់ ហើយយកទៅឲសាធារណជនការពិចារណាលើស្នាដៃដែលគ្រាន់តែជាគំនិតនឹងសម្រេចជារូបរាងជំនួសអ្នកនិពន្ធបានឡើយ។

❖ **ទ្រឹស្តីនៃដំណាក់កាលទាំងបីក្នុងការបង្កើតស្នាដៃអ្នកនិពន្ធ**

តាមទ្រឹស្តីរបស់លោក Henri DESBOIS ដែលជាសាស្ត្រាចារ្យខាងនីតិកម្មសិទ្ធិបញ្ញាជនជាតិបារាំងដ៏ល្បីល្បាញម្នាក់ គ្រប់ការបង្កើតស្នាដៃទាំងអស់ត្រូវធ្វើឡើងជាបីដំណាក់សំខាន់ៗគឺ៖

- ***ទី១ គឺដំណាក់កាលនៃគំនិត***

  **ឧទាហរណ៍៖** គំនិតនៃការសរសេរប្រលោមលោកស្តីពីបុរសក្រីក្រម្នាក់ស្រលាញ់នារីជាកូនស្រីចៅហ្វាយនាយខ្លួន(ក្នុងរឿងកូលាបបៃលិន) ឬគំនិតនៃការបញ្ចូលគ្នារវាងសំលេង តន្ត្រីសម័យគ្រប់ប្រភេទ ជាមួយនិងសំលេងតន្ត្រីខ្មែរបុរាណ...។

- ***ទី២ គឺដំណាក់កាលនៃការបង្កើតគម្រោង***

  **ឧទាហរណ៍៖** គម្រោងនៃសៀវភៅអក្សរសិល្ប៍មួយ គឺជាការបង្កើតប្លង់ ឬរចនាសម្ព័ន្ធនៃដំណើររឿង ឯគម្រោងនៃស្នាដៃនៃគំនូរគឺសំដៅដល់ ការរៀបចំឧបករណ៍គូរនៅពីមុខរូប ឬទេសភាពដែលត្រូវគូរនោះ...។ ដំណាក់កាលទី១ និងទី២នេះហាក់ដូចជាពិបាកក្នុងការកំណត់អោយដាច់ស្រឡះពីគ្នាណាស់។

- ***ទី៣ គឺដំណាក់កាលនៃការបំពេញគម្រោង***

  **ឧទាហរណ៍៖** ការសរសេរប្រលោមលោក(ការប្រើប្រាស់ពាក្យពេចន៍ ឃ្លាប្រយោគដើម្បីពន្យល់សាច់រឿង...) តាមគម្រោងដែលបានបង្កើតឡើងនោះ ឬជាការគូរដើម្បីអោយសម្រេចជារូបរាងគំនូរ គឺស្ថិតនៅក្នុងដំណាក់កាលទី៣នេះឯងដែលទាមទារឲ្យអ្នកនិពន្ធស្នាដៃត្រូវបញ្ចេញនូវស្តាយ(រចនាបទ)របស់ខ្លួន ទៅបង្កើតជាស្នាដៃថ្មីមួយរបស់គេផ្ទាល់ដែលហៅថា "គំនិតប្រាជ្ញាផ្ទាល់របស់អ្នកនិពន្ធ"។ បន្ទាប់ពីបញ្ចប់ដំណាក់កាលនេះ ស្នាដៃអ្នកនិពន្ធមួយត្រូវទទួលបានការការពារទោះបីជាការសរសេរគូរ ឬការតែងនិពន្ធបានបញ្ចប់ ឬមិនទាន់បានបញ្ចប់សព្វគ្រប់ក៏ដោយចុះ[4]។

---

[4] ទាក់ទងនឹងគោលការណ៍ការពារស្នាដៃ ត្រូវបានទទួលស្គាល់ផងដែរដោយមាត្រា៥នៃច្បាប់សិទ្ធិអ្នកនិពន្ធ។

**ច. ទ្រឹស្តីនៃការការពារគំនិត**

គំនិតរបស់បុគ្គលម្នាក់ មិនមែនជាកម្មវត្ថុនៃសិទ្ធិអ្នកនិពន្ធឡើយ។ ស្នាដៃដែលកើតចេញពីគំនិតរបស់បុគ្គលត្រូវតែមានរូបរាងជាក់លាក់ ទើបអាចទទួលបានការការពារតាមរយៈច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ។ ក្នុងករណីមានភស្តុតាងបញ្ជាក់ថា គំនិតរបស់អ្នកនិពន្ធត្រូវបានតតិយជនលួចយកទៅអនុវត្តន៍ និងបង្កើតចេញជាទម្រង់ស្នាដៃមួយ ម្ចាស់គំនិតនោះអាចមានសិទ្ធិប្តឹង ទាមទារសំណងក្នុងឋានៈជាអ្នកនិពន្ធ ឬសហអ្នកនិពន្ធ។ ជាទូទៅករណីខាងលើនេះកើតមានឡើងចំពោះស្នាដៃសហការដែលមានសមាជិកណាម្នាក់ លួចយកគំនិតរួមទៅបង្កើតជាស្នាដៃតែម្នាក់ឯង និងបោះផ្សាយជាសាធារណៈក្នុងនាមផ្ទាល់ខ្លួន។ ដូចនេះ ម្ចាស់គំនិតដែលជាសហអ្នកនិពន្ធអាចមានសិទ្ធិប្តឹងបញ្ឈប់ការបោះផ្សាយ និង/ឬទាមទារសំណងសមស្របប្រសិនបើមានភស្តុតាងច្បាស់លាស់បញ្ជាក់ថាមានការលួចគំនិតរបស់សហអ្នកនិពន្ធ។

**១.១.៣. សញ្ញាណនៃកិច្ចសន្យា**

កិច្ចសន្យាអាចធ្វើឡើងដោយផ្ទាល់មាត់ ឬដោយលាយលក្ខណ៍អក្សរ។ រាល់ការអនុវត្តសិទ្ធិ ឬការធ្វើអាជីវកម្មលើស្នាដៃត្រូវអនុលោមតាមបទបញ្ញត្តិនៃកិច្ចសន្យាអនុប្បទានសិទ្ធិ ឬកិច្ចសន្យាអាជ្ញាប័ណ្ណ។ ក្នុងករណីនៃការធ្វើអាជីវកម្មលើស្នាដៃតាមរយៈកិច្ចសន្យា ច្បាប់សិទ្ធិអ្នកនិពន្ធតម្រូវឲ្យគូភាគីទាំងពីរបង្កើតកិច្ចសន្យាជាលាយលក្ខណ៍អក្សរ។ កិច្ចសន្យាធ្វើអាជីវកម្មលើស្នាដៃទាំងឡាយណាដែលបានធ្វើជាលាយលក្ខណ៍អក្សរ ជាកម្មវត្ថុនៃបណ្តឹងនៃមោឃភាព[5]។ ក្នុងករណីនេះច្បាប់បានផ្តល់សិទ្ធិទៅឲ្យអ្នកនិពន្ធ ឬម្ចាស់សិទ្ធិអាចប្តឹងសុំមោឃភាពបាន។ រាល់កិច្ចសន្យាធ្វើអាជីវកម្មលើស្នាដៃដែលកំពុងបំពេញលក្ខខណ្ឌជាលាយលក្ខណ៍អក្សរ កម្មវត្ថុនៃបណ្តឹងសូមប្តឹងមោឃភាពមិនដាច់ខាត។

**៦សិទ្ធិបេតិកភណ្ឌអាចត្រូវបានផ្ទេរឲ្យទៅទាយាទរបស់អ្នកនិពន្ធ** ឬតតីយជនតាមរយៈមតកសាសន៍បន្ទាប់ពីមរណភាពរបស់អ្នកនិពន្ធ។ ក្នុងករណីដែលពុំមានមតកសាសន៍ទេ ច្បាប់ផ្តល់សិទ្ធិឲ្យទៅអាជ្ញាធរដែលមានសមត្ថកិច្ច ដើម្បីគ្រប់គ្រងលើសិទ្ធិនៃស្នាដៃរបស់អ្នកនិពន្ធនោះ[6]។ អាជ្ញាធររបស់រដ្ឋដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រងសិទ្ធិបេតិកភណ្ឌនេះ គឺសំដៅទៅលើក្រសួងវប្បធម៌ និងវិចិត្រសិល្បៈនៃប្រទេសកម្ពុជា។

[5] មាត្រា ៣៩ នៃច្បាប់សិទ្ធិអ្នកនិពន្ធ។
[6] មាត្រា ៣៣ នៃច្បាប់សិទ្ធិអ្នកនិពន្ធ។

**៦ក្នុងក្របខណ្ឌនៃកិច្ចសន្យាការងារ ស្នាដៃដែលត្រូវបានរកឃើញថាស្ថិតក្រោមការបង្កើតឡើងដោយនិយោជិតក្រោមការបង្គាប់បញ្ជារពីនិយោជកត្រូវចាត់ទុកថា ជាកម្មសិទ្ធិរបស់នយោជក** ដោយយោងតាមគោលការណ៍ "WORK MAKE FOR HIRE" ដែលត្រូវបានទទួលស្គាល់ដោយច្បាប់សិទ្ធិអ្នកនិពន្ធ។ ទោះបីជាយ៉ាងណា បទបញ្ញត្តិនេះពុំមានចរឹកលក្ខណៈដាច់ខាត់ឡើយ។ និយោជិតអាចជាម្ចាស់កម្មសិទ្ធិនៃសិទ្ធិសេដ្ឋកិច្ចនៃស្នាដៃ ប្រសិនបើកិច្ចសន្យានោះបានចែងអំពីការផ្ទេរសិទ្ធិអ្នកនិពន្ធទៅឲ្យនយោជិត។ ក្នុងករណីដែលបុគ្គលម្នាក់បានជួលតតីយជនឲ្យបង្កើតស្នាដៃតាមរយៈកិច្ចសន្យានោះសិទ្ធិបេតិកភណ្ឌ ឬសិទ្ធិសេដ្ឋកិច្ចត្រូវតែជាកម្មសិទ្ធិរបស់អ្នកជួល មានន័យថាតតីយជនគ្មានសិទ្ធិទាមទារក្នុងការធ្វើជាម្ចាស់សិទ្ធិ លើស្នាដៃដែលខ្លួនបានបង្កើតនោះបានទេ។

**៦ចំពោះក្របខណ្ឌមន្ត្រីរាជការស៊ីវិល**

ផ្ទុយពីកិច្ចសន្យាការងារទូទៅ ក្របខណ្ឌមន្ត្រីរាជការស៊ីវិល គឺជាលក្ខន្តិកៈរដ្ឋបាលរួមមួយដែលបង្កើតឡើងក្នុងទម្រង់ជាឋានានុក្រមរដ្ឋបាលរវាងមន្ត្រីថ្នាក់លើ និងថ្នាក់ក្រោម។ នៅក្នុងរូបភាពស្រដៀងគ្នានឹងចំណងនៃកិច្ចសន្យាការងារឯកជន ក្របខណ្ឌមន្ត្រីរាជការស៊ីវិលបានចងភ្ជាប់មន្ត្រីរាជការម្នាក់ៗ ទៅនឹងស្ថាប័នរដ្ឋដែលខ្លួនបំពេញការងារឲ្យ(ពុំមែនទៅនឹងបុគ្គលជាមន្ត្រីថ្នាក់លើនោះឡើយ)។ ដូចគ្នានេះដែរមន្ត្រីរាជការស៊ីវិល ដែលស្ថិតក្នុងការបំពេញការងារក្រោមការដឹកនាំរបស់ប្រធានស្ថាប័ន ផ្តល់ផលប្រយោជន៍ឲ្យស្ថាប័ន ហើយទទួលបានប្រាក់បៀវត្សពីស្ថាប័ននោះគឺមានភាពដូចគ្នាទៅនឹងកិច្ចសន្យាការងារឯកជន ប៉ុន្តែកិច្ចសន្យាការងារមន្ត្រីរាជការស៊ីវិលមិនមែនគ្រប់គ្រងដោយកិច្ចសន្យាការងារឯកជននោះទេ គឺវាបង្កើតដោយសហវិធានរួមហៅថា ច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល ឬសហលក្ខន្តិកៈដោយឡែកទៅវិញ។ ច្បាប់សិទ្ធិអ្នកនិពន្ធពុំបានបញ្ញត្តិករណីនេះឡើយ ដូចនេះការយកវិធាននៃមាត្រា ១៦ និង មាត្រា ២២ នៃច្បាប់សិទ្ធិអ្នកនិពន្ធអាចអនុវត្តន៍បានចំពោះម្ចាស់ស្នាដៃជាមន្ត្រីរាជការស៊ីវិល។

### ១.១.៤. អនុភាពនៃកិច្ចសន្យា

ដើម្បីការពារនូវផលប្រយោជន៍ស្របច្បាប់របស់ម្ចាស់កម្មសិទ្ធិលើស្នាដៃមួយ កិច្ចសន្យាផ្ទេរសិទ្ធិធ្វើអាជីវកម្មត្រូវបញ្ជាក់អំពីចំនុចសំខាន់ៗមួយចំនួន ដែលច្បាប់សិទ្ធិអ្នកនិពន្ធតម្រូវឲ្យមានការកំណត់នូវលក្ខខណ្ឌអប្បបរមាក្នុងកិច្ចសន្យាដែលរួមមាន ការបញ្ជាក់អំពីកម្រិត ទំហំ គោលដៅ ទីកន្លែង និងរយៈពេលនៃការផ្ទេរសិទ្ធិនីមួយៗឲ្យបានច្បាស់លាស់[7]។ កិច្ចសន្យាដែលមានកម្មវត្ថុមិនច្បាស់លាស់ជាកម្មវត្ថុនៃមោឃភាពនៃកិច្ចសន្យា។ ការផ្ទេរសិទ្ធិអាជីវកម្មលើស្នាដៃរបស់អ្នកនិពន្ធមិនរាប់បញ្ចូលនូវសិទ្ធិសីលធម៌ឡើយ។

[7] មាត្រា ៣៥ នៃច្បាប់សិទ្ធិអ្នកនិពន្ធ។

### ១.១.៥. ប្រភេទនៃស្នាដៃ

ដើម្បីឲ្យមានភាពងាយស្រួលដល់អ្នកសិក្សា គេបានបែងចែកប្រភេទស្នាដៃដូចខាងក្រោម៖

**ស្នាដៃអក្សរសាស្ត្រៈ ប្រលោមលោក ស្នាដៃសាកល្បង ឈុតរឿង កំណាព្យ។ល។**

**ស្នាដៃតូរ្យតន្ត្រីៈ អក្សរភ្លេង ទំនុកច្រៀង។ល។**

**ស្នាដៃរបាំនិងកាយវិការៈ របាំនាដសាស្ត្រ ដូចជារបាំបុរាណ ឬរបាំសម័យទំនើប និងកាយវិការ។ល។**

**ស្នាដៃសូនរូបៈ រូបគំនូរ ការបោះពុម្ព រូបចម្លាក់ គំនូរគ្លុក អក្សរសិល្បៈ ឆាកសម្តែងសិល្បៈ សិប្បកម្ម។ល។**

**ស្នាដៃស្ថាបត្យកម្មៈ គំនូរស្ថាបត្យកម្ម និងអគារ។ល។**

**ផែនទី និងដ្យាក្រាមៈ ផែនទី ប្លង់លម្អិត (Blueprints) ដ្យាក្រាម គំនូររចនា រូបភាពពន្យល់ម៉ូដែល។ល។**

**ភាពយន្តៈ ខ្សែភាពយន្ត កម្មវិធីទូរទស្សន៍ វីដេអូហ្គេមផ្នែកទន់។ល។**

**រូបថតៈ រូបថត រូបថតគ្លីសេ ។ល។**

**កម្មវិធីៈ កម្មវីធីកុំព្យូទ័រ ។ល។**

## ១.២. កិច្ចការពារស្នាដៃអ្នកនិពន្ធ

ជាគោលការណ៍អ្នកនិពន្ធស្នាដៃ មានសិទ្ធិផ្តាច់មុខលើស្នាដៃ។ អ្នកនិពន្ធមានសិទ្ធិអនុញ្ញាត ឬហាមឃាត់រាល់ការប្រើប្រាស់ ការចម្លង ការផលិតឡើងវិញនូវស្នាដៃរបស់គាត់។

### ១.២.១. លក្ខខណ្ឌទម្រង់នៃការការពារ

#### ក. គោលការណ៍នៃការការពារដោយស្វ័យប្រវត្តិ

យោងតាម មាត្រា៣៨ វាក្យខណ្ឌទី១ នៃច្បាប់សិទ្ធិអ្នកនិពន្ធចែងថា៖ "រាល់ស្នាដៃទាំងអស់ត្រូវទទួលបានកិច្ចការពារពីច្បាប់នេះជាស្វ័យប្រវត្តិ"។ តាមរយៈពាក្យ "ត្រូវទទួលបានកិច្ចការពារជាស្វ័យប្រវត្តិ" អាចឲ្យយើងបកស្រាយបានពីការបង្កើតកាតព្វកិច្ច ទៅដល់អាជ្ញាធររដ្ឋមានសមត្ថកិច្ចទាំងអស់ក្នុងកិច្ចការពាររាល់ស្នាដៃដែលបានបំពេញលក្ខខណ្ឌ។ ក្នុងន័យនេះច្បាប់នឹងមិនតម្រូវឲ្យម្ចាស់ស្នាដៃត្រូវតែយកស្នាដៃដែលខ្លួនខិតខំបង្កើតបាននោះទៅបំពេញនូវ លក្ខខណ្ឌទម្រង់ណាមួយដើម្បីទទួលបានកិច្ចការពារនោះឡើយ។ ដូច្នេះរាល់ការជិសេធមិនទទួលស្គាល់ សិទ្ធិអ្នកនិពន្ធពីសំណាក់អាជ្ញាធរមិនត្រូវបានចាត់ទុកជាអំពើស្របច្បាប់ឡើយ។

#### ខ. ការចុះបញ្ជី និងការតម្កល់ស្នាដៃអ្នកនិពន្ធ

##### ខ.១. ការចុះបញ្ជីស្នាដៃ[8]

យោងតាមច្បាប់សិទ្ធិអ្នកនិពន្ធ ការចុះបញ្ជីអាចធ្វើទៅបានដោយស្ម័គ្រចិត្តនៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ[9]។ រាល់ការចុះបញ្ជីត្រូវតែចុះឈ្មោះពិតប្រាកដរបស់អ្នកនិពន្ធ ចុះថ្ងៃ...ខែ...ឆ្នាំ...នៃស្នាដៃបានផ្សព្វផ្សាយជាលើដំបូង និងចុះថ្ងៃ...ខែ...ឆ្នាំ...នៃការបង្កើតស្នាដៃ ព្រមទាំងចុះពីសិទ្ធិរបស់អ្នកនិពន្ធ។ តាមគោលការណ៍ស្ម័គ្រចិត្ត អ្នកនិពន្ធគ្រប់រូបអាចយកស្នាដៃដែលខ្លួនបានបង្កើតទៅធ្វើការចុះបញ្ជីនៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដែលជាស្ថាប័នមានសមត្ថកិច្ចលើវិស័យនេះ។ ប្រយោគ "អាចធ្វើដោយស្ម័គ្រចិត្ត" នៅក្នុងមាត្រាខាងលើអាចឲ្យយើងអះអាងថា ការសម្រេចពុំយកស្នាដៃរបស់ខ្លួនទៅចុះបញ្ជីមិនមានន័យថា ស្នាដៃនោះមិនត្រូវបានទទួលកិច្ចការពារនោះទេ។

ការចុះបញ្ជីស្នាដៃអ្នកនិពន្ធនៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក៏ទាមទារឲ្យមានការបង់កម្រៃផងដែរ។ បន្ថែមពីនេះក្រសួងវប្បធម៌ និងវិចិត្រសិល្បៈត្រូវចេញវិញ្ញាបនបត្រចំពោះ ស្នាដៃដែលបានចុះបញ្ជី។ អ្នកស្នើសុំចុះបញ្ជីត្រូវបង់កម្រៃទៅតាមប្រកាសរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[10]។

---

[8] មាត្រា ៣៩ នៃច្បាប់សិទ្ធិអ្នកនិពន្ធ ឆ្នាំ២០០៣

[9] មាត្រា ៣៩ នៃច្បាប់សិទ្ធិអ្នកនិពន្ធ ឆ្នាំ២០០៣

[10] មាត្រា ៤០ នៃច្បាប់សិទ្ធិអ្នកនិពន្ធ ឆ្នាំ២០០៣ និងក្នុងឧបសម្ព័ន្ធ(តារាងបង់កម្រៃសម្រាប់ការចុះបញ្ជីស្នាដៃ)

### ខ.២. នីតិវិធីនៃការផ្តល់សេវាកម្ម

*ទម្រង់នៃការចុះបញ្ជីស្នាដៃលើ៖ សៀវភៅ អត្ថបទ គំនូរ រូបថត ផែនទី*



### ខ.៣. ការតម្កល់ស្នាដៃ

ដូចក្នុងករណីចុះបញ្ជីដែរ វាក្យខណ្ឌទី២ នៃមាត្រា៣៨ ចែងថា "អ្នកនិពន្ធ ឬម្ចាស់សិទ្ធិអាចតម្កល់ទុកស្នាដៃ នៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ"។ ពាក្យ "អាច" ក្នុងន័យនេះសំដៅលើការផ្តល់ជម្រើសដល់អ្នកនិពន្ធក្នុងការសម្រេចតម្កល់ ឬមិនតម្កល់ស្នាដៃរបស់ខ្លួន ដែលការសម្រេចនេះសោត ពិតជាពុំអាចនាំអោយប៉ះពាល់ដល់កិច្ចការពារស្នាដៃនោះឡើយ។ ប៉ុន្តែ ខុសអំពីករណីនៃការចុះបញ្ជីស្នាដៃ ការតម្កល់ស្នាដៃទុកនេះ ពុំត្រូវបានច្បាប់នេះបញ្ជាក់អោយច្បាស់ថា តើអ្នកនិពន្ធ ឬម្ចាស់សិទ្ធិ ត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះ? ឬគ្រាន់តែយកស្នាដៃខ្លួនទៅទុកជាការស្រេច? តើត្រូវបង់កម្រៃណាមួយឬទេ? ។ល។[11]

### គ. ភស្តុតាងបញ្ជាក់ពីអត្ថិភាពនៃសិទ្ធិអ្នកនិពន្ធ

ស្នាដៃដែលបានដាក់ពាក្យស្នើសុំចុះបញ្ជី មន្ត្រីកាន់កាប់បញ្ជីនឹងចេញវិញ្ញាបនបត្របញ្ជាក់អំពីការចុះបញ្ជីស្នាដៃ[12]។ វិញ្ញាបនបត្រនេះជាភស្តុតាងដ៏រឹងមាំ ដែលអាចបញ្ជាក់ពីអត្ថិភាពនៃសិទ្ធិលើស្នាដៃ។ ក្រៅពីវិញ្ញាបនបត្របញ្ជាក់ពីការចុះបញ្ជីសិទ្ធិអ្នកនិពន្ធ ម្ចាស់ស្នាដៃអាចបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិលើស្នាដៃរបស់ខ្លួនតាមរយៈមធ្យោបាយផ្សេងទៀតមានជាអាទិ៍៖

- ឯកសារបញ្ជាក់ពីការបោះពុម្ពផ្សាយលើកដំបូងនៅកម្ពុជា៖ ប័នសារជាតិ បណ្ណាល័យជាតិ ឬបណ្ណាល័យរបស់គ្រឹះស្ថានសិក្សារដ្ឋនានា។

[11] ចំពោះបែបបទនៃការតម្កល់ស្នាដៃគឺត្រូវធ្វើឡើងតាមស្ថានភាពជាក់ស្តែងដែលក្រសួងវប្បធម៌ និងវិចិត្រសិល្បៈតម្រូវ។
[12] សូមមើលក្នុងឧបសម្ព័ន្ធ២។

- ឯកសារបញ្ជាក់ពីការតម្កល់ស្នាដៃនៅស្ថាប័នរដ្ឋ ឬឯកជននៅកម្ពុជាៈ បណ្ណាល័យនៃគ្រឹះស្ថានអប់រំឯកជន(បណ្ណាគារ)។ល។
- ឬកិច្ចសន្យាស្តីអំពីការបោះពុម្ពស្នាដៃ ការផ្តល់សិទ្ធិចែកចាយស្នាដៃក្នុងដែនដីកម្ពុជាៈ កិច្ចសន្យាអាជ្ញាប័ណ្ណ កិច្ចសន្យាបោះពុម្ពជាមួយរោងពុម្ព កិច្ចសន្យាការងារចំពោះស្នាដៃសមូហភាព។ល។

ហេតុដូច្នេះនៅពេលមានវិវាទ អ្នកនិពន្ធអាចប្រើប្រាស់មធ្យោបាយបង្ហាញភស្តុតាងសមស្របណាមួយដែលអាចធ្វើបាន។

### ១.២.២. លក្ខខណ្ឌគ្រឹះនៃការការពារ

ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធបានបង្កើតលក្ខខណ្ឌគ្រឹះមួយចំនួន ដើម្បីអោយស្នាដៃដែលត្រូវបានបង្កើតរួចរាល់ហើយអាចទទួលបាននូវកិច្ចការពារពីច្បាប់ ឬអាចនិយាយម្យ៉ាងទៀតថា បង្កើតសិទ្ធិដល់អ្នកដែលខិតខំប្រឹងប្រែងបង្កើតស្នាដៃនោះ។ ក្នុងចំណោមលក្ខខណ្ឌតម្រូវទាំងនោះ លក្ខខណ្ឌដែលសំខាន់ជាងគេ និងត្រូវតែបំពេញដាច់ខាតចំពោះស្នាដៃទាំងឡាយគឺ លក្ខខណ្ឌដែលទាក់ទងនឹងភាពដើមរបស់ស្នាដៃ។ ម្យ៉ាងវិញទៀតលក្ខខណ្ឌសញ្ជាតិរបស់អ្នកនិពន្ធស្នាដៃ ក៏ដូចជាលក្ខខណ្ឌដែនដីដែលស្នាដៃបានបោះពុម្ពផ្សព្វផ្សាយ គឺតម្រូវឲ្យមានដោយចៀសមិន។ លើសពីនេះទៀតបើទោះបីជាលក្ខខណ្ឌគ្រឹះត្រូវបានបំពេញត្រឹមត្រូវដោយស្នាដៃនិពន្ធក៏ដោយ ក៏ច្បាប់ស្តីពីសិទ្ធអ្នកនិពន្ធនៅតែបង្កើតនូវបញ្ជីអញ្ញត្រកម្ម គឺបានរាយឈ្មោះស្នាដៃអ្នកនិពន្ធដែលមិនទទួលបានកិច្ចការពារពីច្បាប់នេះដែរ។

#### ក. សញ្ញាណនៃភាពដើម

ត្រូវចាត់ទុកជាស្នាដៃដើម គឺជាស្នាដៃទាំងឡាយដែលបង្កើតឡើង ដោយគំនិតប្រាជ្ញាផ្ទាល់របស់អ្នកនិពន្ធស្នាដៃនោះ[13]។ ដើម្បីទទួលស្គាល់សញ្ញាណនៃភាពដើមនេះ មាត្រា៥ និងមាត្រា៨នៃច្បាប់សិទ្ធិអ្នកនិពន្ធ បានបញ្ជាក់អំពីការការពារយ៉ាងដាច់ខាតដល់ស្នាដៃដើមមួយ ប្រឆាំងទល់នឹងការបង្កើតស្នាដៃបន្តទោះបីជាស្នាដៃដើមនោះពុំទាន់ត្រូវបាននិពន្ធ(បង្កើត)ឲ្យចប់សព្វគ្រប់ក្តី ឬមួយក៏ពុំទាន់ត្រូវបានផ្សព្វផ្សាយជាសាធារណៈក្តី[14]។

#### ខ. កម្រិតនៃភាពដើម

ភាពដើមអាចនឹងប្រែប្រួល ទៅតាមលក្ខណៈនៃការប្រើប្រាស់គំនិតប្រាជ្ញារបស់អ្នកនិពន្ធទៅបង្កើតស្នាដៃមួយ។ យើងនឹងវិភាគពីភាពដើមដាច់ខាត និងភាពដើមមិនដាច់ខាតនៃស្នាដៃអ្នកនិព្ធ។

[13] មាត្រា ៨ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ ឆ្នាំ២០០៣

[14] មាត្រា ៥ នៃច្បាប់សិទ្ធិអ្នកនិពន្ធ ឆ្នាំ២០០៣

ភាពដើមដាច់ខាត សំដៅដល់ការប្រើប្រាស់គំនិតប្រាជ្ញាផ្ទាល់របស់អ្នកនិពន្ធទៅបង្កើត (បញ្ញត្តិក្នុងមាត្រា៨)។ ក្នុងករណីនេះ ច្បាប់កំណត់ឈ្មោះស្នាដៃដែលជាផលិតផលនៃភាពដើមដាច់ខាតនេះថា "ស្នាដៃដើម"។ ទន្ទឹមនេះ ច្បាប់ក៏បានទទួលស្គាល់នូវសញ្ញាណនៃភាពដើមមិនដាច់ខាត ពោលគឺការខ្ចីទម្រង់នៃភាពដើមពីគេដូចជា ការបកប្រែ ការយកលំនាំដើម ការកែសម្រួល ការកែច្នៃ ឬការកែលម្អស្នាដៃមួយទៅបង្កើតស្នាដៃថ្មីមួយទៀត ដែលនៅក្នុងករណីនេះច្បាប់អោយឈ្មោះថា "ស្នាដៃបន្ត"[15]។ ថ្វីត្បិតតែស្នាដៃបន្តនេះ គឺបានខ្ចីនូវលក្ខណៈណាមួយពីស្នាដៃដើមដែលនឹងអាចនាំឲ្យភាពដើមផ្ទាល់របស់វាក្លាយជា "ពុំសុទ្ធ" ឬ"លាយ" ប៉ុន្តែស្នាដៃបន្តនេះនៅតែទទួលបានការការពារពីច្បាប់ដដែល កាលបើមានភាពដើមផ្ទាល់របស់ខ្លួនវា ពោលគឺជាគំនិតប្រាជ្ញាផ្ទាល់របស់អ្នកនិពន្ធស្នាដៃបន្តដូចដែលមាត្រា៨ បានចែង។ ក្នុងន័យនេះដែរស្នាដៃចម្លងពីស្នាដៃបន្តមួយ នឹងពុំមានភាពដើមផ្ទាល់នោះឡើយហើយនឹងពុំត្រូវទទួលបានការការពារស្របច្បាប់ដែរ។

ដោយសារតែស្នាដៃបន្តនេះ បានខ្ចីភាពដើមរបស់ស្នាដៃផ្សេងទៀតមកប្រើប្រាស់ដូចនេះ ស្នាដៃបន្តនឹងអាចចាត់ទុកថាស្របច្បាប់ ហើយអាចទទួលបានការការពារពីច្បាប់បានដរាបណាវាត្រូវទទួលបានការយល់ព្រមឲ្យខ្ចីពីម្ចាស់ស្នាដៃដើម។ ការលួចខ្ចីដោយពុំមានការយល់ព្រមពីម្ចាស់ស្នាដៃដើម គឺឲ្យឈ្មោះថាជាការរំលោភបំពានលើសិទ្ធិអ្នកនិពន្ធ ដែលនាំឲ្យភាពដើមផ្ទាល់របស់ស្នាដៃបន្តនោះ បាត់បង់ការទទួលស្គាល់ពីច្បាប់ហើយចាត់ទុកថាជាការលួចចម្លងស្នាដៃទៅវិញ។ ម្យ៉ាងវិញទៀត ការលួចចម្លងស្នាដៃដើមបើទោះបីជ្រកក្រោមទម្រង់ជាស្នាដៃបន្តក៏ដោយ វានៅតែពុំមានភាពដើមផ្ទាល់ ហើយមិនត្រូវទទួលបានការការពារស្របច្បាប់ឡើយ។

### គ. លក្ខខណ្ឌនិត្យានុកូល

❖ **គោលការណ៍ការពារតែស្នាដៃដែលបង្កើតដោយជនមានសញ្ជាតិខ្មែរ**

ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធរបស់កម្ពុជា បានប្រកាសការពារឲ្យតែចំពោះស្នាដៃអ្នកនិពន្ធដែលមានសញ្ជាតិខ្មែរប៉ុណ្ណោះ(អ្នកនិពន្ធជាខ្មែរ) ទោះបីជាស្នាដៃនោះត្រូវបានបង្កើតឡើងនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាក៏ដោយចុះ។ មាត្រា៣ ចំណុច "១-ក" នៃច្បាប់នេះបានចែងទាក់ទងនឹងស្នាដៃអ្នកនិពន្ធថាៈ "ស្នាដៃទាំងឡាយ ដែលទទួលបានការការពារពីច្បាប់នេះមានស្នាដៃអ្នកនិពន្ធដែលបង្កើតឡើងដោយជនមានសញ្ជាតិខ្មែរ ប៉ុន្តែគោលការណ៍នេះពុំដាច់ខាតនោះឡើយ។

❖ **អញ្ញត្រកម្មការពារស្នាដៃរបស់ជនបរទេសដែលមានលំនៅនៅកម្ពុជា**

គោលការណ៍នៃការការពារខាងលើបានទទួលរងនូវអញ្ញត្រកម្មចំនួនពីរគឺៈ កាលបើកម្ពុជាបានជាប់កាតព្វកិច្ចការពារឲ្យស្នាដៃជនបរទេស ក្នុងក្របខណ្ឌនៃកិច្ចព្រមព្រៀងអន្តរជាតិណាមួយ

[15] មាត្រា ៨ នៃច្បាប់សិទ្ធិអ្នកនិពន្ធ ឆ្នាំ២០០៣

នឹងកាលបើកម្ពុជាខ្លួនឯង បានប្រកាសនៅក្នុងច្បាប់ជាតិរបស់ខ្លួនអំពីកាតព្វកិច្ចការពារដល់ស្នាដៃនោះ។ នៅក្នុងន័យនេះ មាត្រា៣ ចំណុច "១" ទាំងមូលបានប្រកាសថានឹងការពារដល់ស្នាដៃដែលបង្កើតដោយជនបរទេសកាលបើះ

- ស្នាដៃនោះត្រូវបានបង្កើតដោយជនបរទេសដែលមានលំនៅ(អចិន្ត្រៃយ៍)នៅកម្ពុជា
- ស្នាដៃនោះត្រូវបានបោះពុម្ពផ្សាយលើកដំបូងនៅកម្ពុជា ឬត្រូវបានបោះពុម្ពផ្សាយលើដំបូងនៅបរទេស ប៉ុន្តែត្រូវបានយកមកបោះពុម្ពផ្សាយនៅកម្ពុជាក្នុងកំឡុងពេល៣០ថ្ងៃ(ចាប់រាប់ពីកាលបរិច្ឆេទនៃការបោះពុម្ពផ្សាយលើកដំបូង) ចំណុច"ខ"។
- ស្នាដៃនោះជាស្នាដៃសោតទស្សន៍ ដែលផលិតករមានទីស្នាក់ការ ឬមានទីលំនៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ស្នាដៃជាស្នាដៃស្ថាបត្យកម្មដែលបានសាងសង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងស្នាដៃសិល្បៈផ្សេងៗដែលភ្ជាប់ទៅនឹងអាគារ ឬរចនាសម្ព័ន្ធនៅព្រះរាជាណាចក្រកម្ពុជា។
- ស្នាដៃនោះជាស្នាដៃ ដែលព្រះរាជាណាចក្រកម្ពុជាមានកាតព្វកិច្ចការពារក្រោមសន្ធិសញ្ញាអន្តរជាតិ។

ពោលគឺជាកិច្ចព្រមព្រៀង ដែលកម្ពុជាយើងជាប្រទេសដែលបានចុះហត្ថលេខី។ លើសពីនេះទៀត មាត្រា៧៦ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ បានកំណត់យកវិធានអន្តរជាតិ(ដូចជាកិច្ចព្រមព្រៀង ឬសន្ធិសញ្ញាអន្តរជាតិ)ជាវិធានគោលកាលបើច្បាប់ជាតិរបស់កម្ពុជាយើងមានជម្លោះគ្នានឹងវិធានអន្តរជាតិដែលកម្ពុជាជាហត្ថលេខីទាំងនោះ។

# ជំពូកទី២
# ការអនុវត្តលើសិទ្ធិអ្នកនិពន្ធ

# ជំពូកទី ២
# ការអនុវត្តលើសិទ្ធិអ្នកនិពន្ធ

## ២.១. ប្រភេទនៃសិទ្ធិដែលទទួលបានពីស្នាដៃ

អ្នកនិពន្ធទទួលបានសិទ្ធិផ្តាច់មុខលើស្នាដៃ សិទ្ធិនេះត្រូវបានទទួលស្គាល់ដោយច្បាប់ជាតិ។ សិទ្ធិអ្នកនិពន្ធមានពីរប្រភេទ គឺសិទ្ធិសីលធម៌ និងសិទ្ធិបេតិកភណ្ឌ។

### ២.១.១. សិទ្ធិសីលធម៌

#### ក. សញ្ញាណទូទៅនៃសិទ្ធិសីលធម៌

"**សិទ្ធិសីលធម៌**" គឺជាសិទ្ធិដែលនៅជាប់ជាមួយអ្នកនិពន្ធជានិរន្តរ៍ លើខ្លឹមសារទម្រង់ទាំងមូលនៃស្នាដៃ ឈ្មោះរបស់អ្នកនិពន្ធ។ល។ សិទ្ធិនេះជាសិទ្ធិផ្ទាល់ខ្លួនរបស់អ្នកនិពន្ធដែលមិនអាចដកចេញឡើយ[16]។ សិទ្ធិសីលធម៌របស់អ្នកនិពន្ធមានដូចខាងក្រោម៖

- អ្នកនិពន្ធមានសិទ្ធិផ្តាច់មុខក្នុងការសម្រេចពីរបៀប និងពេលវេលានៃការផ្សព្វផ្សាយស្នាដៃរបស់ខ្លួនជាសាធារណៈ ព្រមទាំងបែបបទគ្រប់គ្រងការផ្សព្វផ្សាយ
- អ្នកនិពន្ធមានសិទ្ធិកំណត់ឲ្យគេទទួលស្គាល់ ឈ្មោះ ឋានៈ និងស្នាដៃរបស់ខ្លួនសម្រាប់ទាក់ទងជាមួយសាធារណជន។
- អ្នកនិពន្ធមានសិទ្ធិជំទាស់នូវគ្រប់រូបភាពនៃការបំភ្លើស ឬការកាត់ចោលខ្លឹមសារ ឬការកែប្រែខ្លឹមសារ ជាហេតុធ្វើឲ្យខូចកិត្តិយស ឬកេរ្តិ៍ឈ្មោះរបស់ខ្លួន។

រាល់អំពើនៃការកែប្រែខ្លឹមសារនៃស្នាដៃ ការដក ឬការដាក់បន្ថែមនូវខ្លឹមសារ ឬធាតុណាមួយនៃស្នាដៃ ការលុបឈ្មោះអ្នកនិពន្ធចេញពីស្នាដៃ (ដោយពុំមានការអនុញ្ញាតពីអ្នកនិពន្ធ) ត្រូវចាត់ទុកជាអំពើរំលោភសិទ្ធិសីលធម៌របស់អ្នកនិពន្ធ។ ប៉ុន្តែ ប្រសិនបើការដកស្រង់ខ្លឹមសារ ការប្រើប្រាស់ឈ្មោះអ្នកនិពន្ធដោយស្របច្បាប់នឹងមិនអាចចាត់ទុកជា អំពើរំលោភសិទ្ធិសីលធម៌របស់អ្នកនិពន្ធឡើយ។ ការដកស្រង់ស្របច្បាប់នៃស្នាដៃ ពុំតម្រូវឲ្យមានការអនុញ្ញាតពីម្ចាស់សិទ្ធិទេ។ ត្រូវចាត់ទុកថាការដកស្រង់ស្របច្បាប់ដោយពុំចាំបាច់សុំ ការអនុញ្ញាតជាមុនពីម្ចាស់សិទ្ធិរាល់ការដកស្រង់ណាដែលមានបញ្ជាក់ពីនិទ្ទេសមានដូចជា[17]៖ ប្រភព និងឈ្មោះអ្នកនិពន្ធច្បាស់លាស់។ ជាគោលការណ៍ការស្រង់អាគតដ្ឋានដើម្បីបញ្ជាក់ពីការដកស្រង់ស្របច្បាប់ចេញពីស្នាដៃមួយ ដើម្បីដាក់បញ្ចូលទៅក្នុងស្នាដៃមួយទៀតមានដូចតទៅ៖ (១)ឈ្មោះអ្នកនិពន្ធ (២)ចំណងជើងស្នាដៃ (៣)រោងពុម្ពបោះ

[16] មាត្រា ១៩ នៃច្បាប់សិទ្ធិអ្នកនិពន្ធ។
[17] មាត្រា ២៨ នៃច្បាប់សិទ្ធិអ្នកនិពន្ធ។

ផ្សាយ (៤)ឆ្នាំបោះពុម្ពផ្សាយ (៥)លេខបោះពុម្ពផ្សាយប្រសិនបើមាន (៦)លេខទំព័រ ឬលេខកថាខណ្ឌ ឬលេខផ្នែកដែលត្រូវបានដកស្រង់ចេញពីស្នាដៃដើម។

### ខ. ចរិតលក្ខណៈនៃសិទ្ធិសីលធម៌

សិទ្ធិសីលធម៌របស់អ្នកនិពន្ធ គឺជាសិទ្ធិអចិន្ត្រៃយ៍ មិនអាចលក់ដូរបាន និងមិនអាចរឹបអូសបាន និងមិនអាចផុតអាជ្ញាយុកាលឡើយ[18]។ ប៉ុន្តែនៅពេលអ្នកនិពន្ធទទួលមរណៈភាព សិទ្ធិនេះអាចផ្ទេរឲ្យទៅទាយាទរបស់អ្នកនិពន្ធ ឬផ្ទេរឲ្យទៅតតីយជនបានតាមរយៈមតកសាសន៍។ ក្នុងករណីនេះ របបគតិយុត្តិទាំងឡាយនៃមតកសាសន៍ត្រូវយកមកអនុវត្ត[19]។

### គ. រយៈពេលនៃការការពារសិទ្ធិសីលធម៌របស់អ្នកនិពន្ធ

ដោយផ្អែកលើនិយមន័យនៃសិទ្ធិសីលធម៌របស់អ្នកនិពន្ធ សិទ្ធិនេះត្រូវទទួលបានការការពារជានិរន្តរ៍ មិនអាចដូរ មិនអាចរឹបអូសបាន និងមិនអាចផុតអាជ្ញាយុកាលឡើយ។

មានបញ្ហាចោទឡើងថា ក្នុងករណីសិទ្ធិបេតិកភណ្ឌអស់សុពលភាពការពារស្នាដៃអ្នកនិពន្ធនឹងក្លាយជាទ្រព្យសម្បត្តិសាធារណៈ ដែលមានន័យថាជនណាក៏អាចផលិតឡើវិញ និងបោះពុម្ពឡើងវិញដើម្បីធ្វើអាជីវកម្មដោយពុំចាំបាច់មានការអនុញ្ញាតពីអ្នកនិពន្ធ ឬជនពាក់ព័ន្ធបានទេ។ តើក្នុងករណីនេះ សិទ្ធិសីលធម៌អាចត្រូវបាត់បង់ដែរឬទេ?

ចម្លើយគឺ អ្នកផលិត និងអ្នកបោះពុម្ពស្នាដៃឡើងវិញ អាចប្រើប្រាស់ស្នាដៃរបស់អ្នកនិពន្ធក្នុងទម្រង់ដើមពោលគឺ មិនត្រូវកែប្រែ លុបចោល ដកចេញ ដាក់បន្ថែមឈ្មោះ ឬអត្ថន័យផ្សេងណាមួយនៃស្នាដៃឡើយ។ ដូច្នេះ សិទ្ធិសីលធម៌របស់អ្នកនិពន្ធ មិនអាចបាត់បង់តាមរយៈការផុតអាជ្ញាយុកាលនៃសិទ្ធិបេតិកភណ្ឌឡើយ។

### ឃ. លក្ខណៈពិសេសនៃសិទ្ធិសីលធម៌របស់អ្នកនិពន្ធ

សិទ្ធិសីលធម៌របស់អ្នកនិពន្ធមានលក្ខណៈពិសេសបួនយ៉ាងគឺ៖

**☞ អចិន្ត្រៃយ៍**

សិទ្ធិសីលធម៌ ជាសិទ្ធិអចិន្ត្រៃយ៍មានន័យថា សិទ្ធិនេះនៅជាប់អ្នកនិពន្ធជានិច្ចទោះបីជាអ្នកនិពន្ធបានផ្ទេរសិទ្ធិបេតិកភណ្ឌរបស់ខ្លួនទៅឲ្យតតិជនក៏ដោយ។ ជាក់ស្តែងនៅក្នុង មាត្រា១៦ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣ ក៏បានកំណត់ពីបញ្ហានេះដែរ។

[18] មាត្រា ១៩ នៃច្បាប់សិទ្ធិអ្នកនិពន្ធ។

[19] ចំពោះស្នាដៃទាំងឡាយណា ដែលត្រូវបានបង្កើតឡើងដោយការអនុវត្តក្រមរដ្ឋប្បវេណីថ្ងៃទី ២១ ធ្នូ ២០១១ ត្រូវអនុវត្តបញ្ញត្តិទាំងឡាយនៃក្រមនេះស្តីពីមតកសាសន៍(សូមមើលគន្លឹ៨នៃក្រមរដ្ឋប្បវេណី២០០៧ស្តីពីសន្តតិកម្ម)។

☛ **មិនអាចលក់ដូរបាន**

អ្នកនិពន្ធពុំអាចលះបង់ ឬលក់ដូរសិទ្ធិសីលធម៌នេះបានទេ ទោះបីជាអ្នកនិពន្ធចុះកិច្ចសន្យាផ្ទេរក្តី ក៏សិទ្ធិនេះពុំបានបាត់បង់ពីអ្នកនិព្វន្ធឡើយ។ ពាក្យមិនអាចលក់ដូរបាន សំដៅលើសិទ្ធិសីលធម៌ពេលដែលអ្នកនិពន្ធនៅមានជីវិតនៅឡើយ។ ផ្ទុយទៅវិញ សិទ្ធិសីលធម៌អាចត្រូវបានផ្ទេរដោយមូលហេតុអ្នកនិពន្ធទទួលមរណភាព។ ហេតុនេះហើយ សិទ្ធិសីលធម៌នេះអាចត្រូវបានផ្ទេរទៅឲ្យទាយាទ ឬអច្ច័យលាភី តាមបញ្ញត្តិមរតកសាសនិបាន[20]។

ផ្ទុយទៅវិញ បើមរតកជនទទួលមរណភាពដោយពុំបន្សល់ទុកនូវ មរតកសាសន៍ទេគេត្រូវអនុវត្តប្រធាននៃសន្តិកម្មដែលមានចែងក្នុងមាត្រា១១៥៦ និងមាត្រាបន្តបន្ទាប់នៃក្រមរដ្ឋប្បវេណី។ ការផ្ទេរមរតកដែលក្នុងនោះមានសិទ្ធិសីលធម៌របស់អ្នកនិពន្ធ ក៏ដូចជាការផ្ទេរទ្រព្យសម្បត្តិដែរគឺត្រូវផ្ទេរទៅតាមឆន្ទៈរបស់ម្ចាស់បណ្តាំ[21]។

សន្តិកម្មតាមច្បាប់ត្រូវផ្ទេរទៅឲ្យជនមួយចំនួនតាមលំដាប់ដូចជា កូន ឬកូនចិញ្ចឹម បុព្វញាតិផ្ទាល់ បងប្អូនបង្កើត សហព័ទ្ធរបស់មតកជន និងចុងក្រោយគឺរដ្ឋដែលតំណាងដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ[22]។

ច្បាប់កំណត់អំពីការផ្ទេរសិទ្ធិនៃសិទ្ធិសីលធម៌ ឲ្យទៅទាយាទរបស់អ្នកនិពន្ធដោយពុំមានការលើក ឬការកំណត់ត្រួតពិនិត្យការអនុវត្តនេះដោយតុលាការឡើយ។ ប៉ុន្តែក្នុងច្បាប់នៃបណ្តាប្រទេសមួយចំនួន គឺគេតម្រូវឲ្យមានការត្រួតពិនិត្យតាមរយៈតុលាការមុនធ្វើការផ្ទេរសិទ្ធិ។ តុលាការធ្វើការត្រួតពិនិត្យនឹងចេញវិធានការសមស្រប ជាពិសេសនៅពេលដែលទាយាទបានប្រព្រឹត្តអំពើដែលផ្ទុយនឹងឆន្ទៈទាំងស្រុងរបស់អ្នកនិពន្ធ។

ទោះបីជាច្បាប់ពុំបានចែងច្បាស់លាស់ពីបញ្ហានេះក៏ដោយ យើងយល់ថាបន្ទាប់ពីអ្នកនិពន្ធទទួលមរណភាពទៅហើយ សិទ្ធិសីលធម៌ដែលផ្ទេរទៅឲ្យទាយាទមិនមានលក្ខណៈដូចគ្នាទាំងស្រុងទៅនឹងសិទ្ធិសីលធម៌គ្រប់គ្រងដោយអ្នកនិពន្ធនោះទេ។

☛ **មិនអាចរឹបអូសបាន**

សិទ្ធិសីលធម៌ជាសិទ្ធិពុំអាចរឹបអូសបានទេ។ ម្ចាស់បំណុលរបស់អ្នកនិពន្ធពុំមានសិទ្ធិប្តឹងទៅតុលាការដើម្បីសុំការរឹបអូសនេះបានឡើយ ដរាបណាអ្នកនិពន្ធពុំទាន់ផ្សព្វផ្សាយស្នាដៃរបស់ខ្លួនជា

[20] មាត្រា ១៩ នៃច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣។

[21] មាត្រា ១១៩៥ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[22] មាត្រា ១៩ នៃច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣។

សាធារណៈ នោះម្ចាស់បំណុលរបស់អ្នកនិពន្ធពុំអាចបង្ខំរឹបអូសស្នាដៃនោះឡើយ ព្រោះថាសិទ្ធិក្នុងការផ្សព្វផ្សាយស្នាដៃជាសាធារណៈ ជាសិទ្ធិសីលធម៌របស់អ្នកនិពន្ធ។

ម្យ៉ាងទៀតមានតែអ្នកនិពន្ធម្នាក់ប៉ុណ្ណោះមានសិទ្ធិសម្រេចថា តើគួរដល់ពេលផ្សព្វផ្សាយជាសាធារណៈរឺអត់នូវស្នាដៃរបស់ខ្លួន ចំណែកឯម្ចាស់បំណុលពុំមានសិទ្ធិរឹបអូសសិទ្ធិ ឬបង្ខំអ្នកនិពន្ធឲ្យផ្សព្វផ្សាយស្នាដៃខ្លួនជាសាធារណៈបានឡើយ។

**☞ មិនមានអាជ្ញាយុកាល**

សិទ្ធិសីលធម៌មិនមានអាជ្ញាយុកាលនោះទេ សិទ្ធិនេះផ្ទុយពីសិទ្ធិបេតិកភណ្ឌដែលមានរយៈពេលការពារដោយច្បាប់។ សិទ្ធិសីលធម៌អាចផុតរលត់ជាមួយស្នាដៃ ដរាបណាស្នាដៃនៅតែមានអត្ថិភាពនោះ សិទ្ធិសីលធម៌របស់អ្នកនិពន្ធនៅតែមានបន្ត។

### ខ. ទម្រង់នៃការអនុវត្តសិទ្ធិសីលធម៌

**↘ សិទ្ធិគ្រប់គ្រងការផ្សព្វផ្សាយស្នាដៃជាសាធារណៈ**

តាមច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលឆ្នាំ២០០៣ បានបញ្ជាក់យ៉ាងច្បាស់ថា ទោះបីជាស្នាដៃនោះមិនទាន់ចប់សព្វគ្រប់ក្តី ឬពុំទាន់បានផ្សាយជាសាធារណៈក្តី ក៏នៅតែជាស្នាដៃរបស់អ្នកនិពន្ធដែរ[23]។ ការសម្រេចចិត្តក្នុងការផ្សព្វផ្សាយស្នាដៃខ្លួនជាសាធារណៈ ជាសិទ្ធិសម្រេចរបស់អ្នកនិពន្ធដោយសារមានតែអ្នកនិពន្ធប៉ុណ្ណោះ ដែលដឹងថាស្នាដៃរបស់ខ្លួនពេញលេញ ឬមានគុណភាពគ្រប់គ្រាន់សម្រាប់ឲ្យសាធារណៈជនបានទទួលដឹង។ នេះជាបញ្ហាពាក់ព័ន្ធនឹងកិត្តិយសរបស់អ្នកនិពន្ធផ្ទាល់តែម្តង។

ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣ មាត្រា២០ ចែងថា អ្នកនិពន្ធមានសិទ្ធិផ្តាច់មុខក្នុងការសម្រេចពីមធ្យោបាយ និងពេលវេលា នៃការផ្សព្វផ្សាយស្នាដៃរបស់ខ្លួនជាសាធារណៈ ព្រមទាំងបែបបទក្នុងដំណើរការផ្សព្វផ្សាយ។

**↘ សិទ្ធិឲ្យសាធារណៈជនស្គាល់អត្តសញ្ញាណ**

មាត្រា២០ ចំណុច ខ ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលឆ្នាំ២០០៣ ចែងថា "អ្នកនិពន្ធមានសិទ្ធិបង្ហាញនូវឈ្មោះ និងឋានៈដើម្បីឲ្យគេទទួលស្គាល់ ព្រមទាំងអាចដាក់បង្ហាញនូវស្នាដៃរបស់ខ្លួនទៅឲ្យសាធារណជនបានដឹង"។ សិទ្ធិនេះក៏ត្រូវបានទទួលស្គាល់ដោយមាត្រា៦ ស្ទួននៃអនុសញ្ញាទីក្រុងប៊ែលចែងថា "ដោយមិនគិតដល់សិទ្ធិបេតិកភណ្ឌ ហើយទោះជាក្រោយពេលបានធ្វើអនុប្បទានសិទ្ធិបេតិកភណ្ឌហើយក្តី ក៏អ្នកនិពន្ធនៅតែមានសិទ្ធិក្នុងការទាមទារឲ្យដាក់ឈ្មោះឋានៈរបស់ខ្លួនបានដដែល"។

[23] មាត្រា ៥ នៃច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣។

អ្នកនិពន្ធមានសិទ្ធិ ពុំបង្ហាញអត្តសញ្ញាណរបស់ខ្លួនឲ្យគេដឹងបាន ដោយអ្នកនិពន្ធមិនដាក់ឈ្មោះលើស្នាដៃរបស់ខ្លួន ឬគ្រាន់តែដាក់រហ្សនាម ឬដាក់ឈ្មោះអនាមិកលើស្នាដៃរបស់ខ្លួន[24]។ នៅពេលអ្នកនិពន្ធពិតប្រាកដពុំបានបង្ហាញ អត្តសញ្ញាណពិតប្រាកដរបស់ខ្លួនឲ្យសាធារណជនដឹង សិទ្ធិរបស់អ្នកនិពន្ធត្រូវបានជំនួសមុខដោយអ្នកបោះពុម្ពផ្សព្វផ្សាយជាលើកដំបូង។

**៦សិទ្ធិរក្សាបូរណភាពស្នាដៃ**

អ្នកនិពន្ធមានសិទ្ធិជំទាស់នូវគ្រប់រូបភាពនៃការបំផ្លើស ឬការកាត់ចោលខ្លឹមសារ ជាហេតុធ្វើឲ្យខូចកិត្តិយស ឬកេរ្តិ៍ឈ្មោះរបស់ខ្លួន[25]។

ស្នាដៃរបស់អ្នកនិពន្ធជាស្នាដៃត្រូវគោរពហើយមិនអាចបំផ្លើស ឬបន្ថែមបន្ថយនូវខ្លឹមសារណាមួយឡើយ ព្រោះថាការបំផ្លើស ការកែប្រែខ្លឹមសារនៃស្នាដៃរបស់អ្នកនិពន្ធធ្វើឲ្យស្នាដៃដើមបាត់បង់នូវអត្ថន័យដែលអ្នកនិពន្ធចង់បង្ហាញនៅក្នុងស្នាដៃរបស់ខ្លួន។ សិទ្ធិនេះនៅតែអាចអនុវត្តជានិច្ចទោះបីជាអ្នកនិពន្ធបានផ្ទេរសិទ្ធិបេតិកភណ្ឌឲ្យទៅតតិយជនក៏ដោយ។

### ២.១.២. សិទ្ធិបេតិកភណ្ឌរបស់អ្នកនិពន្ធ

#### ក. សញ្ញាណទូទៅនៃសិទ្ធិបេតិកភណ្ឌ

សិទ្ធិបេតិកភណ្ឌ គឺជាសិទ្ធិផ្តាច់មុខរបស់អ្នកនិពន្ធក្នុងការប្រកបអាជីវកម្ម ឬទាញផលប្រយោជន៍ពីស្នាដៃតាមរយៈការផលិត ការផលិតឡើងវិញ ការបោះពុម្ពផ្សាយជាសាធារណៈ ឬការបង្កើតស្នាដៃបន្ត[26]។ សិទ្ធិបេតិកភណ្ឌអាចហៅម៉្យាងទៀតបានថាជា "សិទ្ធិសេដ្ឋកិច្ច" មានន័យថាជាសិទ្ធិដែលអាចទូទាត់ជាសាច់ប្រាក់បានតាមរយៈការអនុវត្តសិទ្ធិរបស់អ្នកនិពន្ធ។ សិទ្ធិនេះត្រូវរួមបញ្ចូលទាំងសិទ្ធិក្នុងការផ្ទេរសិទ្ធិបេតិកភណ្ឌឲ្យទៅតតីយជនដើម្បីធ្វើអាជីវកម្ម ផលិតឡើងវិញ និងចែកចាយស្នាដៃស្របច្បាប់តាមលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងកិច្ចសន្យាដោយឡែកៗ។

កិច្ចសន្យានោះអាចជា កិច្ចសន្យាអនុប្បទានសិទ្ធិ ឬកិច្ចសន្យាជាអាជ្ញាប័ណ្ណ។ កិច្ចសន្យាទាំងពីរប្រភេទនេះ ជាករណីប្រើប្រាស់ច្រើនជាងគេនៅក្នុងការធ្វើអាជីវកម្មលើស្នាដៃ។

ក្នុងករណីនេះ អ្នកនិពន្ធអាចកំណត់ឲ្យតតីយជនអនុវត្តកិច្ចដូចខាងក្រោម៖

- ការបកប្រែស្នាដៃជាភាសារបរទេស
- ការយកលំនាំតាម ឬការកែសម្រួលផ្សេងៗទៀតនៃស្នាដៃ

---

[24] មាត្រា ១៤ នៃច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣។
[25] មាត្រា ២០ ចំណុច គ នៃច្បាប់សិទ្ធិអ្នកនិពន្ធ ឆ្នាំ២០០៣។
[26] មាត្រា ១៨ នៃច្បាប់សិទ្ធិអ្នកនិពន្ធ ឆ្នាំ២០០៣។

- ការជួលស្នាដៃច្បាប់ដើម ឬច្បាប់ចម្លងនៃស្នាដៃ
- ការលក់ ការជួល ឬតាមមធ្យោបាយផ្សេងៗទៀតនូវច្បាប់ដើម ឬច្បាប់ចម្លងដែលពុំទាន់បានលក់ ឬផ្ទេរកម្មសិទ្ធិ
- ការនាំចូលស្នាដៃចម្លងចេញពីស្នាដៃរបស់អ្នកនិពន្ធ
- ការផលិតស្នាដៃឡើងវិញ
- ការសម្តែងស្នាដៃជាសាធារណៈ
- ការបង្ហាញជាស្នាដៃសាធារណៈ
- ការផ្សាយស្នាដៃតាមទូរផ្សាយ
- ការផ្សព្វផ្សាយស្នាដៃជាសាធារណៈតាមវិធីផ្សេងៗទៀ

### ខ. ចរិតលក្ខណៈនៃសិទ្ធិបេតិកភណ្ឌ

សិទ្ធិបេតិកភណ្ឌ ឬហៅម្យ៉ាងទៀតថាជាសិទ្ធិសេដ្ឋកិច្ចរបស់អ្នកនិពន្ធ គឺសំដៅដល់សិទ្ធិដែលអនុញ្ញាតឲ្យអ្នកនិពន្ធអាចធ្វើអាជីវកម្មទៅលើស្នាដៃ ដែលជាផលនៃការបង្កើតខាងបញ្ញារបស់ខ្លួនតាមរបៀបមួយផ្តាច់មុខតែឯង។ សិទ្ធិអ្នកនិពន្ធ អាចធ្វើអាជីវកម្មនេះដោយខ្លួនឯងផ្ទាល់ ឬក៏អាចអនុញ្ញាតឲ្យអ្នកដ៏ទៃធ្វើជំនួសខ្លួន(តាមរយៈយន្តការនៃកិច្ចសន្យាលក់ ឬជួលលើសិទ្ធិនេះ)។

ផ្ទុយគ្នាពីសិទ្ធិសីលធម៌ សិទ្ធិបេតិកភណ្ឌនេះក៏អាចត្រូវបានផ្ទេរពីអ្នកនិពន្ធទៅឲ្យបុគ្គលដទៃផ្សេងទៀតដែលមិនបានបង្កើតស្នាដៃតាមឆន្ទៈ របស់អ្នកនិពន្ធ។ ដូចនេះម្ចាស់សិទ្ធិលើស្នាដៃនិពន្ធអាចជាតតីយជនដែលទទួលបានសិទ្ធិបេតិកភណ្ឌពីអ្នកនិពន្ធផង និងក៏ជាអ្នកនិពន្ធដែលជាម្ចាស់នៃសិទ្ធិសីលធម៌នោះផង។ នៅក្នុងលក្ខណៈបែបនេះ ម្ចាស់សិទ្ធិបេតិកភណ្ឌដែលមិនមែនជាអ្នកនិពន្ធដែលអាចប្រើប្រាស់សិទ្ធិរបស់ខ្លួននៅត្រឹមកម្រិត នៃសិទ្ធិបេតិកភណ្ឌដែលខ្លួនទទួលបាន និងដោយឈរលើគោលការណ៍គោរពសិទ្ធិសីលធម៌របស់អ្នកនិពន្ធផ្ទាល់ទៀតផង។

### គ. រយៈពេលនៃកិច្ចការពារសិទ្ធិបេតិកភណ្ឌរបស់អ្នកនិពន្ធ

សិទ្ធិអ្នកនិពន្ធ បានបង្កើតអាជ្ញាយុកាលមួយជាគោលការណ៍ ដល់ម្ចាស់សិទ្ធិបេតិកភណ្ឌពោលគឺ តាមរយៈអាជ្ញាយុកាលនេះ ម្ចាស់សិទ្ធិបេតិកភណ្ឌ នៃស្នាដៃមួយអាចទទួលបានការការពាររយៈពេលពេញមួយជីវិតអ្នកនិពន្ធ និងបូកបន្ថែម៥០ឆ្នាំទៀត នៅក្រោយមរណភាពរបស់អ្នកនិពន្ធស្នាដៃ[27]។ អាជ្ញាយុកាលតាមគោលការណ៍នេះ អាចអនុវត្តបានតែចំពោះស្នាដៃ ដែលត្រូវបានបង្កើតឡើងដោយអ្នកនិពន្ធមួយរូបគត់ និងដែលអត្តសញ្ញាណរបស់អ្នកនិពន្ធរូបនោះ ត្រូវបានស្គាល់ទៀតផង។ ដោយឡែក ស្នាដៃសមូហភាព ឬស្នាដៃសោតទ្សន៍ ឬស្នាដៃបច្ឆាមរណ(មាត្រា៣១ កថាខណ្ឌ

[27] មាត្រា ៣០ នៃច្បាប់សិទ្ធិអ្នកនិពន្ធ ឆ្នាំ២០០៣។

ទី៤) គឺ៧៥ឆ្នាំ គិតចាប់ពីបំណាច់ប្រតិទិននៃឆ្នាំ ដែលស្នាដៃនោះបានផ្សព្វផ្សាយលើកដំបូងត្រឹមត្រូវតាមច្បាប់ និងប្រសិនបើពុំមានការបោះពុម្ពផ្សាយក្នុងកំឡុងពេល៥០ឆ្នាំនោះទេគឺ អាជ្ញាយុកាល ១០០ឆ្នាំ គិតចាប់ពីបំណាច់ប្រតិទិននៃឆ្នាំនៃស្នាដៃនោះបានបង្កើតឡើង។ ចំពោះស្នាដៃអានាមិក ឬស្នាដៃរហស្សនាម (យោងតាមមាត្រា៣១ កថាខណ្ឌទី១ និងទី២) គឺ៧៥ឆ្នាំ គិតចាប់ពីបំណាច់ប្រតិទិននៃឆ្នាំ ដែលស្នាដៃនោះបានបោះពុម្ពផ្សាយជាលើកដំបូង ដោយមានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិ និងប្រសិនបើពុំមានការបោះពុម្ពផ្សាយក្នុងកំឡុងពេល៥០ឆ្នាំទេ គឺអាជ្ញាយុកាល១០០ឆ្នាំគិតចាប់ពីបំណាច់ប្រតិទិននៃឆ្នាំដែលស្នាដៃនោះបានបង្កើត។

### ២.១.៣. អញ្ញត្រកម្មនៃសិទ្ធិបេតិកភណ្ឌ

សិទ្ធិបេតិកភណ្ឌរបស់អ្នកនិពន្ធនេះ ត្រូវបានរឹតត្បឹតដោយអញ្ញត្រកម្មមួយចំនួននៅក្នុងច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនេះ។ តាមរយៈ មាត្រា២៤ ដល់មាត្រា២៩ នៃច្បាប់នេះចែងអំពីអញ្ញត្រកម្មដែលយើងឃើញថាអ្នកនិពន្ធពុំមានសិទ្ធិហាមឃាត់ចំពោះការនាំចូល ឬផលិតឡើងវិញនូវស្នាដៃណាមួយរបស់ខ្លួនឡើយ ប្រសិនបើការនាំចូល ឬផលិតឡើងវិញនេះគឺធ្វើក្នុងគោលបំណងបម្រើនូវសេចក្តីត្រូវការផ្ទាល់ខ្លួននៃរូបវន្តបុគ្គលម្នាក់ ឬក្នុងរង្វង់គ្រួសារ ឬក្នុងគោលបំណងមិនស្វែងរកប្រាក់កម្រៃ ឬមួយក្នុងគោលបំណងសិក្សាណាមួយ លើកលែងតែជាកាផលិតឡើងវិញដែលត្រូវបានហាមឃាត់នៅក្នុងមាត្រា២៤ កថាខណ្ឌទី២ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ។

#### ក. អញ្ញត្រកម្មនៃសិទ្ធិបោះពុម្ពផ្សាយឡើងវិញ

ជាទូទៅ ការបោះពុម្ពផ្សាយឡើងវិញនូវស្នាដៃដោយពុំមានការអនុញ្ញាតពីអ្នកនិពន្ធ ត្រូវចាត់ទុកជាអំពើរំលោភសិទ្ធិអ្នកនិពន្ធ។ ដោយឡែក ការនាំចូលនូវស្នាដៃសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនអាចប្រព្រឹត្តទៅបានដោយពុំចាំបាច់មានការអនុញ្ញាតជាមុនពីអ្នកនិពន្ធឡើយ[28]។ អញ្ញត្រកម្មនេះមិនត្រូវបានយកមកអនុវត្តចំពោះការផលិតឡើងវិញនូវស្នាដៃដូចខាងក្រោម៖

- ស្នាដៃស្ថាបត្យកម្ម មានទម្រង់ជាអាគារ ឬសំណង់ផ្សេងៗ
- ការចម្លងទាំងស្រុង ឬភាគសំខាន់ខ្លះនូវសៀវភៅ តាមវិធីបោះពុម្ពជាថ្មី និងការចម្លងស្នាដៃតូរ្យតន្ត្រីក្រោមរូបភាពជាអក្សរភ្លេង
- ការចម្លងទាំងស្រុង ឬភាគខ្លះនៃប្រព័ន្ធទិន្នន័យតាមទម្រង់ឌីជីថល[29]
- កម្មវិធីកុំព្យូទ័រ លើកលែងតែច្បាប់ចម្លងកម្មវិធី រក្សាទុកដើម្បីការពារការបាត់បង់

[28] មាត្រា ២៣ នៃច្បាប់សិទ្ធិអ្នកនិពន្ធ ឆ្នាំ២០០៣។

[29] "ឌីជីថល" ជាពាក្យយកតាមភាសាអង់គ្លេស"Digital" ដែលមានន័យថា ការពិពណ៌នានូវព័ត៌មាន តន្ត្រី រូបភាព។ល។ ដែលត្រូវបានរក្សាទុក ឬផ្សព្វផ្សាយតាមប្រព័ន្ធបច្ចេកវិទ្យាកុំព្យូទ័រ។

- ស្នាដៃណាមួយក្នុងលក្ខណៈផលិតឡើងវិញ ធ្វើឲ្យប៉ះពាល់ដល់អាជីវកម្មជាប្រក្រតីនៃស្នាដៃ ឬធ្វើឲ្យខូចខាត ដោយមិនសមហេតុផលទៅលើផលប្រយោជន៍ស្របច្បាប់របស់អ្នកនិពន្ធ ឬម្ចាស់កម្មសិទ្ធិ។

គេអាចផលិតស្នាដៃមួយជាបណ្ដោះអាសន្នឡើងវិញបាន លុះត្រាតែការផលិតនោះធ្វើឡើងស្របពេលជាមួយនឹងការប្រើប្រាស់ស្នាដៃដែលបានទទួលការអនុញ្ញាតពីម្ចាស់សិទ្ធិ។

## ខ. អញ្ញត្រកម្មនៃសិទ្ធិផ្សព្វផ្សាយឡើងវិញ និងការដាក់បង្ហាញ

អ្នកនិពន្ធ មិនអាចហាមឃាត់ចំពោះសកម្មភាពប្រើប្រាស់ស្នាដៃអ្នកនិពន្ធដូចខាងក្រោម[30]៖

- ការសម្ដែងស្នាដៃជាឯកជនដោយមិនគិតថ្លៃក្នុងរង្វង់គ្រួសារ ឬញាតិមិត្ត
- ការរៀបចំទុកក្នុងបណ្ណាល័យនូវសៀវភៅសំណៅស្នាដៃណាមួយ ដើម្បីរក្សាទុកឲ្យបានគង់វង្ស ឬដើម្បីទុកសម្រាប់ធ្វើការស្រាវជ្រាវ
- ការប្រើប្រាស់នូវស្នាដៃសម្រាប់ការសិក្សាដោយមិនរកប្រាក់កម្រៃ
- ការបកប្រែស្នាដៃ ពីភាសាខ្មែរទៅជាភាសាជនជាតិភាគតិច ឬបកប្រែពីភាសាជនជាតិភាគតិចមកជាភាសាខ្មែរ។

## គ. អញ្ញត្រកម្មនៃសិទ្ធិដោយផ្អែកលើការបង្ហាញអត្តសញ្ញាណអ្នកនិពន្ធ

ប្រសិនបើមានការបញ្ជាក់យ៉ាងច្បាស់នូវឈ្មោះរបស់អ្នកនិពន្ធ និងប្រភពនៃស្នាដៃ អ្នកនិព្ធ មិនអាចហាមឃាត់តតីជនឲ្យបញ្ឈប់នូវរាល់សកម្មភាពទាំងឡាយដូចខាងក្រោម[31]៖

- ការវិភាគ និងអាគតដ្ឋានខ្លីៗនៃស្នាដៃ ដែលបញ្ជាក់ពីការរិះគន់ក្នុងសង្គ្រាមប៉ាកកាគរុកោសល្យ វិទ្យាសាស្ត្រ ឬព័ត៌មានស្ដីពីស្នាដៃនោះ
- ការផ្សាយទស្សនៈសារព័ត៌មាន
- ការផ្សាយទាំងស្រុង ឬភាគខ្លះនៃសុន្ទរកថានានាដែលបានថ្លែងជាសាធារណៈក្នុងសារព័ត៌មាន ឬទូរផ្សាយ
- ការគ្រាប់កំប្លែង ការគ្រាប់តាមគំរូ ឬគំនូរត្លុកដោយផ្អែកតាមលំនាំនៃស្នាដៃ
- ការចម្លងរូបភាពស្នាដៃ សិល្បៈក្រាហ្វិក ឬសិល្បៈសូនរូប ដែលស្ថិតនៅទីកន្លែងសាធារណៈមួយ លើកលែងតែរូបភាពត្រូវបានចាត់ទុកថាជាកម្មវត្ថុសំខាន់នៃការចម្លងបន្ត។

[30] មាត្រា ២៥ នៃច្បាប់សិទ្ធិអ្នកនិពន្ធ ឆ្នាំ២០០៣។

[31] មាត្រា ២៥ នៃច្បាប់សិទ្ធិអ្នកនិពន្ធ ឆ្នាំ២០០៣។

សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលឆ្នាំ២០០៣ ពុំបានកំណត់ពីបរិមាណ ប្រវែង ឬទំហំនៃអាគតដ្ឋានឡើយ។ ការស្រង់អាគតដ្ឋាន គឺត្រូវមានលក្ខណៈសមរម្យហើយមិនហួសពីគោលដៅដែលត្រូវបំពេញឡើយ។

ដើម្បីឲ្យកាស្រង់អាគតដ្ឋានមានលក្ខណៈត្រឹមត្រូវ ស្នាដៃដែលគេស្រង់នោះចាំបាច់ត្រូវតែបានផ្សព្វផ្សាយត្រឹមត្រូវជាមុនតួយ៉ាង តាមរយៈការថតចម្លងស្នាដៃដែលបោះពុម្ព ចែកចាយ ឬយកទៅសម្តែងតាមរោងល្ខោនជាសាធារណៈ ឬតាមទូរផ្សាយនានា។ ការផ្សេព្វផ្សាយនេះក៏អាចធ្វើតាមរយៈការផ្តល់អាជ្ញាប័ណ្ណបញ្ជារផងដែរ។

ទោះជាយ៉ាងណាក្តីនៅក្នុងការស្រង់អាគតដ្ឋាន គេត្រូវបញ្ជាក់ពីប្រភព និងឈ្មោះអ្នកនិពន្ធ ប្រសិនបើ នៅក្នុងប្រភពនោះមានឈ្មោះអ្នកនិពន្ធច្បាស់លាស់។ ចំពោះស្នាដៃដែលមិនបានផ្សព្វផ្សាយជាសាធារណៈ គឺមិនអាចស្រង់អាគតដ្ឋានបានឡើយ។ ប្រការទាំងឡាយនៃការទាក់ទងគ្នារវាងស្នាដៃថ្មី (ក) និងស្នាដៃដែលត្រូវស្រង់អាគតដ្ឋាន (ខ) មានដូចខាងក្រោមៈ

- ស្នាដៃ (ក) ជាស្នាដៃសំខាន់ ឯអាគតដ្ឋានដែលស្រង់ពីស្នាដៃ (ខ)ជាចំណុចបន្ទាប់បន្សំ។
- មានភាពខុសគ្នាច្បាស់លាស់រវាង (ក) និងចំណុចដែលដកស្រង់ចេញពី (ខ)។
- ជាការចាំបាច់ណាស់ដើម្បីការស្រង់អាគតដ្ឋានពី (ខ) សម្រាប់បង្កើតស្នាដៃ (ក)។
- អាគតដ្ឋានស្រង់ពី (ខ) ត្រូវកំណត់ចំណុចសំខាន់ៗមានចំនួនជាអប្បបរិមា។
- អាគតដ្ឋានស្រង់ពី (ខ) ត្រូវសរសេរឲ្យបានត្រឹមត្រូវដូចស្នាដៃដើម។
- ប្រភពដកស្រង់ចេញពី (ខ) ត្រូវបញ្ជាក់អោយបានច្បាស់លាស់។
- ការស្រង់អាគតដ្ឋានមិនត្រូវរំលោភបំពានលើសិទ្ធិសីលធម៌អ្នកនិពន្ធស្នាដៃ (ខ)ឡើយ។

### ២.១.៤. ការចាត់ចែងលើសិទ្ធិបេតិកភណ្ឌ

ការចាត់ចែងលើសិទ្ធិបេតិកភណ្ឌ ត្រូវបានគេធ្វើឡើងទៅតាមរូបភាពពីរយ៉ាងគឺ ការផ្ទេរសិទ្ធិ និងការធ្វើអាជីវកម្មទៅលើសិទ្ធិនេះ។

#### ក. ការផ្ទេរសិទ្ធិ

- **ការផ្ទេរសិទ្ធិដោយមូលហេតុមរណភាព**

នៅមុនឆ្នាំ២០០៣ ប្រទេសកម្ពុជាយើងមិនទាន់មានច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលទេ។ សិល្បករ អ្នកនិពន្ធ ផលិតករខ្សែភាគយន្តនៅជំនាន់នោះ គឺមានភាពល្បីល្បាញទទួលការកោតសរសើរគាំទ្រពីប្រជាពលរដ្ឋក្នុងប្រទេស និងក្រៅប្រទេស។ ក៏ប៉ុន្តែជាអកុសលប្រទេស

ដែលធ្លាប់មានសេចក្តីសុខ ប្រជាពលរដ្ឋរស់នៅប្រកបដោយភាពសុខដុមមួយនេះ បានជួបនូវវិបត្តិយ៉ាងធ្ងន់ធ្ងរជាពិសេសនៅក្នុងរបប ប៉ុល ពត។ ប្រជាជនកម្ពុជារាប់លាននាក់ត្រូវបានកាប់សម្លាប់ក្នុងនោះក៏មានសិល្បករ អ្នកនិពន្ធ ផលិតករខ្សែភាពយន្តផងដែរ។ អ្នកទាំងនោះបានស្លាប់ក៏ពិតមែនតែពួកគេក៏បានបន្សល់ទុកនៅស្នាដៃជាច្រើន ប៉ុន្តែមិនបានចាត់ចែងទុកនូវមរតកសាសន៍សម្រាប់ទាយាទរបស់ពួកគេនោះឡើយ។

សិទ្ធិបេតិកភណ្ឌអាចផ្ទេរទៅឲ្យទាយាទរបស់អ្នកនិពន្ធបាន ដោយមូលហេតុនៃមរណភាពរបស់អ្នកនិពន្ធ ឬអាចប្រគល់ទៅឲ្យតតិយជនបានដោយសារយោងតាមបទបញ្ញត្តិមរតកសាសន៍[32]។

បញ្ហាពាក់ព័ន្ធទៅនឹងភាគបម្រុងបានកំណត់ដោយក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ដោយហេតុថាសិទ្ធិបេតិភណ្ឌ ជាសិទ្ធិដែលអាចគិតជាប្រាក់បាន ការផ្ទេរសិទ្ធិបេតិកភណ្ឌរបស់អ្នកនិពន្ធឲ្យតតិយជនតាមរយៈមរតកសាសន៍ ពុំត្រូវឲ្យមានការប៉ះពាល់ដល់ភាគបម្រុងរបស់ទាយាទបម្រុងឡើយ។

ក្នុងករណីគ្មានអ្នកទទួលមរតក រដ្ឋដែលតំណាងដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈជាអ្នកទទួលគ្រប់គ្រងសិទ្ធិនោះ។

**ឧទាហរណ៍៖** សម្រាប់ទាយាទ លោក **ស៊ីន ស៊ីសាមុត** ដែលបានទទួលមរណភាពនៅក្នុងសម័យ ប៉ុល ពត តែគាត់នៅសល់ទាយាទ(កូន និងប្រពន្ធ)រហូតដល់សព្វថ្ងៃ ចុះហេតុអ្វីបានជាស្នាដៃមួយចំនួនរបស់គាត់ត្រូវបានក្រសួងវប្បធម៌ និងវិចិត្រសិល្បៈគ្រប់គ្រងទៅវិញ? ហេតុអ្វីបានជាទាយាទរបស់ លោក ស៊ីន ស៊ីសាមុត មិនមានសិទ្ធិគ្រប់គ្រងដូចមាត្រា៣៣ នៃច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលឆ្នាំ២០០៣បានចែង?

ចម្លើយ គឺដោយសារតែទាយាទរបស់គាត់(លោក ស៊ីន ច័ន្ទឆាយា និងអ្នកពាក់ពន្ធដទៃ) មិនបានធ្វើបញ្ជីសារពើភ័ណ្ឌអំពីស្នាដៃរបស់ លោក ស៊ីន ស៊ីសាមុត ឲ្យបានច្បាស់លាស់ជាពិសេសគឺមិនអាចកំណត់ថាស្នាដៃទាំងនោះ ពិតជាស្នាដៃដែលបានបង្កើតឡើងដោយ លោក ស៊ី ស៊ីសាមុត មែនរឺយ៉ាងណា។ ត្រង់ចំណុចនេះធ្វើឲ្យការអះអាងរបស់ លោក ស៊ីន ច័ន្ទឆាយា មិនមានលក្ខណៈគ្រប់គ្រាន់សម្រាប់ធ្វើជាអំណះអំណាង ព្រោះមាត្រា ៣ និងមាត្រា ៧នៃច្បាប់ស្តីពីសិទ្ធិអ្នកនិព្ធ និងសិទ្ធិប្រហាក់ប្រហែលឆ្នាំ២០០៣ បានចង្អុលបង្ហាញទាយាទរបស់អ្នកនិពន្ធទាំងឡាយ ប្រសិនបើចង់គ្រប់គ្រងនូវស្នាដៃដែលបន្សល់ទុកដោយមតកជន គឺត្រូវមានភស្តុតាងគ្រប់គ្រាន់មកបញ្ជាក់ជូនក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីទទួលបាននូវឋានៈក្នុងការគ្រប់គ្រងសិទ្ធិនៃស្នាដៃ។ ក្រោយពីមានការបញ្ជាក់ភស្តុងតាង ក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ និងធ្វើការស្រាវជ្រាវបើពិនិត្យឃើញថាច្បាស់លាស់ត្រឹមត្រូវតាមផ្លូវច្បាប់ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈនឹងចេញសេចក្តីសម្រេចទទួល

[32] មាត្រា៣៣ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣

ឋានៈក្នុងការគ្រប់គ្រងលើស្នាដៃអក្សរសាស្ត្រ សិល្បៈ និងតូរ្យតន្ត្រី ដល់ញាតិពន្ធនៃម្ចាស់ស្នាដៃនោះ[33]។

### ការផ្ទេរសិទ្ធិតាមរយៈកិច្ចសន្យា

មានតែសិទ្ធិបេតិកភណ្ឌប៉ុណ្ណោះ ដែលអាចផ្ទេរតាមរយៈកិច្ចសន្យាបាន ចំណែកឯសិទ្ធិសីលធម៌វិញ ជាសិទ្ធិដែលមិនអាចផ្ទេរ ឬដោះដូរបានឡើយ៕

ការផ្ទេរសិទ្ធិរបស់ផលិតករវីដេអូ មិនអាចធ្វើឡើងដាច់ដោយឡែកពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិអ្នកសម្តែង ដែលបានរួមសហការផលិតវីដេអូបានឡើយ[34]។ មានន័យថា ការផ្ទេរសិទ្ធិផលិតករវីដេអូនាំឲ្យមានការផ្ទេរសិទ្ធិអ្នកនិពន្ធ និងសិទ្ធិអ្នកសម្តែងតែម្តង ហេតុនេះហើយចាំបាច់ត្រូវមានការយល់ព្រមពីអ្នកនិពន្ធ និងអ្នកសម្តែងផងដែរ។

មាត្រា៣២ វាក្យខណ្ឌទី២ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ សិទ្ធិប្រហាក់ប្រហែលបានអនុញ្ញាតឲ្យមានកិច្ចសន្យាពីរប្រភេទដែល អ្នកនិពន្ធអាចឲ្យតតិយជនតំណាងខ្លួនបាន គឺកិច្ចសន្យាផ្ទេរ និងកិច្ចសន្យាអាជ្ញាប័ណ្ណ។

បន្ទាប់ពីការផ្ទេរសិទ្ធិហើយអ្នកនិពន្ធ ឬម្ចាស់សិទ្ធិលែងមានសិទ្ធិនោះហើយ។ ផ្ទុយទៅវិញទោះបីជា កិច្ចសន្យាអាជ្ញាប័ណ្ណមានអនុភាពអនុវត្តស្ទើរតែដូចនឹងកិច្ចសន្យាផ្ទេរក៏ដោយ ក៏អ្នកនិពន្ធ ឬម្ចាស់សិទ្ធិនៅតែជាម្ចាស់សិទ្ធិដដែល គ្រាន់តែម្ចាស់សិទ្ធិអនុញ្ញាតឲ្យជនម្នាក់ទៀតអនុវត្តនូវសិទ្ធិជំនួសខ្លួនតែប៉ុណ្ណោះ។ នៅពេលដែលអាជ្ញាប័ណ្ណមួយ មានរយៈពេលស្មើនឹងរយៈពេលនៃសិទ្ធិបេតិកភណ្ឌ ហើយនៅពេលដែលអាជ្ញាប័ណ្ណនោះគ្របដណ្តប់នូវរាល់សិទ្ធិទាំងអស់ អ្នកទទួលអាជ្ញាប័ណ្ណស្ថិតនៅក្នុងស្ថានភាពដូចគ្នានឹងម្ចាស់សិទ្ធិដែរ។

ដើម្បីឲ្យកិច្ចសន្យាផ្ទេរអាជ្ញាប័ណ្ណមានសុពលភាព មាត្រា៣៤ និងមាត្រា៣៥ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ សិទ្ធិប្រហាក់ប្រហែលឆ្នាំ២០០៣ បានតម្រូវឲ្យមានលក្ខខណ្ឌបន្ថែមលើសពីលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាដូចជា៖

- ធ្វើជាលាយលក្ខណ៍អក្សរជាក់លាក់។
- ការមិនគោរពលក្ខខណ្ឌនេះនាំឲ្យកិច្ចសន្យាមោឃៈ ប៉ុន្តែមានតែអ្នកនិពន្ធឬម្ចាស់សិទ្ធិប៉ុណ្ណោះដែលមានសិទ្ធិលើកឡើងនូវហេតុផលដើម្បីស្នើរសុំមោឃភាពនៃកិច្ចសន្យា។

[33] សេចក្តីជូនដំណឹងលេខ៣៣ ស.ជ.ណ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការប្រគល់សិទ្ធិគ្រប់គ្រង់លើស្នាដៃអក្សរសាស្ត្រ សិល្បៈ និងតូរ្យតន្ត្រី ដែលគ្មានមរតកសាសន៍

[34] មាត្រា៤៦ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣

– បញ្ជាក់ភាពដាច់ដោយឡែកអំពី កម្រិតទំហំ គោលដៅ ទីកន្លែង និងរយៈពេលនៃការផ្ទេរសិទ្ធិនីមួយៗឲ្យបានច្បាស់លាស់។

**ការផ្ទេរសិទ្ធិតាមរយៈការអនុញ្ញាត ឬអាជ្ញាប័ណ្ណ**

ក្រោមការអនុញ្ញាត គឺម្ចាស់សិទ្ធិអាចអនុញ្ញាត ឬហាមនូវសកម្មភាពផ្នែកណាមួយ ឬច្រើន ឬសិទ្ធិទាំងស្រុងដែលមានចែងក្នុងច្បាប់ ដូច្នេះការអនុញ្ញាតគឺការផ្ទេរកម្មសិទ្ធិមួយផ្នែក ឬមួយភាគ។

ជាទូទៅ ការផ្តល់អាជ្ញាប័ណ្ណ មានន័យថាម្ចាស់កម្មសិទ្ធិថ្មីដែលទទួលបានពីការផ្ទេរសិទ្ធិអ្នកនិពន្ធអាចអនុញ្ញាតឲ្យភាគីទី៣ ធ្វើនូវរាល់សកម្មភាពលើសិទ្ធិសេដ្ឋកិច្ច ដោយមានរយៈពេលជាក់លាក់នឹងសម្រាប់គោលបំណងច្បាស់លាស់ណាមួយ ដែលអ្នកនិពន្ធប្រលោមលោកអាចផ្តល់អាជ្ញាប័ណ្ណឲ្យអ្នកបោះពុម្ព ការផលិត រួចចែកផ្សាយស្នាដៃនោះក្នុងពេលជាមួយគ្នានោះដែរ។

អាជ្ញាប័ណ្ណ អាចចេញដោយអង្គភាពគ្រប់គ្រងសិទ្ធិរួម[35] អ្នកនិពន្ធ ឬម្ចាស់សិទ្ធិដ៏ទៃទៀត អាចផ្តល់សិទ្ធិផ្តាច់មុខទៅឲ្យអង្គភាពគ្រប់គ្រងសិទ្ធិរួម ដែលអង្គភាពនោះតាំងនាមឲ្យខ្លួនដើម្បីផ្តល់ការអនុញ្ញាតដោយប្រមូល និងបែងចែប្រាក់លាភដើម្បីការពារ និងប្រឆាំងនិងការរំលោភសិទ្ធិ និងទាមទារនូវសំណងពីការរំលោភបំពានសិទ្ធិ។

### ខ. ការធ្វើអាជីវកម្មលើសិទ្ធិ

**ការធ្វើអាជីវកម្មទៅលើសិទ្ធិបេតិកភណ្ឌ**

ការធ្វើអាជីវកម្មទៅលើសិទ្ធិបេតិកភណ្ឌ ត្រូវបានធ្វើឡើងទៅតាមរូបភាពនៃការចុះកិច្ចសន្យា ហើយកិច្ចសន្យាទាំងឡាយណាដែលទាក់ទងនឹងការធ្វើអាជីវកម្មនេះ ត្រូវតែធ្វើឡើងតាមរយៈលិខិតជាលាយលក្ខណ៍អក្សរជាក់លាក់[36]។

**ឧទាហរណ៍៖** តន្ត្រីករម្នាក់បានផលិតចម្រៀងរបស់ខ្លួន និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនថតសម្លេង តន្ត្រីករនោះបានយល់ព្រមក្នុងការផ្ទេរនូវសិទ្ធិអ្នកនិពន្ធទាំងអស់ក្នុងការថតចម្លងទៅក្រុមហ៊ុន។

សំនួរសួរថា ហេតុអ្វីបានជាម្ចាស់សិទ្ធិអ្នកនិពន្ធបោះបង់ចោលនូវសិទ្ធិរបស់ខ្លួន? ចំលើយគឺថាក្រុមហ៊ុនធំៗមាននូវសមត្ថភាពផលិតកម្ម និងមានទីផ្សារច្រើនជាងអ្នកនិពន្ធ។ ក្នុងយុគសម័យវេខូបនីយកម្ម(Digital Age)នៃតន្ត្រី ប្រហែលជាត្រូវបានថតចម្លង និងបែងចែកក្នុងថ្លៃដើមទាបបំផុតតាមរយៈអ៊ីនធឺណែត។

---

35 "ប្រកាស ស្តីពីអង្គភាពគ្រប់គ្រងសិទ្ធិរួម លេខ ១១២ ប្រ.ក ចុះនៅថ្ងៃ ០៥ ខែកក្កដា ឆ្នាំ២០១៦

36 មាត្រា ៣៩ នៃច្បាប់សិទ្ធិអ្នកនិពន្ធ ឆ្នាំ២០០៣

ករណីខ្លះ ម្ចាស់សិទ្ធិអ្នកនិពន្ធ មិនអាចផ្ទេរសិទ្ធិទាំងស្រុងបានទេ។ សិទ្ធិមួយចំនួនអាចត្រូវបានផ្ទេរឲ្យភាគីផ្សេងទៀតនូវអាជ្ញាប័ណ្ណមិនផ្តាច់មុខដើម្បី ថតចម្លង ឬចែកចាយស្នាដៃទៅតំបន់ជាក់លាក់ណាមួយ។

**លក្ខខណ្ឌនៃការធ្វើអាជីវកម្មទៅលើសិទ្ធិបេតិកភណ្ឌ**

ចំពោះលក្ខខណ្ឌនៃកិច្ចសន្យាលើអាជីវកម្មសិទ្ធិបេតិកភណ្ឌ គឺត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ដាច់ដោយឡែកពីគ្នា អំពីកម្រិតទំហំ គោលដៅ ទីកន្លែង និងរយៈពេលនៃការផ្ទេរសិទ្ធិនីមួយៗឲ្យបានច្បាស់លាស់[37]។

ចំពោះកិច្ចសន្យាអាជីវកម្ម នៃសិទ្ធិអ្នកនិពន្ធ គឺគ្មានមាត្រាច្បាប់ណាមួយដែលបញ្ជាក់ឲ្យបានច្បាស់លាស់អំពីប្រភេទនៃកិច្ចសន្យាទេ។ នៅប្រទេសបារាំង សិទ្ធិអ្នកនិពន្ធមានលក្ខណៈជឿនលឿនហើយត្រូវបានមនុស្សទូទៅទទួលស្គាល់ ជាពិសេសអ្នកដែលមានចំណេះដឹងខាងវិស័យច្បាប់ សុទ្ធតែនាំគ្នាខិតខំបង្កើតឲ្យចេញជារូបរាងនៃកិច្ចសន្យា ដែលពាក់ព័ន្ធដូចជា កិច្ចសន្យាតំណាង កិច្ចសន្យាផលិតកម្ម សោតទស្សន៍ កិច្ចសន្យាអាជីវកម្ម និង កិច្ចសន្យាបោះពុម្ពផ្សាយ។

កិច្ចសន្យាបោះពុម្ពផ្សាយ ជាកិច្ចសន្យាដែលសំខាន់ជាងគេនៅក្នុងចំណោមកិច្ចសន្យាផ្សេងទៀតនៃសិទ្ធិអ្នកនិពន្ធ។ ជាទូទៅ កិច្ចសន្យាបោះពុម្ពផ្សាយគឺមានដូចជា ការបោះពុម្ពស្នាដៃអក្សរសាស្ត្រ ស្នាដៃផលិតកម្មវិធីកុំព្យូទ័រ ការបោះពុម្ពផ្សាយស្នាដៃតូរ្យតន្ត្រី(ទំនុកភ្លេង និងទំនុកច្រៀង)។

**ការសុំធ្វើមោឃភាពទៅលើការធ្វើអាជីវកម្ម**

គួរកត់ចំណាំផងដែរថាមានតែអ្នកនិពន្ធ ឬម្ចាស់សិទ្ធិប៉ុណ្ណោះដែលមានសិទ្ធិគ្រប់គ្រាន់លើករណីលើកឡើងនូវហេតុផលដើម្បីសុំមោឃភាពនៃកិច្ចសន្យាបាន។

ប្រសិនបើ ការងារធ្វើឡើងដើម្បីប្រាក់ឈ្នួលនោះនិយោជក គឺជាម្ចាស់ដើមនៃសិទ្ធិអ្នកនិពន្ធលើកលែងតែមានកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ ដែលមានចែងផ្ទុយពីនេះនឹងត្រូវបានចុះហត្ថលេខាដោយភាគីទាំងពីរ។

## ២.២. ការការពារសិទ្ធិអ្នកនិពន្ធ

ជាទូទៅស្នាដៃនីមួយៗដែលអ្នកនិពន្ធបានបង្កើតឡើង នឹងទទួលបាននូវការការពារសិទ្ធិចំពោះស្នាដៃទាំងនោះ ទោះបីជាស្នាដៃទាំងនោះជាប្រភេទស្នាដៃអ្វីក៏ដោយ ប៉ុន្តែការការពារមិនមែនចេះធ្វើឡើងជារៀង រហូតដល់ស្នាដៃនោះវិនាសបាត់បង់ទៅវិញនោះទេ ការការពារនេះគឺធ្វើឡើងក្នុងរយៈពេលមួយជាកំណត់។

[37] មាត្រា ៣៥ នៃច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣។

**២.២.១. លក្ខខណ្ឌទទួលបានសិទ្ធិការពារលើស្នាដៃ**

លក្ខខណ្ឌចម្បង ក្នុងការទទួលបាននូវការការពារ សិទ្ធិអ្នកនិពន្ធលើស្នាដៃមួយចាំបាច់ត្រូវតែជាស្នាដៃដើមរបស់អ្នកនិពន្ធ តែមិនសំដៅដល់ស្នាដៃ ដែលមានតម្លៃអស្ចារ្យមានតែមួយឬប្លែកថ្មីនោះទេ។ ស្នាដៃដើមរបស់អ្នកនិពន្ធជាស្នាដៃ ដែលអាចយល់ដឹងបានដោយញានរបស់មនុស្ស (ទោះបីជាមានជំនួយពីម៉ាស៊ីនដោយផ្ទាល់ក្តី) មានន័យថាប្រសិនបើគ្រាន់តែជាគំនិតដែលគិតនៅក្នុងចិត្តមិនត្រូវបានគេការពារទេ ព្រោះវាជារបស់អរូបិយ តែប្រសិនបើរឿងនោះត្រូវបានយកទៅសរសេរនៅលើក្រដាសនោះនឹងទទួលបាននូវការកាពារភ្លាម។

ស្នាដៃទាំងឡាយនិងទទួលបាននូវការការពារ កាលណាបើស្នាដៃនោះត្រូវបានបង្កើតឡើងដោយរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយដែលមានសញ្ជាតិខ្មែរ ឬមានលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយត្រូវបានបង្កើតឡើងដោយគោរពទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងមានការិយាល័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ម្យ៉ាងវិញទៀតស្នាដៃទាំងឡាយដែលបានបោះពុម្ពផ្សាយលើកដំបូង ឬបានបោះពុម្ពក្នុងអំឡុង៣០(សាមសិប)ថ្ងៃក្នុងព្រះរាជាណាចក្រកម្ពុជាបន្ទាប់ពីបោះពុម្ពលើកដំបូងនៅឯបរទេស ក៏ទទួលបានការការពារដែរ។

**ឧទាហរណ៍៖** ស្នាដៃរឿងប្រលោមលោក កុលាបប៉ៃលិន ដែលនិពន្ធនៅក្នុងទសវត្សទី៦០ ត្រូវបានទទួលការការពារដោយច្បាប់តែម្តង ព្រោះអ្នកនិពន្ធរឿងនេះគឺលោក ញ៉ុក ថែម ជាអ្នកនិពន្ធមានសញ្ជាតិខ្មែរ។

ចំពោះស្នាដៃសោតទស្សន៍ដែលផលិតករមានទីស្នាក់ការ ឬមានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងស្នាដៃស្ថាបត្យកម្ម ដែលបានសាងសង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងស្នាដៃសិល្បៈផ្សេងៗដែលភ្ជាប់ទៅនិងអាគារ ឬរចនាសម្ព័ន្ធផ្សេងទៀត ក្នុងព្រះរាជាណាចក្រកម្ពុជាក៏នឹងទទួលបានការការពារផងដែរ។ ចំពោះស្នាដៃដែលព្រះរាជាណាចក្រកម្ពុជាមានកាតព្វកិច្ចការពារស្ថិតក្រោមសន្ធិសញ្ញាអន្តរជាតិក៏ទទួលបានការការពារដូចគ្នា។

**២.២.២. ការរក្សាសិទ្ធិ Copyright©**

តាមច្បាប់នៅប្រទេសខ្លះ គេតម្រូវឲ្យដាក់សញ្ញា "©រក្សាសិទ្ធិ" លើស្នាដៃណាមួយ ទើបអាចទទួលបានការការពារសិទ្ធិអ្នកនិពន្ធ។ ក៏ប៉ុន្តែតាមច្បាប់នៅកម្ពុជាក៏ដូចជាប្រទេសផ្សេងទៀត ដែលជាហត្ថលេខី នៃអនុសញ្ញាក្រុងប៊ែន (Berne) គេមិនតម្រូវឲ្យមានដាក់សញ្ញា"©រក្សាសិទ្ធិទេ។ បើទោះ

ជាស្នាដៃដែលគ្មានដាក់សញ្ញា "©រក្សាសិទ្ធិ" ក៏ទទួលបានការការពារដោយសិទ្ធិអ្នកនិពន្ធដែរ។ ប៉ុន្តែសញ្ញា "©រក្សាសិទ្ធ" មានប្រយោជន៍ក្នុងការជូនដំណឹងដល់សាធារណជនថា ស្នាដៃនេះស្ថិតក្រោមការរក្សាសិទ្ធិ។ ប្រសិនបើគ្មានសញ្ញា "©រក្សាសិទ្ធិ" វាអាចចោទជាបញ្ហានៅពេលមានក្តីក្តាំ។ ចុងចោទគេអាចដោះសារថាគេមិនបានដឹងដោយស្មានថា ស្នាដៃនេះមិនមានរក្សាសិទ្ធិ។ ប្រសិនបើមានដាក់សញ្ញា "©រក្សាសិទ្ធិ" គេមិនអាចដោះសារថា មិនបានដឹងនោះទេ។

# ជំពូកទី៣

# ការរំលោភសិទ្ធិអ្នកនិពន្ធ

# និង

# យន្តការដោះស្រាយ

# ជំពូកទី ៣
# ការរំលោភសិទ្ធិអ្នកនិពន្ធ និងយន្តការដោះស្រាយ

## ៣.១. ការរំលោភសិទ្ធិអ្នកនិពន្ធ

តើអំពើណាខ្លះ ដែលចាត់ទុកជាអំពើរំលោភសិទ្ធិរបស់អ្នកនិពន្ធក្នុងនីតិកម្ពុជា? ជាទូទៅត្រូវបានគេចាត់ទុកថាជាអំពើរំលោភសិទ្ធិអ្នកនិពន្ធ គឺរាល់អំពើនៃការប្រើប្រាស់ ការចម្លងទាំងស្រុង ឬដោយផ្នែក ការផ្សព្វផ្សាយទាំងស្រុង ឬដោយផ្នែក តាមគ្រប់មធ្យោបាយដោយពុំមានការអនុញ្ញាតពីអ្នកនិពន្ធ។ អំពើរំលោភសិទ្ធិអ្នកនិពន្ធ សំដៅទៅលើការរំលោភសិទ្ធិបេតិកភណ្ឌ និង/ឬសិទ្ធិសីលធម៌របស់អ្នកនិពន្ធ។

ការរំលោភសិទ្ធិបេតិកភណ្ឌ សំដៅទៅលើការធ្វើអាជីវកម្ម ការផលិតឡើងវិញនូវស្នាដៃ ឬការចែកចាយនូវស្នាដៃដោយពុំមានការអនុញ្ញាតពីអ្នកនិពន្ធស្នាដៃ។

អំពើរំលោភសិទ្ធិសីលធម៌ សំដៅលើអំពើនៃការ កែប្រែខ្លឹមសារស្នាដៃ ការដក ឬដាក់បន្ថែមនូវខ្លឹមសារ ឬធាតុណាមួយនៃស្នាដៃ និងការលុបឈ្មោះអ្នកនិពន្ធចេញពីស្នាដៃដោយពុំមានការអនុញ្ញាតពីម្ចាស់សិទ្ធិ។

រាល់អំពើរំលោភសិទ្ធិអ្នកនិពន្ធគ្រប់រូបភាព ដោយប្រើមធ្យោបាយបែបណាក៏ដោយត្រូវបានចាត់ជាបទល្មើស និងត្រូវបានដាក់ទោសតាមច្បាប់។

### ៣.១.១. រូបភាពនៃអំពើរំលោភសិទ្ធិអ្នកនិពន្ធ

សិទ្ធិបេតិកភណ្ឌ ឬសិទ្ធិសេដ្ឋកិច្ចរបស់អ្នកនិពន្ធ សំដៅលើសិទ្ធិដែលអាចប្តូរជាប្រាក់បានតាមរយៈការធ្វើអាជីវកម្មលើស្នាដៃ។ ការផ្ទេរសិទ្ធិបេតិកភណ្ឌលើស្នាដៃឲ្យទៅតតីជនដោយទទួលបាននូវកម្រៃតបស្នង។ សកម្មភាពដូចបានរៀបរាប់ខាងលើដោយពុំមានការអនុញ្ញាតពីម្ចាស់សិទ្ធិត្រូវបានចាត់ទុកថាជាអំពើរំលោភលើសិទ្ធិបេតិកភណ្ឌរបស់អ្នកនិពន្ធ។ បុគ្គលណាដែលបានលួចចម្លងស្នាដៃដោយពុំមានការអនុញ្ញាតពីម្ចាស់ស្នាដៃ ក្នុងគោលដៅធ្វើអាជីវកម្មបន្តដើម្បីប្រយោជន៍ផ្ទាល់ខ្លួន ត្រូវបានចាត់ទុកថាជាអំពើរំលោភសិទ្ធិបេតិកភណ្ឌរបស់អ្នកនិពន្ធ និងត្រូវទទួលទណ្ឌកម្មតាមច្បាប់(ទណ្ឌកម្មរដ្ឋប្បវេណី និងទណ្ឌកម្មព្រហ្មទណ្ឌ)។

ច្បាប់សិទ្ធិអ្នកនិពន្ធ បានកំណត់នូវអំពើដែលចាត់ទុកថាជាអំពើរំលោភសិទ្ធិអ្នកនិពន្ធមានដូចជា៖ "រាល់អំពើនៃការផលិត ការផលិតឡើងវិញ ឬការសម្តែង ឬការផ្សព្វផ្សាយនូវស្នាដៃដែលប្រើតាមមធ្យោបាយណាក៏ដោយ[38]។

[38] មាត្រា ៦៤ កថាខណ្ឌទី១ នៃច្បាប់សិទ្ធិអ្នកនិពន្ធ ឆ្នាំ២០០៣។

អំពើដែលត្រូវចាត់ទុកថាជាបទល្មើសមានដូចខាងក្រោម[39]៖

- ការផលិត ឬការនាំចូលដើម្បីដាក់លក់ ឬដាក់ជូលនូវឧបករណ៍ ឬគ្រឿងមធ្យោបាយណាមួយដែលធ្វើឡើង ឬយកលំនាំតាម ក្នុងគោលបំណងឲ្យរាំងស្ទះដំណើរការល្អនៃឧបករណ៍ ឬគ្រឿងមធ្យោបាយទូទៅ ឬកាត់បន្ថយចំនួនការផលិតឡើងវិញនូវស្នាដៃហ្វូណូក្រាម ឬការផ្សាយតាមទូរផ្សាយ ឬធ្វើឲ្យខូចខាតគុណភាពនូវច្បាប់ចម្លង។
- ការផលិត ឬការនាំចូលដើម្បីដាក់លក់ ឬដាក់ជូលនូវឧបករណ៍ ឬគ្រឿងមធ្យោបាយណាមួយដែលនាំឲ្យបុគ្គលគ្មានសិទ្ធិទទួលបាននូវកម្មវិធីផ្សាយតាមសញ្ញា លេខកូដ ទូផ្សាយ ឬផ្សាយជាសាធារណៈតាមវិធីផ្សេងៗ រួមមានការផ្សាយតាមផ្កាយរណប។
- ការលុបចោល ឬការប្រែព័ត៌មានស្តីពីរបបសិទ្ធិ[40] តាមទម្រង់អេឡិចត្រូនិច ដោយគ្មានការអនុញ្ញាពីម្ចាស់កម្មសិទ្ធិ។
- ការចែកចាយ ឬការនាំចូលដើម្បីចែកចាយផ្សាយ តាមអង្គភាពទូរផ្សាយ ការផ្សាយជាសាធារណៈ ឬការដាក់ជូនសាធារណៈជននូវស្នាដៃ ការសម្តែង ហ្វូណូក្រាម ឬកម្មវិធីផ្សាយនៃអង្គភាពទូរផ្សាយដោយគ្មានការអនុញ្ញាត ហើយអ្នកប្រព្រឹត្តដឹងច្បាស់ថា ព័ត៌មានស្តីពីរបបសិទ្ធិតាមទម្រង់អេឡិចត្រូនិចជាព័ត៌មាន ដែលត្រូវបានគេលុបចោល ឬកែប្រែរួចហើយ។

### ៣.១.២. ទណ្ឌកម្មពិន័យ និងព្រហ្មទណ្ឌនៃអំពើរំលោភសិទ្ធិអ្នកនិពន្ធ

ច្បាប់បានកំណត់ពីទណ្ឌកម្មពិន័យចំពោះបទល្មើសរំលោភសិទ្ធិអ្នកនិពន្ធដូចខាងក្រោម៖

❖ **បទល្មើសនៃការផលិត ឬការផលិតឡើងវិញ**

បទល្មើសនៃការផលិត ឬការផលិតឡើងវិញ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥ (ប្រាំ) លានរៀល ដល់ ២៥ (ម្ភៃប្រាំ) លានរៀន និង/ឬត្រូវបានផ្តន្ទាទោសជាប់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ដល់ ១២ (ដប់ពីរ) ខែ។ ក្នុងករណីមិនរាងចាល ត្រូវទទួលស្លានទម្ងន់ទោសទ្វេរដង[41]។

❖ **បទល្មើសនាំចូល ឬនាំចេញផលិតផលរំលោភសិទ្ធិអ្នកនិពន្ធ៖**

ការនាំចូល ឬនាំចេញនូវផលិតផលបានមកពីបទល្មើស ក្នុងទម្រង់ជាការផលិតឡើងវិញ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២ (ពីរ) លានរៀល ដល់១០ (ដប់) លានរៀល និង/ឬត្រូវបានផ្តន្ទា

[39] មាត្រា ៦២ នៃច្បាប់សិទ្ធិអ្នកនិពន្ធ ឆ្នាំ២០០៣។
[40] មាត្រា ៦៣ កថាខណ្ឌទី១ នៃច្បាប់សិទ្ធិអ្នកនិពន្ធ ឆ្នាំ២០០៣។
[41] មាត្រា ៦៤ កថាខណ្ឌទី២ នៃច្បាប់សិទ្ធិអ្នកនិពន្ធ ឆ្នាំ២០០៣។

ទោសជាប់ពន្ធនាគារពី ១ (មួយ) ខែ ដល់១២ (ដប់ពីរ) ខែ។ ក្នុងករណីមិនរាងចាល ត្រូវទទួលស្ថានទម្ងន់ទោសទ្វេដង។

❖ **បទល្មើសនៃការសម្តែង ឬការផ្សព្វផ្សាយស្នាដៃ**

បទល្មើសនៃការសម្តែង ឬការផ្សព្វផ្សាយស្នាដៃត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១ (មួយ) លានរៀល ដល់ ៥ (ប្រាំ) លានរៀល និង/ឬ ត្រូវបានផ្តន្ទាទោសជាប់ពន្ធនាគារពី ១ (មួយ) ខែ ដល់ ៣ (បី) ខែ។ ក្នុងករណីដែលបទល្មើសត្រូវបានប្រព្រឹត្តច្រើនដង ការផ្តន្ទាទោសត្រូវគុណ នឹងចំនួនដងនៃការប្រព្រឹត្ត។ ក្នុងករណីមិនរាងចាល ត្រូវទទួលស្ថានទម្ងន់ទោសទ្វេរដង។

❖ **សំណងរដ្ឋប្បវេណី**

អ្នកនិពន្ធដែលត្រូវគេរំលោភបំពាន អាចប្តឹងទៅតុលាការដើម្បីបញ្ឈប់ការរំលោភបំពានសិទ្ធិរបស់ខ្លួនក្នុងបំណងទប់ស្កាត់នូវការខូចខាត[42]។ ក្នុងករណីអំពើការរំលោភបំពាននោះបម្រុងនឹងកើតឡើងម្ចាស់សិទ្ធិអាចស្នើសុំឲ្យឃាត់ចុងចោទពីការរំលោភបំពានសិទ្ធិរបស់គាត់។ ក្រៅពីការទូទាត់សំណង ម្ចាស់សិទ្ធិអាចពិនិត្យមើលពីផលប្រយោជន៍ដែលបានមកពីអំពើល្មើសនោះព្រមទាំងរឹបអូសយកនូវឧបករណ៍ និងសម្ភារៈក្នុងអំពើនោះទៀតផង។

តុលាការអាចបញ្ជារឲ្យរឹបអូសយក ឬបំផ្លាញចោលនូវឧបករណ៍ និងសម្ភារៈដែលបានផលិត ឬប្រើប្រាស់។ ក្នុងរយៈពេល៣០ថ្ងៃនៃការរឹបអូសនោះ ម្ចាស់សម្ភារៈដែលគេបានរឹបអូសយកនោះ អាចស្នើសុំទៅតុលាការឲ្យដោះលែងក្នុងករណីមានភស្តុតាងផ្ទុយ។

តុលាការមានអំណាច ចាត់វិធានការដែលចាំបាច់ដើម្បីធានារក្សាទុកនូវផលិតផលខុសច្បាប់។ ដើម្បីរក្សាសុវត្ថិភាព ម្ចាស់បណ្តឹងត្រូវទទួលខុសត្រូវនូវរាល់ការខូចខាតចំពោះចុងចម្លើយប្រសិនបើតុលាការមិនបានរកឃើញភស្តុតាងពិតប្រាកដ។

## ៣.២. ការចាត់វិធានការការពារសិទ្ធិអ្នកនិពន្ធ

ជាគោលការណ៍ ម្ចាស់សិទ្ធិមានសិទ្ធិរកដំណោះស្រាយតាមប្រពន្ធ័តុលាការ តាមរយៈការដាក់ពាក្យបណ្តឹងអំពីអំពើរំលោភសិទ្ធិនេះ។ ប៉ុន្តែ នៅក្នុងវិស័យកម្មសិទ្ធិបញ្ញា ភាគីអាចបើក ឱកាសឲ្យមានការចរចាលើការបញ្ឈប់អំពើតាមរយៈការ ជូនដំណឹង(ហៅថា"លិខិតព្រមាន")ទៅលើអ្នករំលោភសិទ្ធិ និង/ឬ ទាមទារសំណងព្យសនៈកម្មទទួលរងដោយអំពើល្មើសនោះ។

### ៣.២.១. វិធានការជូនដំណឹង

វិធានការនេះ អាចត្រូវបានចាត់ទុកថាជាវិធានការទន់ភ្លន់របស់ម្ចាស់សិទ្ធិនៅក្នុងការជូនដំណឹងដល់អ្នករំលោភសិទ្ធិ បញ្ឈប់អំពើរំលោភនេះ និងទាមទារនូវសំណងសមរម្យ។ តាមរយៈវិធាន

[42] មាត្រា៥៧ នៃច្បាប់សិទ្ធិអ្នកនិពន្ធ ឆ្នាំ២០០៣។

ការនេះ ម្ចាស់សិទ្ធិអាចធ្វើជាលិខិតព្រមាន ឬជូនដំណឹងអំពីការរំលោភសិទ្ធិអ្នកនិពន្ធរបស់គាត់ទៅតតីយជន(រំលោភបំពាន)ឲ្យធ្វើការបញ្ឈប់នូវអំពើរំលោភទាំងនោះ។ វិធានការនេះគ្រាន់តែជាការរំលឹកដាស់តឿនទៅដល់ជនរំលោភបំពាន អំពីអំពើរំលោភសិទ្ធិរបស់អ្នកនិពន្ធ និងចរចារក្នុងការបញ្ឈប់អំពើរំលោភសិទ្ធិអ្នកនិពន្ធតែប៉ុណ្ណោះ។ វិធានការបន្តបន្ទាប់ទៀតនឹងត្រូវអនុវត្តដោយម្ចាស់សិទ្ធិ ប្រសិនបើមានភស្តុតាងច្បាស់លាស់បញ្ជាក់ថា អ្នករំលោភសិទ្ធិនោះពុំបានបញ្ឈប់នូវអំពើរំលោភបំពានសិទ្ធិអ្នកនិពន្ធនោះទេ។

### ៣.២.២. វិធានការបណ្ដោះអាសន្ន

វិធានការនេះមានលក្ខណៈបណ្ដោះអាសន្នដែលប្រព្រឹត្តទៅ និងអនុវត្តដោយអ្នកកាន់កាប់បញ្ជី ឬដោយការបង្គាប់ដែលមានលក្ខណៈជាសេចក្ដីសម្រេចរបស់តុលាការ។ នីតិវិធីនេះ គឺមានសារៈសំខាន់ណាស់ក្នុងករណីមានការរំលោភបំពានពីព្រោះភស្តុតាងតែងតែត្រូវបានគេលុបបំបាត់ចោលមុនពេលដែលភស្តុតាងដ៏ចម្បង នៃការរំលោភអាចត្រូវគេរកឃើញ។

ប្រសិនបើគេអនុវត្តទៅតាមវិធានរបស់តុលាការ ហើយធ្វើឡើងយ៉ាងប្រុងប្រយ័ត្ននូវកាកំណត់ពេលវេលាតឹងរឹង នោះគេនឹងអាចទប់ស្កាត់នូវការរំលោភបំពាន និងការបំផ្លាញភស្តុតាងនេះរហូតដល់កំរឹតមួយទាបបំផុត មានន័យថាតាមសំណើរបស់អ្នកប្ដឹង តុលាការមានអំណាចដាក់ចេញនូវវិធានការបណ្ដោះអាសន្ន(ដីកាលើកពាក្យសុំឬដីកាប្រញាប់) ជាបន្ទាន់ វាជាប្រសិទ្ធភាពដើម្បីទប់ស្កាត់ការរំលោភបំពានដែលប្រុងនឹងកើតមាន ឬរក្សាភស្តុតាងដែលពាក់ព័ន្ធឲ្យបានគង់វង្ស។

នៅពេលដែលវិធានការត្រូវបានគេដាក់ចេញ តុលាការត្រូវជូនដំណឹងដល់ចុងចម្លើយអំពីសេចក្ដីសម្រេចពីការចាត់វិធានការបណ្ដោះអាសន្ននេះ។ ក្នុងករណីនេះចុងចម្លើយអាចដាក់ពាក្យបណ្ដឹងទៅតុលាការ ដើម្បីស្នើសុំឲ្យតុលាការពិនិត្យវិធានការនេះឡើងវិញក្នុងរយៈពេល១៥ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យបណ្ដឹងពីសេចក្ដីសម្រេចរបស់តុលាការ។ តុលាការត្រូវផ្ដល់ឱកាសសវនាការដល់ភាគីដែលពាក់ព័ន្ធហើយត្រូវពិនិត្យវិធានការនេះឡើងវិញ និងតម្កល់ ឬកែតម្រូវ ឬលុបចោលនូវសេចក្ដីសម្រេចរបស់ខ្លួនក្នុងរយៈពេលមួយសមស្របតាមច្បាប់កំណត់។

តុលាការចេញវិធានការបណ្ដោះអាសន្ន ដោយផ្អែកទៅលើ ការផ្ដល់ជូននូវឯកសារពីសំណាក់ដើមចោទដូចជា ភស្តុតាងត្រឹមត្រូវដែលពាក់ព័ន្ធធ្វើឲ្យតុលាការយល់ស្របក្នុងកម្រិតមួយគ្រប់គ្រាន់សម្រាប់សន្និដ្ឋាន និងបញ្ជាក់ថា ដើមចោទពិតជាម្ចាស់ពិតប្រាកដមែន ហើយសិទ្ធិរបស់អ្នកប្ដឹងកំពុងត្រូវបានគេរំលោភបំពាននោះ អាចនឹងកើតឡើងក្នុងពេលឆាប់ៗ។ ចំពោះប្រាក់កក់ធានាដែលតម្រូវ ឬការធានាដែលមានតម្លៃនៃប្រាក់កក់គ្រប់គ្រាន់ក្នុងការការពារចុងចម្លើយ និងទប់ស្កាត់កុំឲ្យមានការរំលោភបំពាន ប្រាក់ធានានោះត្រូវស្ថិតនៅក្រោមការកម្រឹតរបស់តុលាការ។ ករណីដើមចោទវិញ

នៅក្នុងរយៈពេល២០ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃបានទទួលដំណឹងពីការដាក់ចេញនូវវិធានការបណ្ដោះអាសន្នហើយ ឬនៅក្នុងរយៈពេលមួយសមស្រប ដែលកំណត់ដោយតុលាការនៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន បើមិនបានផ្ដួចផ្ដើមបន្តសំណុំរឿងបណ្ដឹង ប្ដឹងពីសេចក្ដីសម្រេចដល់អង្គសេចក្ដីក្នុងករណីនោះទេ តុលាការលុបចោលនូវវិធានការបណ្ដោះអាសន្ននោះចោលវិញ ដោយផ្អែកទៅតាមសំណើរបស់ចុងចម្លើយ[43]។

**៣.២.៣. វិធានការតាមមាត់ច្រកព្រំដែន**

មាត្រា៦៣ ច្បាប់ស្ដីពីសិទ្ធិអ្នកនិពន្ធ និងប្រហាក់ប្រហែល ឆ្នាំ២០០៣ ជាមូលដ្ឋានមួយអនុញ្ញាតឲ្យមានវិធានការតាមមាត់ច្រកព្រំដែន ចំពោះការរំលោភលើសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល។ បទបញ្ញត្តិនេះសមស្របជាមួយនឹងមាត្រា៥១នៃកិច្ចព្រមព្រៀង TRIPS ដែលចែងថាប្រទេសជាសមាជិកអាចអនុម័តនីតិវិធីនានា ដើម្បីឲ្យអាជ្ញាធររដ្ឋបាល ឬតុលាការ មានសមត្ថកិច្ចប្ដឹងជាលាយលក្ខណ៍អក្សរ សំដៅឲ្យអាជ្ញាធរគយផ្អាកការដាក់ឲ្យចរាចនូវទំនិញណាមួយ ប្រសិនបើម្ចាស់សិទ្ធិបញ្ញាមានមូលហេតុត្រឹមត្រូវ សង្ស័យថាមានការនាំចូលនៅទំនិញថតចម្លងប៉ះពាល់ដល់សិទ្ធិអ្នកនិពន្ធ។

នីតិវិធីទាក់ទង នឹងវិធានការតាមមាត់ច្រកព្រំដែន មានចែងក្នុងច្បាប់ស្ដីពីអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលឆ្នាំ២០០៣ ច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងការប្រកួតប្រជែងមិនស្មោះត្រង់ដែលចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០០២[44] ព្រមទាំងកិច្ចព្រមព្រៀង TRIPS ចាប់ពីមាត្រា៥១ និងមាត្រាបន្តបន្ទាប់។ នីតិវិធីទាំងនោះត្រូវប្រព្រឹត្តិទៅដូចខាងក្រោមៈ

**៦. បណ្ដឹង**

នៅពេលមានទំនិញក្លែងបន្លំ ពោលគឺទិញលទ្ធផលបានមកពីការបំពានលើសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលដូចជា សៀវភៅអានបោះពុម្ពដោយគ្មានការអនុញ្ញាតពីម្ចាស់សិទ្ធិស៊ីឌីចំរៀងក្លែងក្លាយជាដើម ម្ចាស់សិទ្ធិអាចស្នើសុំជាលាយលក្ខណ៍អក្សរទៅរដ្ឋបាលគយ និងរដ្ឋាករក្នុងគោលបំណងឲ្យអាជ្ញាធរមានសមត្ថកិច្ចធ្វើការឃាត់ទុកជាបន្ទាន់នូវទំនិញក្លែងក្លាយទាំងនោះ[45]។

មាត្រា៥១ នៃកិច្ចព្រមព្រៀង TRIPS ក៏ដូចជាមាត្រា៣៥ នៃច្បាប់ស្ដីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០១ ដោយតម្រូវឲ្យម្ចាស់បណ្ដឹងបង្ហាញភស្តុតាង

[43] ជំពូកទី៩ ច្បាប់ម៉ាក បញ្ជីពាណិជ្ជកម្ម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២

[44] មាត្រា ៦៣ កថាខណ្ឌទី១ នៃច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល តំរូវឲ្យយកបទបញ្ញត្តិស្ដីពីវិធាន ការតាមមាត់ច្រកព្រំដែននៃច្បាប់ស្ដីពីម៉ាក់ ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងដោយមិនស្មោះត្រង់ ឆ្នាំ២០០២យកមកអនុវត្តជាបន្ថែមទៀត។

[45] មាត្រា ៦៣ នៃច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣

ច្បាស់លាស់ថា ខ្លួនជាម្ចាស់សិទ្ធិត្រឹមត្រូវ ឬនិយាយម្យ៉ាងទៀតថា ត្រូវមានភស្តុតាងសមស្របដើម្បីឲ្យអាជ្ញាធរមានសមត្ថកិច្ចជឿរថា ប្រហែលជាមានការប៉ះពាល់ដល់សិទ្ធិកម្មសិទ្ធិបញ្ញា ព្រមទាំងធ្វើការពណ៌នាជាលម្អិតគ្រប់គ្រាន់ពីទំនិញ ដើម្បីឲ្យអាជ្ញាធរពាក់ព័ន្ធអាចស្គាល់ទំនិញដែលពាក់ព័ន្ធយ៉ាងងាយស្រួល។

មាត្រា៦៣ ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២ ពាក្យបណ្តឹងខាងលើនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរអមដោយៈ

- សេចក្តីថ្លែងពីមូលហេតុនៃការប្តឹង និងជាពិសេសភស្តុតាងដំបូងដែលបង្ហាញថាទំនិញនោះពិតជាប៉ះពាល់ដល់សិទ្ធិអ្នកនិពន្ធមែន។
- ការរៀបរាប់ដ៏ល្អិតល្អន់ពីទំនិញដែលជាកម្មវត្ថុនៃសិទ្ធិអ្នកនិពន្ធត្រឹមត្រូវ។
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង និងតំណាងរបស់គេត្រូវរៀបរាប់ឲ្យបានសព្វគ្រប់តាមការកំណត់។
- លិខិតអនុញ្ញាតពីម្ចាស់សិទ្ធិអ្នកនិពន្ធ ប្រសិនបើពាក្យបណ្តឹងនោះត្រូវបានដាក់តំណាងដែលទទួលសិទ្ធិ។
- កម្រៃរដ្ឋបាល តាមកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

កិច្ចព្រមព្រៀង TRIPS អនុញ្ញាតឲ្យច្បាប់នៃប្រទេសជាសមាជិក ទុកសិទ្ធិឲ្យអាជ្ញាធរមានសមត្ថកិច្ចឃាត់ទុកទំនិញដោយផ្តួចផ្តើមរបស់ខ្លួនតែម្តង។ ប៉ុន្តែច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលឆ្នាំ២០០៣ ក៏ដូចជាច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២ ដែរពុំបានបញ្ញត្តិអនុញ្ញាតឲ្យធ្វើយ៉ាងដូច្នេះឡើយ។ កិច្ចព្រមព្រៀងTRIPS ចែងថា ក្នុងករណីដែលប្រទេសជាសមាជិក ទាមទារឲ្យអាជ្ញាធរមានសមត្ថកិច្ចធ្វើសកម្មភាពដោយសារការផ្តួចផ្តើមគំនិតផ្ទាល់ខ្លួន ហើយឃាត់ទុកទំនិញមិនឲ្យធ្វើចរាចរណ៍ ដោយហេតុថាគេមានភស្តុតាងសន្មតថាទំនិញទាំងនោះប៉ះពាល់ដល់កម្មសិទ្ធិបញ្ញាៈ

  - អាជ្ញាធរមានសមត្ថកិច្ច អាចស្នើសុំឲ្យម្ចាស់សិទ្ធិផ្តល់នូវរាល់ព័ត៌មានដែលអាចជួយគេក្នុងការអនុវត្តអំណាចរបស់ខ្លួន។
  - អ្នកនាំចូលនិងម្ចាស់សិទ្ធិ ត្រូវទទួលដំណឹងពីការឃាត់ទុកនេះក្នុងរយៈពេលយ៉ាងឆាប់បំផុត ក្នុងករណីដែលអ្នកនាំចូលប្តឹងជំទាស់នឹងការឃាត់ទុក ការឃាត់ទុកនេះត្រូវគោរពតាមលក្ខខណ្ឌក្នុងមាត្រា៥៥ ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣។

- ប្រទេសជាសមាជិកនឹងឲ្យអាជ្ញាធរ និងភ្នាក់ងារសាធារណៈ ឲ្យរួចផុតពីការទទួលខុសត្រូវតែក្នុងដែលពួកគេប្រព្រឹត្តិអំពើ ឬមានបំណងប្រព្រឹត្តអំពើដោយចេតនាសុចរិត[46]។

**៦ សេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ច**

មាត្រា៥២ នៃកិច្ចព្រមព្រៀង TRIPS អាជ្ញាធរមានសមត្ថកិច្ចត្រូវជូនដំណឹងដល់អ្នកប្តឹងក្នុងរយៈពេលសមហេតុផលថាតើខ្លួនយល់ព្រមតាមសំណើររបស់អ្នកប្តឹងឬអត់ ហើយជូនដំណឹងដល់អ្នកប្តឹងពីរយៈពេលកំណត់ដែលអាជ្ញាធរគយចាត់វិធានការ។ ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់បានកំណត់រយៈពេលចំនួន១០ថ្ងៃ។ បានសេចក្តីថាក្នុងរយៈពេល ១០ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលនូវពាក្យបណ្តឹង រដ្ឋបាលគយនិងរដ្ឋាករត្រូវជូនដំណឹងទៅអ្នកប្តឹងថាពាក្យបណ្តឹងរបស់ខ្លួនត្រូវបានទទួលស្គាល់ថាត្រឹមត្រូវ ឬបដិសេធ ឬមួយរក្សាទុកសម្រាប់ពិចារណាទៅពេលក្រោយ។

ច្បាប់ប្រទេសកម្ពុជា ក៏ដូចជាកិច្ចព្រមព្រៀងTRIPS ដែលអនុញ្ញាតឲ្យរដ្ឋបាលគយនិងរដ្ឋាករស្នើសុំឲ្យអ្នកប្តឹងបង់ប្រាក់ធានា ឬតម្រូវឲ្យមានការធានាមានតម្លៃស្មើនឹងប្រាក់កក់គ្រប់គ្រាន់សម្រាប់ការពារអ្នកទទួល អ្នកនាំចេញ ឬម្ចាស់ទំនិញបាន[47]។ ប្រាក់ធានានេះមានគោលដៅបង្កាការប្រើប្រាស់នីតិវិធីដោយរំលោភ។ ទោះជាយ៉ាងណាក្តីប្រាក់ធានា ឬការធានាខាងលើ ត្រូវកំណត់តាមរបៀប និងបែបបទមួយ ដែលមិនត្រូវរារាំងដល់ការអនុវត្តនីតិវិធីនេះដោយមិនសមហេតុផលឡើយ[48] ព្រោះថាប្រសិនបើ មានការតម្រូវឲ្យបង់ប្រាក់ធានាច្រើនពេកម្ចាស់សិទ្ធិប្រហែលជាខ្លាចរអាមិនហ៊ានប្តឹងឡើយ។

បន្ទាប់ពីបានសម្រេចរួចហើយ រដ្ឋបាលគយ និងរដ្ឋាករ ត្រូវជូនដំណឹងដល់ភាគីពាក់ព័ន្ធ។ ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ២០០២ តម្រូវឲ្យរដ្ឋបាលគយ ឬរដ្ឋាករត្រូវជូនដំណឹងជាបន្ទាន់ដល់តុលាការមានសមត្ថកិច្ច អាជ្ញាធរជាដើមបណ្តឹង អ្នកកាន់កាប់ទំនិញ បញ្ញត្តិស្របជាមួយនឹងមាត្រា៥៤ នៃកិច្ចព្រមព្រៀង TRIPS ដែលកំណត់ឲ្យអ្នកនាំចូល និងអ្នកប្តឹងត្រូវទទួលការជូនដំណឹងអំពីការឃាត់ទុកទំនិញពុំឲ្យធ្វើចរាចរណ៍ក្នុងរយៈពេលយ៉ាងខ្លី។

តាមច្បាប់កម្ពុជាវិញ រដ្ឋបាលគយ និងរដ្ឋាករអាចអនុញ្ញាតឲ្យម្ចាស់សិទ្ធិ អ្នកនាំចូល ឬអ្នកនាំចេញពិនិត្យទំនិញដែលបានព្យួរទុកតាមបែបបទរដ្ឋបាលគយ ក្នុងគោលដៅវិភាគឲ្យដឹងថាទំនិញ

[46] មាត្រា ៥៤ នៃកិច្ចព្រមព្រៀង TRIPS

[47] មាត្រា៣៨ ច្បាប់ស្តីពីម៉ាក់ ពាណិជ្ជនាម និងអំពើនៃការប្រគួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២ និងមាត្រា ៥២ នៃកិច្ចព្រមព្រៀង TRIPS

[48] មាត្រា៣៨ ច្បាប់ស្តីពីម៉ាក់ ពាណិជ្ជនាម និងអំពើនៃការប្រគួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២

នោះជាទំនិញក្លែងបន្លំដែលអាចប៉ះពាល់ដល់សិទ្ធិអ្នកនិពន្ធដែរឬទេ។ អាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិសម្រេចឲ្យអ្នកប្តឹងសងទៅម្ចាស់ទំនិញ អ្នកនាំចូល និងអ្នកទទួលទំនិញនូវសំណងសមស្របចំពោះការខូចខាតរបស់គេ ដែលបណ្តាលមកពីការឃាត់ទុកទំនិញមិនត្រឹមត្រូវ។ ភាគីមិនសុខចិត្តអាចប្តឹងទៅតុលាការបាន។

រដ្ឋបាលគយ និងរដ្ឋាករ មានសិទ្ធិបំផ្លាញចោលនូវទំនិញក្លែងក្លាយតាមរយៈសេចក្តីសម្រេចរបស់តុលាការ[49]។

គួរគូសបញ្ជាក់ថា បទប្បញ្ញត្តិទាក់ទងនឹងការឃាត់ទុកទំនិញក្លែងក្លាយនេះមិនត្រូវយកមកអនុវត្តក្នុងករណីដែលទំនិញក្លែងក្លាយ មិនមានលក្ខណៈពាណិជ្ជកម្មដែលនៅក្នុងឥវាន់ផ្ទាល់ខ្លួនរបស់អ្នកដំណើរ។

កិច្ចព្រមព្រៀង TRIPS ចែងថា ដោយពុំមានការខូចខាតដល់ការការពារព័ត៌មានសម្ងាត់ ប្រទេសជាសមាជិក អាចផ្តល់នីតិសម្បទាឲ្យអាជ្ញាធរមានសមត្ថកិច្ចរៀបចំនូវលទ្ធភាពមួយគ្រប់គ្រាន់ដល់ម្ចាស់សិទ្ធិ ក្នុងការត្រួតពិនិត្យរាល់ទំនិញទាំងអស់ ដែលឃាត់ទុកដោយអាជ្ញាធរគយដើម្បីបញ្ជាក់ឲ្យឃើញពីភាពត្រឹមត្រូវនៃការអះអាងរបស់ខ្លួន។ អាជ្ញាធរមានសមត្ថកិច្ចក៏មាននិតិសម្បទារៀបចំនូវលទ្ធភាពដល់អ្នកនាំចូល ក្នុងការត្រួតពិនិត្យទំនិញទាំងនោះ។ ក្នុងករណីដែលការកំណត់មានលក្ខណៈវិជ្ជមានប្រទេសដែលជាសមាជិកអាចផ្តល់ នីតិសម្បទាឲ្យអាជ្ញាធរមានសមត្ថកិច្ចផ្តល់ព័ត៌មានដល់ម្ចាស់សិទ្ធិ អំពីឈ្មោះអាសយដ្ឋានរបស់អ្នកផ្ញើទំនិញ អ្នកនាំចូល អ្នកទទួលទំនិញព្រមទាំងបរិមាណនៃទំនិញពាក់ព័ន្ធ[50]។

**៦. ករណីលើកលែងនៃការឃាត់ទុក**

មាត្រា៦៣ ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលឆ្នាំ២០០៣ បានកំណត់ឲ្យលើកលែងការឃាត់ទុកប្រសិនបើរយៈពេល១០ថ្ងៃនៃការធ្វើការ(អាចពន្យាពេលបាន១០ថ្ងៃធ្វើការបាន)។ ហើយរយៈពេល១០ថ្ងៃនេះ គឺគិតចាប់ពីថ្ងៃជូនដំណឹងពីការឃាត់ទុក អ្នកប្តឹងពុំបានបង្ហាញភស្តុតាងត្រឹមត្រូវដើម្បីបញ្ជាក់ទៅរដ្ឋបាលគយ និងរដ្ឋាករឲ្យដឹងថាសមីខ្លួនបាន៖

1. ស្នើទៅតុលាការឲ្យចាត់វិធានការតាមមាត្រា៥៩ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលឆ្នាំ២០០៣។ បានសេចក្តីថា ស្នើទៅតុលាការឲ្យចាត់វិធានការបណ្តោះអាសន្ន។

[49] មាត្រា៩៦ ច្បាប់ស្តីពីម៉ាក់ ពាណិជ្ជនាម និងអំពើនៃការប្រគួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២
[50] មាត្រា ៥៧ នៃកិច្ចព្រមព្រៀង TRIPS

2. ប្ដឹងទៅតុលាការដោយមានភ្ជាប់ជាមួយនូវការធានាគ្រប់គ្រាន់ ដើម្បីការពារទុកជាមុននៅការទទួលខុសត្រូវរបស់ខ្លួនដែលអាចមានកើតឡើងជាយថាហេតុ។ មាត្រា៥៥ នៃកិច្ចព្រមព្រៀងTRIPS ក៏មានបញ្ញត្តិប្រហាក់ប្រហែលគ្នានេះដែរដោយចែងថា ប្រសិនបើក្នុងរយៈពេលមិនហួសពី១០ថ្ងៃ ក្រោយពេលពីអ្នកប្ដឹងទទួលដំណឹងពីការឃាត់ទំនិញ អាជ្ញាធរគយពុំទទួលដំណឹងថា អ្នកប្ដឹងបានចាត់ការឲ្យមាននីតិវិធីនាំទៅដល់សេចក្ដីសម្រេចដល់អង្គសេចក្ដី ឬក៏អាជ្ញាធរមានសមត្ថកិច្ចបានចាត់វិធានការបណ្ដោះអាសន្ន ពន្យាបន្តការឃាត់ទុកទំនិញកុំឲ្យចរាចរនោះទំនិញឃាត់ទុកត្រូវលែងឲ្យមានចរាចរវិញ លុះត្រាតែបានបំពេញរាល់លក្ខខណ្ឌទាំងឡាយសម្រាប់ការនាំចូល ឬការនាំចេញ។ ក្នុងករណីសមស្រប ក្នុងរយៈពេលនេះអាចបន្ត១០ថ្ងៃបន្ថែមទៀត។

ប្រសិនបើបណ្ដឹងរបស់អ្នកប្ដឹងត្រូវបានរកឃើញថា ជាបណ្ដឹងគ្មានមូលហេតុត្រឹមត្រូវអ្នកប្ដឹងត្រូវតែជួសជុលការខូចខាតបណ្ដាលមកពីការឃាត់ទុកទំនិញ។ កិច្ចព្រមព្រៀងTRIPS ក៏អនុញ្ញាតឲ្យធ្វើដូច្នេះដោយចែងថា អាជ្ញាធរមានសមត្ថកិច្ចមាននីតិសម្បទាក្នុងការបញ្ជាឲ្យអ្នកប្ដឹងបង់សំណងឲ្យអ្នកនាំចូលឲ្យអ្នកទទួលបញ្ញើទំនិញ និងម្ចាស់ទំនិញដើម្បីជួសជុលរាល់ការខូចខាតដែលបង្កឡើងដោយសារការឃាត់ទុកទំនិញដោយអយុត្តិធម៌ ឬដោយសារការឃាត់ទំនិញពុំឲ្យចរាចរ[51]។

ប្រសិនបើអ្នកប្ដឹងបានផ្ដួចផ្ដើមឲ្យមានចំណាត់ការដល់អង្គសេចក្ដីនោះ ចុងក្រោយចម្លើយអាចស្នើសុំសម្រេចថា តើវិធាននេះត្រូវតម្កល់ កែតម្រូវ ឬលុបចោល។ ហេតុនេះការលើកលែងវិធានការឃាត់ទុក ក៏អាចសម្រេចដល់តុលាការបានដែរ។

### ៣.២.៤. វិធានការតាមផ្លូវតុលាការ

ការដាក់ពាក្យបណ្ដឹងរបស់ម្ចាស់កម្មសិទ្ធិ ដែលបានចុះបញ្ជីនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្មអាចដាក់ពាក្យនៅភ្នាក់ងារគយ ឬអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការក៏បាន។ ពាក្យបណ្ដឹងត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវមានឯកសារយោងដែលពាក់ព័ន្ធដូចជាវិញ្ញាបនបត្រដែលចុះបញ្ជី សេចក្ដីថ្លែងពីមូលហេតុនៃការប្ដឹង និងជាពិសេសភស្តុតាងដំបូងដែលបង្ហាញថាទំនិញនេះពាក់ម៉ាកក្លែងក្លាយមែន រួមទាំងការរៀបចំយ៉ាងល្អិតល្អន់ពីទំនិញ ដែលម៉ាករបស់វាត្រូវបានប្រើប្រាស់ក៏ដូចជាគំរូនៃផលិតផលពិតប្រាកដ និងសំណូមពរឈ្មោះ អាសយដ្ឋានរបស់អ្នកប្ដឹង ឬតាមរយៈតំណាងរបស់គេ ដែលត្រូវរៀបរាប់ឲ្យបានសព្វគ្រប់ តាមការកំណត់លិខិតអនុញ្ញាត

[51] មាត្រា៥៥ និងមាត្រា៥៦ នៃកិច្ចព្រមព្រៀង TRIPS

ពីម្ចាស់ម៉ាកដែលបានចុះបញ្ជី ប្រសិនបើពាក្យបណ្តឹងនោះត្រូវបានប្រគល់សិទ្ធិឲ្យទៅអ្នកតំណាងជាចុងក្រោយ ត្រូវបង់កម្រៃរដ្ឋបាលតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក្នុងរយៈពេល១០ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលនូវពាក្យបណ្តឹងរដ្ឋបាលគយ និងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចត្រូវជូនដំណឹងទៅអ្នកប្តឹងថា ពាក្យបណ្តឹងរបស់ខ្លួនត្រូវបានទទួលស្គាល់ត្រឹមត្រូវ ឬបដិសេធ ឬរក្សាទុកសម្រាប់ពិចារណានៅពេលក្រោយ។

រដ្ឋបាលគយ និងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ច ដែលតំណាត់ដោយតុលាការមានសិទ្ធិស្នើឲ្យអ្នកប្តឹងបង់ប្រាក់ធានា ឬតម្រូវឲ្យមានការធានាដែលមានតម្លៃស្មើ និងប្រាក់កក់គ្រប់គ្រាន់សម្រាប់ការពារអ្នកនាំចូល អ្នកទទួល អ្នកនាំចេញ ឬម្ចាស់ទំនិញ និងអាជ្ញាធរមានសមត្ថកិច្ច។ ប្រាក់ធានា ឬការធានាដែលមានតម្លៃស្មើ និងប្រាក់កកនេះត្រូវបានកំណត់តាមរបៀប និងបែបបទមួយដែលមិនតម្រូវឲ្យរារាំងដល់ការអនុវត្តនីតិវិធីនេះដោយមិនសមហេតុផល។

ក្នុងពេលយល់ព្រមតាមពាក្យបណ្តឹងដូចបានរៀបរាប់ខាងលើ រដ្ឋបាលគយ និងរដ្ឋាករ ត្រូវព្យួរទុកនូវការធ្វើបែបបទទំនិញ ដែលទាក់ទងទៅនិងពាក្យបណ្តឹង។ ការព្យួរទុកនេះត្រូវនៅជាធរមានក្នុងរយៈពេលដំបូង និងក្នុងរយៈពេលដែលមានការពន្យាមិនលើសពី១០ថ្ងៃ នៃថ្ងៃធ្វើការ។

រដ្ឋបាលគយ និងរដ្ឋាករត្រូវជូនព័ត៌មានភ្លាមទៅអ្នកនាំចូល និងអ្នកប្តឹងអំពីការព្យួរទុកនូវការធ្វើបែបទបទំនិញហើយ ត្រូវបញ្ជាក់ពីមូលហេតុនៃការព្យួរនេះផង។ រដ្ឋបាលគយ និងរដ្ឋាករ បានទទួលនូវព័ត៌មានថា ចំណាត់ការដែលបាននាំដល់ការសម្រេចនូវអង្គសេចក្តីនៃករណីនេះ មិនត្រូវបានគេផ្តួចផ្តើមដោយភាគីម្ខាងផ្សេងទៀតក្រៅពីចុងចម្លើយ ឬអាជ្ញាធរដែលប្រគល់សិទ្ធិត្រឹមត្រូវ មិនបានអនុវត្តវិធានការបណ្តោះអាសន្ន ដើម្បីពន្យាពេលនៃការលែងទំនិញទេ គឺទំនិញនោះនិងដោះលែងតែក្នុងករណីដែលមានលក្ខខណ្ឌផ្សេងទៀតសម្រាប់ការនាំចូល ឬនាំចេញត្រូវបានគេគោរព។ ក្នុងករណីសមស្របរយៈពេលនេះត្រូវបានពន្យា១០ថ្ងៃទៀត នៃថ្ងៃធ្វើការ។

ប្រសិនបើតំណាក់កាលនាំឲ្យមានការសម្រេចដល់អង្គសេចក្តី នៃករណីត្រូវផ្តួចផ្តើមឡើងនោះការពិនិត្យឡើងវិញមានទាំងការធ្វើសវនការផងត្រូវបានរៀបចំឡើង តាមការស្នើសុំពីសំណាក់ចុងចម្លើយដើម្បីសម្រេចក្នុងរយៈពេលមួយសមស្របថាតើវិធាននេះត្រូវការតំកល់ កែតម្រូវ ឬលុបចោល។ អាជ្ញាធរមានសមត្ថកិច្ច ដែលពាក់ព័ន្ធ មានសិទ្ធិសម្រេចឲ្យអ្នកប្តឹងសងទៅអ្នកនាំចូល និងអ្នកទទួលទំនិញនូវសំណងខូចខាតរបស់គេ ដែលបណ្តាលមកពីការឃាត់ទំនិញនមិនត្រឹមត្រូវ។ ក្នុងករណីនេះ បើភាគីណាមួយមិនយល់ស្របតាមសេចក្តីសម្រេចទេភាគីនោះមានសិទ្ធិប្តឹងទៅតុលាការ។

រដ្ឋបាលគយ និងរដ្ឋាករ អាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀតអាចអនុញ្ញាតឲ្យម្ចាស់សិទ្ធិនាំចូល ឬអ្នកនាំចេញ ពិនិត្យទំនិញដែលបានព្យួរទុកតាមបែបបទ និងយកនូវគំរូដើម្បីសាកល្បង និងវិភាគ

ក្នុងគោលបំណងដើម្បីបញ្ជាក់ឲ្យដឹង ថាទំនិញនោះពាក់ម៉ាកក្លែងក្លាយ រដ្ឋបាលគយ និងអាជ្ញាធរជូនព័ត៌មានទៅម្ចាស់សិទ្ធិ និងអាសយដ្ឋាននៃអ្នកនាំចេញ អ្នកនាំចូល អ្នកទទួល និងបរិមាណទំនិញ ដោយមិនឲ្យប៉ះពាល់ការការពារនូវព័ត៌មានរបស់រដ្ឋបាលគយ និងរដ្ឋាករ ឬ អាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត ដែលអាចផ្តល់ទៅម្ចាស់សិទ្ធិនូវឯកសារចម្លង នៃទំនិញទាំងអស់នោះឬពត៌មានដែលមាន ឬឯកសារដែលទាក់ទងនឹងការនាំចេញនាំចូលទំនិញប្រហាក់ប្រហែលពីមុន ដោយអ្នកនាំចូល ឬនាំចេញដដែលនោះតាមសំណូមពររបស់ម្ចាស់សិទ្ធិ។

**៣.២.៥. អង្គភាពគ្រប់គ្រងសិទ្ធិរួម**

ការអនុវត្តន៍សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មិនមែនជារឿងរបស់កម្ពុជាតែម្នាក់ឯងនោះទេ ប៉ុន្តែជាចរន្តរបស់សកលលោក។ មកទល់បច្ចុប្បន្ន តាមរបាយការណ៍មានជាង១០០ប្រទេសនៅលើពិភពលោក បាននឹងកំពុងដំណើរការអនុវត្តសិទ្ធិនេះតាមរយៈស្ថាប័នកណ្តាលមួយហៅថា (Collective Management Organization(CMO) ដែលមានទម្រង់ខុសគ្នា ខ្លះជាក្រុមហ៊ុន និងខ្លះទៀតជាស្ថាប័ន។ ប៉ុន្តែនៅកម្ពុជា ត្រូវបានហៅឈ្មោះថា "អង្គភាពគ្រប់គ្រងសិទ្ធិរួម"។

តាមនិយមន័យ CMO គឺជាអង្គភាពចំណុះក្រោមច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលដែលបង្កើតឡើងដោយអ្នកនិពន្ធ ឬម្ចាស់សិទ្ធិមានសញ្ជាតិខ្មែរ។

អង្គភាពនេះមានមុខងារ តួនាទីកាតព្វកិច្ចការពារ និងគ្រប់គ្រងសិទ្ធិបេតិកភណ្ឌ និងសិទ្ធិសីលធម៌ជំនួសមុខឲ្យសមាជិកខ្លួនចំពោះមុខច្បាប់។ ភារកិច្ចនៃអង្គភាពនេះមានជាអាទិ៍[52]៖

- ផ្តល់កិច្ចសន្យាអាជ្ញាប័ណ្ណឲ្យប្រើប្រាស់ស្នាដៃ
- ប្រមូលលាភការពីទីតាំងធ្វើអាជីវកម្មលើស្នាដៃសមាជិកខ្លួន និងបែងចែកលាភការជូនសមាជិកខ្លួនតាមលក្ខន្តិកៈរបស់អង្គភាព
- ដោះស្រាយវិវាទដែលទាក់ទងលើការប្រើប្រាស់ស្នាដៃ
- ការពារស្នាដៃរបស់សមាជិកខ្លួន
- ការធ្វើតារាងដែលកំណត់អត្រាតម្លៃនៃការប្រើប្រាស់ស្នាដៃ ដែលទទួលស្គាល់ដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ការធ្វើបញ្ជីគណនេយ្យប្រកបដោយតម្លាភាព
- បង្កើតនីតិវិធី និងយន្តការដើម្បីគ្រប់គ្រង និងតាមដានការប្រើប្រាស់ស្នាដៃ
- ដឹកនាំការងាររដ្ឋបាលប្រចាំថ្ងៃតាមជំនាញនីមួយៗរបស់អង្គភាព

[52] ប្រការ ៤ ប្រកាសស្តីពីការគ្រប់គ្រងសិទ្ធិរួមនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ លេខ.១១២ ប្រ.ក

- បង្កើតលក្ខន្តិកៈសម្រាប់អង្គភាពឲ្យសមស្របតាមច្បាប់ និងបទដ្ឋានគតិយុត្តនានានៃព្រះរាជាណាចក្រកម្ពុជា។

រាល់ការធ្វើអាជីវកម្មលើស្នាដៃរបស់សមាជិកខ្លួននៅឯបរទេស អង្គភាពគ្រប់គ្រងសិទ្ធិរួមត្រូវសហការជាមួយអង្គភាពគ្រប់គ្រងសិទ្ធិរួម ឬអង្គភាពដែលមានប្រភពប្រហាក់ប្រហែលនៅបរទេស ដើម្បីប្រមូល បែងចែកលាភការ និងការពារផលប្រយោជន៍ផ្សេងៗទៀតជូនសមាជិករបស់ខ្លួន។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទ សិទ្ធិអ្នកនិពន្ធ-ការវិវាទសិទ្ធិ និងយន្តការដោះស្រាយការរំលោភសិទ្ធិ យើងឃើញថាវាពិតជាមានសារៈសំខាន់ណាស់ចំពោះប្រយោជន៍ខាងវប្បធម៌ និងសេដ្ឋកិច្ច។ ជាការពិតយើងមិនអាចបំភ្លេចបានទេចំពោះសិទ្ធិអ្នកនិពន្ធ ព្រោះសិទ្ធិនេះទាក់ទងជាមួយនឹងវប្បធម៌របស់ប្រទេសមួយ។ គ្រប់ប្រទេសកំពុងអភិវឌ្ឍន៍ទាំងអស់ ត្រូវបានផ្សាភ្ជាប់ជាមួយវិចិត្រករយ៉ាងខ្លាំង ព្រោះស្នាដៃថ្មីៗត្រូវបានបង្កើតឡើងជានិច្ច។ ប្រសិនបើគ្មានការកាពារសិទ្ធិអ្នកនិពន្ធនោះទេ វិស័យសិល្បៈត្រូវបានគេលួច ជាងនេះទៅទៀតអ្នកនិពន្ធ ឬម្ចាស់សិទ្ធិមិនអាចរកប្រាក់ចំណេញពីកិច្ចខិតខំប្រឹងប្រែង ក្នុងការបង្កើតនូវស្នាដៃរបស់ខ្លួនបានឡើយ។ បច្ចុប្បន្ននេះស្នាដៃអក្សរសាស្ត្រ សិល្បៈ វប្បធម៌ សហគមសិល្បៈ ព័ត៌មានឧស្សាហកម្មវប្បធម៌ ឬឧស្សាហកម្មនៃកម្មវិធីកុំព្យូទ័រ មានភាពទូលំទូលាយជាងមុន។

ច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធប្រហាក់ប្រហែល របស់ព្រះរាជាណាចក្រកម្ពុជា ត្រូវបានចូលជាធរមាននៅឆ្នាំ២០០៣ ដែលស្របតាមកិច្ចព្រមព្រៀង TRIPS និងច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលអន្តរជាតិ។ ច្បាប់នេះ មានគោលបំណងធានាការគោរពសិទ្ធិអ្នកនិពន្ធ និងការពារនូវផលិតផលវប្បធម៌ ជាស្នាដៃនិពន្ធ អ្នកសម្តែង ផលិតករហ្វូណូក្រាម និងអង្គភាពទូរផ្សាយជាដើម សំដៅធានាដល់ការធ្វើអាជីវកម្មមួយត្រឹមត្រូវ ស្របច្បាប់លើផលិតផលវប្បធម៌ទាំងនោះដើម្បីរួមចំណែកអភិវឌ្ឍន៍វិស័យវប្បធម៌។ ស្នាដៃដែលត្រូវបានទទួលការការពារ គឺជាស្នាដៃដែលកើតចេញពីគំនិត ប្រាជ្ញា របស់អ្នកនិពន្ធផ្ទាល់ មានទម្រង់ជាក់លាក់ និងមិនមែនជាគំនិតស្រមើស្រម៉ៃ។ ស្នាដៃទាំងនោះមានដូចជា ផលិតផលខាងវិស័យអក្សរសាស្ត្រ វិទ្យាសាស្ត្រ សិល្បៈ តូរ្យតន្ត្រី ហ្វូណូក្រាមជាដើម។ អ្នកនិពន្ធទទួលបានសិទ្ធិផ្តាច់មុខពីរ គឺសិទ្ធិបេតិកភណ្ឌ និងសិទ្ធិសីលធម៌។ ខណៈដែលសិទ្ធិបេតិកភណ្ឌអាចផ្ទេរ ជួល លក់ ឬធ្វើអាជីវកម្មដើម្បីរកប្រាក់ចំណេញបាន ចំណែកឯសិទ្ធិសីលធម៌ពុំត្រូវបានអនុញ្ញាតឲ្យធ្វើដូច្នោះឡើយ ព្រោះសិទ្ធិនេះគឺជាសិទ្ធិអចិន្ត្រៃយ៍របស់អ្នកនិពន្ធនឹងមិនមានអាជ្ញាយុកាល ប៉ុន្តែនៅពេលដែលអ្នកនិពន្ធទទួលមរណៈភាព សិទ្ធិនេះអាចផ្ទេរទៅឲ្យទាយាទរបស់អ្នកនិពន្ធបាន ឬផ្ទេរឲ្យទៅតតីយជនបានតាមរយៈមតកសាសន៍។ ច្បាប់សិទ្ធិអ្នកនិពន្ធ គឺជាច្បាប់គោលក្នុងការប្រើប្រាស់ដើម្បីដោះស្រាយរាល់អំពើរំលោភសិទ្ធិអ្នកនិពន្ធ។ រីឯនីតិវិធីក្នុងតុលាការត្រូវបានដោះស្រាយដោយផ្អែកលើ នីតិរដ្ឋប្បវេណី និងក្រមព្រហ្មទណ្ឌ។

ការស្រាវជ្រាវក៏បានរកឃើញផងដែរថាការលួចថតចម្លង គឺជាចំនុចដ៏រសើបមួយក្នុងទម្រង់នៃការរំលោភសិទ្ធិអ្នកនិពន្ធ ព្រោះនៅពេលដែលស្នាដៃស្នាដៃថ្មីមួយត្រូវបានបញ្ចេញលក់លើទីផ្សារត្រូវបានគេលួចចម្លងភ្លាម ដែលជាហេតុធ្វើឲ្យបាត់បង់ចំណូលនឹងបង្កឲ្យមានការបាក់ទឹកចិត្តជាខ្លាំង

ពីសំណាក់អ្នកបង្កើតស្នាដៃ។ ទង្វើនេះបានជះឥទ្ធិពលអាក្រក់យ៉ាងខ្លាំងទៅលើវប្បធម៌ដ៏ស្រស់ស្អាតនៃប្រទេសយើង។

ដើម្បីជួយលើកកម្ពស់ សិទ្ធិអ្នកនិពន្ធ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក៏បានស្នើឲ្យបង្កើតអង្គភាពគ្រប់គ្រងសិទ្ធិរួម។ វាជាអង្គភាពចំណុះឲ្យក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមានមុខងារ តួនាទី កាតព្វកិច្ចការពារ និងគ្រប់គ្រង សិទ្ធិបេតិកភណ្ឌ សិទ្ធិសីលធម៌ជំនួសមុខឲ្យអ្នកនិពន្ធ ឬម្ចាស់សិទ្ធិទាំងឡាយដែលជាសមាជិកខ្លួនចំពោះមុខច្បាប់ នៅពេលមានការរំលោភពានសិទ្ធិកើតឡើង។

# អនុសាសន៍

# អនុសាសន៍

តាមរយៈការបកស្រាយខាងលើ យើងឃើញកម្ពុជាក៏ជាប្រទេសមួយដែលមានការយកចិត្តទុកដាក់លើវិស័យអ្នកនិពន្ធផងដែរ ប៉ុន្តែការអនុវត្តច្បាប់សិទ្ធិអ្នកនិពន្ធនេះនៅមានកម្រិតនៅឡើយ។ ដូច្នេះ ដើម្បីអោយវិស័យអ្នកនិពន្ធកាន់តែមានភាពប្រសើរឡើង ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងស្ថាប័នដែលជាប់ពាក់ពន្ធទាំងអស់គួរតែ៖

- ធ្វើការពង្រឹង និងបង្កើតបន្ថែមនូវបញ្ញត្តិក្នុងការបំពេញនូវភាពខ្វះចន្លោះដែលតែងតែកើតមានឡើងនៅក្នុងសង្គមខ្មែរបច្ចុប្បន្នក្រោមទម្រង់ជាការរំលោភសិទ្ធិដូចជា ការប្រើប្រាស់ការចម្លងទាំងស្រុង ឬដោយផ្នែក ការផ្សព្វផ្សាយទាំងស្រុង ឬដោយផ្នែកដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬម្ចាស់សិទ្ធិ។
- អង្គភាពគ្រប់គ្រងសិទ្ធិរួមដែលចំណុះឲ្យក្រសួងវប្បធម៌ និងវិចិត្រសិល្បៈគួរពង្រឹង និងពង្រីកវិសាលភាពក្នុងការទាក់ទាញអ្នកនិពន្ធផ្សេងទៀតដែលមិនទាន់ចូលជាសមាជិក ព្រមទាំងចូលរួមសហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈដើម្បីការពារសិទ្ធិអ្នកនិពន្ធផ្តល់ផលប្រយោជន៍ និងស្វែងរកយុត្តិធម៌ដល់ជនរងគ្រោះពីការរំលោភបំពានសិទ្ធិរបស់ពួកគេ។
- គ្រប់ក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធទៅនឹងសិទ្ធិអ្នកនិពន្ធ និងកម្មសិទ្ធិបញ្ញា គួរតែស្ថិតនៅក្រោមការគ្រប់គ្រងតែមួយរួមគ្នាដើម្បីបង្កើននូវប្រសិទ្ធិភាពការងារ។
- លើកកម្ពស់ស្នាដៃនិពន្ធក្នុងស្រុក ព្រោះវាជាលទ្ធផលដែលកើតចេញពីគំនិតប្រាជ្ញារបស់អ្នកនិពន្ធខ្មែរ។
- ជុំវិញបញ្ហានេះដែរ រដ្ឋាភិបាលក៏ត្រូវមានវិធានការឲ្យបានឆាប់រហ័សក្នុងផ្តល់ចំណេះដឹងផ្នែកកម្មសិទ្ធិបញ្ញានេះទៅដល់សាធារណៈជនទូទៅអោយបានជ្រាប ដើម្បីចៀសវាងការលួចចម្លងទាំងដុលទៅលើស្នាដៃរបស់អ្នកនិពន្ធ ព្រមទាំងជំរុញឲ្យមានការបង្កើតស្នាដៃថ្មីៗ។ បន្ថែមពីលើនេះរដ្ឋាភិបាលក៏ត្រូវធ្វើការរឹតបន្តឹងការអនុវត្ត ច្បាប់សិទ្ធិអ្នកនិពន្ធខាងលើដើម្បីផ្តល់ឲ្យវិនិយោគិននូវទំនុកចិត្តក្នុងការហក់ចូលមកវិនិយោគ ក្នុងវិស័យឧស្សាហកម្មវប្បធម៌នាពេលខាងមុខ។
- ជាពិសេសក្នុងនាមជាយុវជនជំនាន់ក្រោយ ដែលមានការយល់ដឹងទាក់ទងនឹងសិទ្ធិអ្នកនិពន្ធដាច់ខាតមិនត្រូវជួយ ឬបន្តគាំទ្រនូវរាល់សកម្មភាពរំលោភសិទ្ធិអ្នកនិពន្ធគ្រប់រូបភាពដូចជាលួចថតចម្លងខុសច្បាប់ ការលួចយកគំនិតរបស់អ្នកដទៃមកធ្វើជារបស់ខ្លួន ឬការប្រើប្រាស់ផលិតផល ដែលជាស្នាដៃអ្នកនិពន្ធដោយគ្មានការអនុញ្ញាពីម្ចាស់សិទ្ធិឡើយ។

# ឯកសារពិគ្រោះ

# ឯកសារពិគ្រោះ


**ក. លិខិតបទដ្ឋានគតិយុត្ត**

១. ច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលឆ្នាំ២០០៣

២. ប្រកាសលេខ ១១២ ប្រ.ក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦

៣. ប្រកាសលេខ ៦០ ប្រ.ក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៣

**ខ. សៀវភៅ**

១. **ទេព សុខ** នីតិកម្មសិទ្ធិបញ្ញា ឆ្នាំ២០១៧-២០១៨ ភ្នំពេញ

២. **នី វិចិត្រ** នីតិកម្មសិទ្ធិបញ្ញាកម្ពុជា ឆ្នាំ២០១៣ ភ្នំពេញ

៣. **តាម៉ុតស៊ូ ហ្វូហ្ស៊ីយមី** សិទ្ធិអ្នកនិពន្ធអ្នកស្រុកអាស៊ី បោះពុម្ពផ្សាយជាភាសាខ្មែរលើកទី១ ឆ្នាំ២០០៩ ភ្នំពេញ

៤. កម្រងច្បាប់ពាណិជ្ជកម្ម និង ច្បាប់កម្មសិទ្ធិបញ្ញាភាគ១ ភ្នំពេញ

៥. **ឥន យឿន** និង **អ៊ុក វណ្ណារ័ត្ន** ឯកសារនីតិកម្មសិទ្ធិបញ្ញា ឆ្នាំ២០១៣ ភ្នំពេញ

៦. **ភាន់ សុទ្ធម៉ូលីន** នីតិកម្មសិទ្ធិបញ្ញា ឆ្នាំ២០០៩ ភ្នំពេញ

៧. **លឹម យុស្ស** សេចក្តីផ្តើមនៃការសិក្សានីតិកម្មសិទ្ធិបញ្ញា ឆ្នាំ២០១៣ ភ្នំពេញ

**គ. គេហទំព័រ**

http://www.cambodiaip.gov.kh (25 April 2019)

http://www.service.gov.kh/ministry/38 (25 April 2019)

http://www.mcfa.gov.kh (25 April 2019)

# ឧបសម្ព័ន្ធ

# តារាងឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ១

១. ច្បាប់រដ្ឋធម្មនុញ្ញ

២. ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

៣. ច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលឆ្នាំ២០០៣

## ឧបសម្ព័ន្ធ២

៤. ប្រកាសលេខ ១១២ ប្រ.ក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦

៥. ប្រកាសលេខ ៦០ ប្រ.ក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៣

# ឧបសម្ព័ន្ធ១

អគ្គលេខាធិការដ្ឋាន (ព្រឹទ្ធសភា)
ចូល
លេខ ៧០៥
ថ្ងៃទី ២៥ ០៣ ម៉ោង ១៥:៣០
បញ្ជូនទៅ

# ច្បាប់

# ស្ដីពី

# សិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល

# ព្រះរាជក្រម

នស/រកម/០៣០៣/០០៨

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៣ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាល ទី ២ ហើយដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ នាសម័យប្រជុំពេញអង្គលើកទី ៨ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងធានាការគោរពសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រ-ហែល និងការពារនូវផលិតផលវប្បធម៌ជាស្នាដៃអ្នកនិពន្ធ អ្នកសម្តែង ផលិតករ ហ្វូណូ-ក្រាមនិងអង្គភាពឃ្សាយ សំដៅធានាការធ្វើអាជីវកម្មមួយត្រឹមត្រូវ ស្របច្បាប់លើផលិតផលវប្បធម៌ទាំងនោះ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍វិស័យវប្បធម៌ ។

**មាត្រា ២.-**

ក្នុងន័យនៃច្បាប់នេះ ពាក្យមួយចំនួនដូចខាងក្រោមមានអត្ថន័យដូចតទៅ :

**ក-ស្នាដៃ** ជាផលិតផលខាងវិស័យអក្សរសាស្ត្រ វិទ្យាសាស្ត្រ សិល្បៈ ឬតូរ្យតន្ត្រី កើតចេញពីការច្នៃប្រឌិត បង្កើតឡើងដោយគំនិតប្រាជ្ញា ឬមនោសញ្ចេតនា ។

**ខ-អ្នកនិពន្ធ** ជាជនដែលបង្កើតបានស្នាដៃ ។

**គ-ការសម្តែង** ជាការបញ្ចេញស្នាដៃលើឆាកដូចជារាំ ប្រគំតន្ត្រី ច្រៀង ឬបង្ហាញតាមមធ្យោបាយនិងវិធីផ្សេងៗទៀតនូវស្នាដៃសិល្បៈប្រពៃណី ទំនៀមទម្លាប់ អក្សរសាស្ត្រ ការអប់រំឬវិទ្យាសាស្ត្រ ។

**ឃ-ការសូត្រ** ជាការបញ្ចេញសម្លេងដោយការនិយាយ ការអាននិងការសូត្រនូវស្នាដៃផ្សេងៗ ។

**ង-អ្នកសម្តែង** ជាសិល្បករ អ្នករបាំ តន្ត្រីករ អ្នកចម្រៀង ឬជនដែលធ្វើការសម្តែង ។

**ច-ប្រព័ន្ធទិន្នន័យ** ជាសំណុំព័ត៌មាន អត្ថបទ លេខ ឌីយ៉ាក្រាម ដែលបង្កើតនិងស្រាវជ្រាវដោយប្រព័ន្ធកុំព្យូទ័រ ។

**ឆ-ស្នាដៃសោតទស្សន៍** ជាស្នាដៃបង្កើតឡើងដោយមានរូបភាពតគ្នាជាឈុតៗភ្ជាប់គ្នា បង្កើតបានជាចលនាអាចឱ្យមើលឃើញបាន ទោះបីមានឬពុំមានបញ្ចូលសម្លេង ហើយបើមានបញ្ចូលសម្លេងគឺអាចស្តាប់ឮសូរសម្លេងបាន ។

**ជ-ការផ្សាយ** ជាការផ្សាយសម្លេង រូបភាព ឯកសារ ឬសារនានាគ្រប់ប្រ-

ភេទតាមវិទ្យុ ទូរទស្សន៍ ទូរទស្សន៍ខ្សែកាបឬផ្កាយរណប ។

**ឈ-ការផ្សព្វផ្សាយជាសាធារណៈ** ជាការផ្សាយតាមខ្សែ ឬគ្មានខ្សែក្រៅវង្ង់គ្រួសារនូវរូបភាព ឬសម្លេង ឬរូបភាពជាមួយសម្លេងនៃស្នាដៃណាមួយ ដែលអាចឱ្យសាធារណជនទទួលបាននៅទីកន្លែងដើម ឬទីកន្លែងដទៃទៀត ដោយមិនគិតថា ជននោះទទួលឬមិនទទួលនូវរូបភាព ឬសម្លេងនោះ ក្នុងពេលនិងទីកន្លែងជាមួយគ្នា ឬក្នុងពេលនិងទីកន្លែងខុសគ្នាតាមការជ្រើសរើសផ្ទាល់ខ្លួនរបស់គេ ។

**ញ-ហ្វូណូក្រាម** ជាវត្ថុដែលបានថតបញ្ចូលសម្លេងនៃការសម្តែង ឬសម្លេងផ្សេងៗទៀត ឬនិមិត្តសញ្ញានៃសម្លេង ក្រៅពីទម្រង់នៃការថតបញ្ចូលជាខ្សែភាពយន្ត ឬស្នាដៃសោតទស្សន៍ផ្សេងៗទៀត ។

**ដ-ផលិតករហ្វូណូក្រាម** ជាជនដែលផលិតហ្វូណូក្រាម ដូចមានចែងនៅក្នុងចំណុច ញ ។

**ឋ-កម្មវិធីកុំព្យូទ័រ** ជាសំណុំនៃសេចក្តីណែនាំដែលធ្វើឡើងតាមអក្សរ ឬលេខកូដ ឬគំនូសបំព្រួញ ឬតាមទម្រង់ណាមួយជាហេតុធ្វើឱ្យគេបំពេញបាន ឬទទួលបាននូវកិច្ចការ ឬលទ្ធផលពិសេសណាមួយតាមមធ្យោបាយកុំព្យូទ័រ ឬតាមវិធីសាស្ត្រអេឡិចត្រូនិច ដើម្បីបំពេញកិច្ចការពត៌មានបាន កាលណាកម្មវិធីនោះត្រូវបានបញ្ចូលក្នុងកុំព្យូទ័រ ។

**ឌ-ការផលិតឡើងវិញ** ជាការចម្លងទាំងស្រុង ឬភាគខ្លះនៃស្នាដៃ ឬហ្វូណូក្រាម បង្កើតជាផលិតផលចម្លងមួយច្បាប់ ឬច្រើនច្បាប់តាមមធ្យោបាយ ឬទម្រង់ណាមួយគិតបញ្ចូលទាំងស្នាដៃ ឬហ្វូណូក្រាមដែលរក្សាទុកជាអចិន្ត្រៃយ៍ ឬបណ្តោះអាសន្នតាមទម្រង់អេឡិចត្រូនិច ។

**ឍ-អង្គភាពទូរផ្សាយ** គឺស្ថានីយវិទ្យុ ទូរទស្សន៍ ទូរទស្សន៍ខ្សែកាប ឬផ្កាយរណប ។

**ណ-សិទ្ធិប្រហាក់ប្រហែល** ជាសិទ្ធិអ្នកសម្តែង សិទ្ធិផលិតករហ្វូណូក្រាម និងសិទ្ធិអង្គភាពទូរផ្សាយ ។

**មាត្រា ៣.-**

ស្នាដៃទាំងឡាយដែលត្រូវទទួលបានកិច្ចការពារពីច្បាប់នេះមានស្នាដៃអ្នកនិពន្ធ

ស្នាដៃអ្នកសម្តែង ហ្វូណូក្រាមនិងការផ្សាយតាមទូរផ្សាយ ។

**១-ស្នាដៃអ្នកនិពន្ធសំដៅ :**

ក-ស្នាដៃដែលបង្កើតឡើងដោយជនមានសញ្ជាតិខ្មែរ ឬជនដែលមានលំនៅក្នុងព្រះរាជាណាចក្រកម្ពុជារួមមាននីតិបុគ្គល ហើយត្រូវបានបង្កើតឡើងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងមានការិយាល័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ខ-ស្នាដៃដែលបានបោះពុម្ពផ្សាយលើកដំបូងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬស្នាដៃដែលបានបោះពុម្ពផ្សាយលើកដំបូងនៅបរទេស ហើយដែលត្រូវបានយកមកបោះពុម្ពផ្សាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងអំឡុង ៣០(សាមសិប)ថ្ងៃ ។

គ-ស្នាដៃសោតទស្សន៍ដែលផលិតករមានទីស្នាក់ការ ឬមានទីលំនៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ឃ-ស្នាដៃស្ថាបត្យកម្មដែលបានសាងសង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងស្នាដៃសិល្បៈផ្សេងៗទៀតដែលភ្ជាប់ទៅនឹងអាគារ ឬរចនាសម្ព័ន្ធផ្សេងទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ង-ស្នាដៃដែលព្រះរាជាណាចក្រកម្ពុជាមានកាតព្វកិច្ចការពារក្រោមសន្ធិសញ្ញាអន្តរជាតិ ។

**២-ស្នាដៃអ្នកសម្តែងសំដៅ :**

ក-ស្នាដៃរបស់អ្នកសម្តែងដែលមានសញ្ជាតិខ្មែរ ។

ខ-ស្នាដៃរបស់អ្នកសម្តែងដែលពុំមានសញ្ជាតិខ្មែរ តែការសម្តែងនោះ :

- បានប្រព្រឹត្តឡើងនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ឬ
- បានថតបញ្ចូលជាហ្វូណូក្រាមដែលស្ថិតក្រោមកិច្ចការពារនៃច្បាប់នេះ ឬ
- ពុំទាន់បានថតបញ្ចូលជាហ្វូណូក្រាម ប៉ុន្តែបានផ្សព្វផ្សាយតាមទូរ-ផ្សាយដែលស្ថិតក្រោមកិច្ចការពារនៃច្បាប់នេះ ។

**៣-ហ្វូណូក្រាមសំដៅ :**

ក-ហ្វូណូក្រាមរបស់ផលិតករមានសញ្ជាតិខ្មែរ ។

ខ-ហ្វូណូក្រាម ដែលបានថតបញ្ចូលសូរសម្លេងជាលើកដំបូងនៅក្នុង

ព្រះរាជាណាចក្រកម្ពុជា ។

គ-ហ្វូណូក្រាម ដែលបានថតផ្សាយលើកដំបូងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**៤-ការផ្សាយតាមទូរផ្សាយសំដៅ :**

ក-ការផ្សាយនៃអង្គភាពទូរផ្សាយដែលមានទីស្នាក់ការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ខ-ការផ្សាយចេញពីឧបករណ៍ផ្សាយដែលមានទីតាំងនៅក្នុងព្រះរាជណាចក្រកម្ពុជា ។

បទប្បញ្ញត្តិនៃច្បាប់នេះក៏ត្រូវអនុវត្តផងដែរ ចំពោះអ្នកសម្តែង ផលិតករហ្វូណូក្រាមនិងអង្គភាពទូរផ្សាយដែលអាចទទួលនូវកិច្ចការពារតាមសន្ធិសញ្ញាអន្តរជាតិ ឬកិច្ចព្រមព្រៀងអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជាភាគី ។

## ជំពូកទី ២
## សិទ្ធិអ្នកនិពន្ធ
### ផ្នែកទី ១
### ស្នាដៃ

**មាត្រា ៤.-**

ត្រូវចាត់ទុកថាជាស្នាដៃដើមគឺស្នាដៃទាំងឡាយដែលបង្កើតឡើងតាមគំនិតប្រាជ្ញាផ្ទាល់របស់អ្នកនិពន្ធនៃស្នាដៃនោះ ។

**មាត្រា ៥.-**

ស្នាដៃមួយទោះបីពុំទាន់ចប់សព្វគ្រប់ក្តី ឬពុំទាន់បានផ្សព្វផ្សាយជាសាធារណៈក្តី ស្នាដៃនោះត្រូវចាត់ទុកថាបានបង្កើតឡើងដោយចំណេះដឹងពិតប្រាកដតែមួយគត់ពីគំនិតប្រាជ្ញាអ្នកនិពន្ធ ។

**មាត្រា ៦.-**

ស្នាដៃសហការជាស្នាដៃដែលមានរូបវន្តបុគ្គលច្រើននាក់ចូលរួមសហការៈដើម្បី

បង្កើតស្នាដៃនោះ ។

ស្នាដៃបន្តជាស្នាដៃបង្កើតឡើងផ្អែកតាមស្នាដៃដើម តាមរយៈការបកប្រែ ការយកលំនាំតាមឬការសម្រួល ។

ស្នាដៃសមូហភាពគឺជាស្នាដៃបង្កើតឡើងដោយរូបវន្តបុគ្គលច្រើននាក់ តាមគំនិតផ្តួចផ្តើមរបស់រូបវន្តបុគ្គលម្នាក់ដែលបានធ្វើការបោះពុម្ពផ្សាយក្រោមការដឹកនាំនិងក្នុងនាមរបស់បុគ្គលនោះ ។

មាត្រា ៧.–

ស្នាដៃទាំងឡាយ យោងតាមមាត្រា ៣ ដែលត្រូវទទួលបានការការពារក្រោមច្បាប់នេះមាន :

ក-សៀវភៅអានគ្រប់ប្រភេទ ឬឯកសារផ្សេងៗទៀតស្តីពីអក្សរសាស្ត្រ សិល្បៈ វិទ្យាសាស្ត្រនិងការអប់រំ ។

ខ-អត្ថបទបាឋកថា សង្ក្ថា ធម្មទេសនា ការការពារខ្លួនដោយនិយាយ ឬដោយសរសេរនិងស្នាដៃផ្សេងៗទៀត ដែលមានប្រភេទដូចគ្នា ។

គ-ស្នាដៃនាដកម្ម ឬនាដកម្ម-តូរ្យតន្ត្រី ។

ឃ-ស្នាដៃរបាំសម័យ ឬយកលំនាំតាមស្នាដៃបុរាណ ឬប្រពៃណី ។

ង-ការសម្តែងសៀកនិងការសម្តែងកាយវិការ ។

ច-ការតែងបទភ្លេងដោយមាន ឬគ្មានទំនុកច្រៀង ។

ឆ-ស្នាដៃសោតទស្សន៍ ។

ជ-ស្នាដៃជាផ្ទាំងគំនូរ ផ្ទាំងចម្លាក់ រូបចម្លាក់ ឬស្នាដៃផ្សេងៗទៀតខាងសិល្បៈសូនរូបឬសិល្បៈអនុវត្ត ។

ឈ-ស្នាដៃថតរូបនិងស្នាដៃទាំងឡាយដែលសម្រេចបានដោយសារមានជំនួយបច្ចេកទេសដូចគ្នានឹងការថតរូប ។

ញ-ស្នាដៃស្ថាបត្យកម្ម ។

ដ-ផែនទី ប្លង់ គំនូសវាស ឬស្នាដៃស្តែងចេញជារូបដែលទាក់ទងនឹងភូមិសាស្ត្រ ឋានលេខា ឬវិទ្យាសាស្ត្រនានា ។

៦-កម្មវិធីកុំព្យូទ័រនិងគម្រោងឯកសារសមោធានដែលទាក់ទងទៅនឹងកម្ម-វិធីទាំងនោះ ។

៧-ផលិតផលផ្នែកសិប្បកម្ម តម្បាញ ឬម៉ូតសម្លៀកបំពាក់ផ្សេងៗ ។

មាត្រា ៨.-

ស្នាដៃបន្តដែលនៅក្នុងនោះមាន ការបកប្រែ ការយកលំនាំតាម ការសម្រួល ការកែច្នៃ ឬការកែលំអស្នាដៃផ្សេងទៀត ឬការចងក្រងជាប្រព័ន្ធទិន្នន័យ ទោះបីជាក្នុងម៉ាស៊ីនដែលអាចអានបាន ឬក៏ជាទម្រង់ផ្សេងទៀត ក៏ត្រូវទទួលបាននូវកិច្ចការពារពីច្បាប់នេះដែរ ។

កិច្ចការពារស្នាដៃណាមួយដែលមានចែងក្នុងវាក្យខ័ណ្ឌខាងលើ មិនធ្វើឱ្យបាត់បង់សិទ្ធិចំពោះកិច្ចការពារស្នាដៃដើមដែលត្រូវបានបញ្ចូល ឬប្រើប្រាស់សម្រាប់ការបង្កើតស្នាដៃថ្មី ។

មាត្រា ៩.-

ចំណងជើងនៃស្នាដៃណាមួយដែលបង្ហាញពីលក្ខណៈស្នូលនៃស្នាដៃដើម ចំណងជើងនោះត្រូវទទួលបាននូវកិច្ចការពារពីច្បាប់ដូចគ្នានឹងស្នាដៃនោះដែរ ។

ស្នាដៃមួយ ទោះបីលែងទទួលបាននូវកិច្ចការពារពីច្បាប់តាមមាត្រា ៣០ និង មាត្រា ៣១ នៃច្បាប់នេះក៏ដោយ ក៏គ្មានបុគ្គលណាម្នាក់មានសិទ្ធិប្រើប្រាស់ចំណងជើងនៃស្នាដៃនោះសម្រាប់ធ្វើជាចំណងជើងនៃស្នាដៃមួយផ្សេងទៀត ជាហេតុបង្កឱ្យមានការភ័ន្តច្រឡំ ។

មាត្រា ១០.-

ស្នាដៃដែលមិនស្ថិតនៅក្រោមការការពារនៃច្បាប់នេះមាន :

ក-រដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យនិងលិខិតបទដ្ឋានផ្លូវការនានា ។

ខ-ប្រកាស សេចក្តីសម្រេច លិខិតបញ្ជាក់ សារាចរណែនាំផ្សេងៗដែលចេញដោយអង្គការរដ្ឋ ។

គ-សេចក្តីសម្រេច សាលក្រមឬសាលដីកាផ្សេងៗរបស់តុលាការ ។

ឃ-អត្ថបទបកប្រែជាភាសាបរទេសនៃអត្ថបទក្នុងចំណុច ក ចំណុច ខ និង ចំណុច គ ខាងលើក្នុងមាត្រានេះ ។

ង-គំនិត នីតិវិធី ប្រព័ន្ធ របៀបប្រតិបត្តិការ ទស្សនៈ គោលការណ៍ ការរុករកឃើញឬទិន្នន័យសាមញ្ញ ទោះបីត្រូវបានផ្សព្វផ្សាយ អត្ថាធិប្បាយ ពន្យល់ឬមានក្នុងស្នាដៃណាមួយក៏ដោយ ។

## ផ្នែកទី ២

## អ្នកនិពន្ធ

**មាត្រា ១១.-**

ឋានៈជាអ្នកនិពន្ធគឺជាឋានៈរបស់បុគ្គលម្នាក់ ឬច្រើននាក់ជាម្ចាស់កម្មសិទ្ធិលើស្នាដៃដែលសាមីខ្លួនបានបង្កើតឡើង ហើយស្នាដៃនោះត្រូវបានផ្សព្វផ្សាយជាសាធារណៈលើកលែងតែមានភស្តុតាងផ្ទុយ ។

**មាត្រា ១២.-**

សហអ្នកនិពន្ធគឺជាម្ចាស់កម្មសិទ្ធិលើស្នាដៃសហការ ។ សហអ្នកនិពន្ធត្រូវតែប្រើសិទ្ធិរបស់ខ្លួនយោងតាមការឯកភាពជាឯកច្ឆន្ទនិងជាលាយលក្ខណ៍អក្សរ ។ នៅពេលមិនឯកភាពគ្នាត្រូវធ្វើពាក្យប្តឹងទៅតុលាការ ។

**មាត្រា ១៣.-**

រូបវន្តបុគ្គលឬនីតិបុគ្គលជាម្ចាស់ស្នាដៃសមូហភាពដែលឈ្មោះបុគ្គលនោះត្រូវគេផ្សាយជាចំហក្នុងពេលធ្វើការផ្សព្វផ្សាយស្នាដៃ បុគ្គលនោះគឺជាអ្នកទទួលបាននូវសិទ្ធិអ្នកនិពន្ធ លើកលែងតែមានភស្តុតាងផ្ទុយ ។

**មាត្រា ១៤.-**

អ្នកនិពន្ធស្នាដៃ រហស្សនាម ឬអានាមិកជាអ្នកទទួលបានសិទ្ធិទាំងឡាយលើស្នាដៃនោះ ។

ដរាបណាអ្នកនិពន្ធនោះនៅតែពុំទាន់បង្ហាញឱ្យគេដឹងពីអត្តសញ្ញាណខ្លួន និងនៅពុំទាន់បង្ហាញភស្តុតាងដែលបញ្ជាក់ឱ្យដឹងពីឋានៈខ្លួន ដរាបនោះអ្នកនិពន្ធនៅតែត្រូវបានជំនួសមុខដោយអ្នកបោះពុម្ពឬអ្នកផ្សព្វផ្សាយលើកដំបូង ដែលនឹងត្រូវផ្តល់សិទ្ធិឱ្យអនុវត្តនិងការពារសិទ្ធិសីលធម៌និងសិទ្ធិបេតិកភណ្ឌរបស់អ្នកនិពន្ធ ។ អ្នកបោះពុម្ពផ្សាយ ឬអ្នកផ្សព្វផ្សាយលើកដំបូងត្រូវមានកិច្ចសន្យាបញ្ជាក់ពីអត្តសញ្ញាណរបស់អ្នកនិពន្ធ រហស្សនាម ឬអានាមិក ។

វាក្យខ័ណ្ឌទី ២ មិនអាចអនុវត្តបានឡើយ បើរហស្សនាមដែលអ្នកនិពន្ធបានជ្រើសរើសយកនោះត្រូវបានផ្សាយឈ្មោះអ្នកនិពន្ធពិតប្រាកដជាចំហ ។

## មាត្រា ១៥.-

រូបវន្តបុគ្គលម្នាក់ឬច្រើននាក់ដែលបានបង្កើតស្នាដៃសោតទស្សន៍តាមគំនិតប្រាជ្ញារបស់ខ្លួន រូបវន្តបុគ្គលនោះត្រូវបានទទួលឋានៈជាអ្នកនិពន្ធស្នាដៃសោតទស្សន៍ ។

លើកលែងតែមានភស្តុតាងផ្ទុយ សហអ្នកនិពន្ធនៃស្នាដៃសោតទស្សន៍មាន :

ក-សមិទ្ធិករ ។

ខ-អ្នកនិពន្ធសេណារីយ៉ូ ។

គ-អ្នកនិពន្ធដោយយកលំនាំតាម ។

ឃ-អ្នកនិពន្ធអត្ថបទនិយាយ ។

ង-អ្នកនិពន្ធបទភ្លេងមាន ឬគ្មានទំនុកច្រៀងដែលជាបទភ្លេងត្រូវបានបង្កើតឡើងជាពិសេសសម្រាប់តែជាប្រយោជន៍ស្នាដៃនោះ ។

ច-អ្នកនិពន្ធសិល្បៈគំនូរសម្រាប់ស្នាដៃគំនូរជីវចល ។

## មាត្រា ១៦.-

អ្នកនិពន្ធស្នាដៃគឺជាអ្នកមានសិទ្ធិធ្វើជាម្ចាស់លើសិទ្ធិសីលធម៌ និងសិទ្ធិបេតិកភណ្ឌ។ ក្នុងករណីដែលអ្នកនិពន្ធបានបង្កើតស្នាដៃដើម្បីជាប្រយោជន៍ឱ្យដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលជានិយោជកក្នុងក្របខ័ណ្ឌនៃកិច្ចសន្យាការងារ និងកិច្ចសន្យាការប្រើប្រាស់ស្នាដៃ សិទ្ធិបេតិកភណ្ឌលើស្នាដៃនោះត្រូវបានចាត់ទុកថាបានផ្ទេរជូននិយោជក លើកលែងតែមានបទប្បញ្ញត្តិផ្ទុយពីកិច្ចសន្យាទាំងនោះ ។

### មាត្រា ១៧.-

សមិទ្ធិករស្នាដៃសោតទស្សន៍មួយដែលមានការចូលរួមវិភាគទានពីសហអ្នកនិពន្ធបង្កើតស្នាដៃតាមកិច្ចសន្យាដោយមិនរាប់បញ្ចូលអ្នកនិពន្ធស្នាដៃភ្ជាប់តន្ត្រី សមិទ្ធិករនោះទទួលបាននូវសិទ្ធិបេតិកភណ្ឌរបស់សហអ្នកនិពន្ធ លើកលែងតែមានបទប្បញ្ញត្តិផ្ទុយពីកិច្ចសន្យា ។ ប៉ុន្តែសហអ្នកនិពន្ធនោះ នៅតែរក្សាសិទ្ធិបេតិកភណ្ឌរបស់គេបានតាមទំហំនៃការប្រើប្រាស់វិភាគទាន ក្នុងករណីការរួមវិភាគទាននោះបានប្រព្រឹត្តឡើងដាច់ដោយឡែកពីការបង្កើតស្នាដៃសោតទស្សន៍ ។

## ផ្នែកទី ៣
## សិទ្ធិអ្នកនិពន្ធ

### មាត្រា ១៨.-

អ្នកនិពន្ធស្នាដៃជាអ្នកទទួលបាននូវសិទ្ធិជាម្ចាស់កម្មសិទ្ធិផ្តាច់មុខលើស្នាដៃនោះ ហើយជាសិទ្ធិដែលជនគ្រប់រូបត្រូវតែទទួលស្គាល់ ។

សិទ្ធិនេះមានសិទ្ធិសីលធម៌និងសិទ្ធិបេតិកភណ្ឌ ។

### មាត្រា ១៩.-

សិទ្ធិសីលធម៌របស់អ្នកនិពន្ធគឺជាសិទ្ធិអចិន្ត្រៃយ៍ មិនអាចលក់ដូរបាន មិនអាចរឹបអូសបាននិងមិនអាចផុតអាជ្ញាយុកាល ។ សិទ្ធិនេះអាចត្រូវបានផ្ទេរទៅឱ្យទាយាទរបស់អ្នកនិពន្ធ ដោយមូលហេតុអ្នកនិពន្ធបានទទួលមរណភាពឬប្រគល់ជូនតតិយជនបាន ដោយយោងតាមបទប្បញ្ញត្តិមរតកសាសន៍ ។

ក្នុងករណីគ្មានអ្នកទទួលមរតក រដ្ឋដែលតំណាងដោយក្រសួងវប្បធម៌និងវិចិត្រសិល្បៈជាអ្នកគ្រប់គ្រងសិទ្ធិនោះ ។

### មាត្រា ២០.-

សិទ្ធិសីលធម៌របស់អ្នកនិពន្ធមានបីចំណុចដូចខាងក្រោម :

ក-អ្នកនិពន្ធមានសិទ្ធិផ្តាច់មុខក្នុងការសម្រេចពីរបៀបនិងពេលវេលានៃ

ការផ្សព្វផ្សាយស្នាដៃរបស់ខ្លួនជាសាធារណៈ ព្រមទាំងបែបបទគ្រប់គ្រងការផ្សព្វផ្សាយ ។

ខ-អ្នកនិពន្ធមានសិទ្ធិកំណត់ឱ្យគេទទួលស្គាល់ឈ្មោះ ឋានៈ និងស្នាដៃរបស់ខ្លួនសម្រាប់ទាក់ទងជាមួយសាធារណជន ។

គ-អ្នកនិពន្ធមានសិទ្ធិជំទាស់នូវគ្រប់រូបភាពនៃការបំផ្លើស ឬការកាត់ចោលខ្លឹមសារ ឬការកែប្រែខ្លឹមសារ ជាហេតុធ្វើឱ្យខូចកិត្តិយសឬកេរ្តិ៍ឈ្មោះខ្លួន ។

**មាត្រា ២១.–**

សិទ្ធិបេតិកភណ្ឌជាសិទ្ធិប្រកបអាជីវកម្មរបស់អ្នកនិពន្ធលើទ្រព្យជាស្នាដៃរបស់ខ្លួនតាមរយៈការផលិតឡើងវិញ ការផ្សព្វផ្សាយជាសាធារណៈនិងការបង្កើតស្នាដៃបន្ត ។

លើកលែងតែក្នុងករណីនៃបទប្បញ្ញត្តិចែងក្នុងមាត្រា ២៤ មាត្រា ២៥ មាត្រា ២៦ មាត្រា ២៧ មាត្រា ២៨ និងមាត្រា ២៩ នៃច្បាប់នេះ អ្នកនិពន្ធមានសិទ្ធិផ្តាច់មុខធ្វើដោយខ្លួនឯងឬអនុញ្ញាតឱ្យគេធ្វើកិច្ចការដូចតទៅ :

ក-ការបកប្រែជាភាសាបរទេសនូវស្នាដៃរបស់ខ្លួន ។

ខ-ការយកលំនាំតាមឬការកែសម្រួលផ្សេងៗទៀតនៃស្នាដៃ ។

គ-ការជួលស្នាដៃច្បាប់ដើម ឬច្បាប់ចម្លងស្នាដៃសោតទស្សន៍ ឬស្នាដៃថតបញ្ចូលជាហ្វូណូក្រាម កម្មវិធីកុំព្យូទ័រ ប្រព័ន្ធទិន្នន័យ ឬស្នាដៃតូរ្យតន្ត្រីជាអក្សរភ្លេង ។

ឃ-ការចែកចាយជាសាធារណៈតាមការលក់ ការជួល ឬតាមមធ្យោបាយផ្សេងទៀតនូវច្បាប់ដើម ឬច្បាប់ចម្លងដែលពុំទាន់បានលក់ ឬផ្ទេរកម្មសិទ្ធិ ។

ង-ការនាំចូលក្នុងប្រទេសនូវស្នាដៃចម្លងចេញពីស្នាដៃរបស់សាមីខ្លួនដែលជាអ្នកនិពន្ធ ។

ច-ការផលិតស្នាដៃឡើងវិញ ។

ឆ-ការសម្តែងស្នាដៃជាសាធារណៈ ។

ជ-ការបង្ហាញស្នាដៃជាសាធារណៈ ។

ឈ-ការផ្សាយស្នាដៃតាមប៉ុស្តិ៍ផ្សាយ ។

ញ-ការផ្សព្វផ្សាយស្នាដៃជាសាធារណៈតាមវិធីផ្សេងៗទៀត ។

សិទ្ធិដាក់ជួលដូចមានចែងក្នុងចំណុច គ នៃមាត្រានេះ មិនត្រូវអនុវត្តចំពោះការ

ផ្ដល់កម្មវិធីកុំព្យូទ័រឡើយ ក្នុងករណីដែលកម្មវិធីកុំព្យូទ័រនោះមិនមែនជាកម្មវត្ថុដ៏សំខាន់សម្រាប់ការដាក់ជួល ។

**មាត្រា ២២.-**

សិទ្ធិបេតិកភណ្ឌចំពោះកម្មវិធីកុំព្យូទ័រនិងឯកសារសមោធានដែលបង្កើតឡើងដោយនិយោជិតម្នាក់ឬច្រើននាក់ ក្នុងពេលបំពេញមុខនាទីឬក្នុងពេលធ្វើតាមសេចក្ដីបង្គាប់របស់និយោជក ជាកម្មសិទ្ធិរបស់និយោជក លើកលែងតែមានកិច្ចសន្យាចែងផ្ទុយពីនេះ ។

ចំពោះជនណាម្នាក់ដែលបានជួលបុគ្គលណាផ្សេងឱ្យបង្កើតកម្មវិធីកុំព្យូទ័រឱ្យខ្លួនដោយឆ្លងតាមកិច្ចសន្យាបញ្ជាទិញ ជននោះត្រូវបានទទួលសិទ្ធិបេតិកភណ្ឌ ។

## ផ្នែកទី ៤
## ការកម្រិតសិទ្ធិអ្នកនិពន្ធ

**មាត្រា ២៣.-**

រូបវន្តបុគ្គលណាម្នាក់នាំចូលនូវស្នាដៃមួយច្បាប់សម្រាប់សេចក្ដីត្រូវការផ្ទាល់ខ្លួនអាចប្រព្រឹត្តទៅបានដោយពុំចាំបាច់តម្រូវឱ្យមានការអនុញ្ញាតពីអ្នកនិពន្ធ ឬពីម្ចាស់សិទ្ធិលើស្នាដៃនោះឡើយ ។

**មាត្រា ២៤.-**

ការផលិតឡើងវិញចំនួនមួយច្បាប់ជាលក្ខណៈឯកជននូវស្នាដៃដែលបានបោះផ្សាយហើយសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួននឹងត្រូវអនុវត្តបាន ដោយពុំចាំបាច់មានការអនុញ្ញាតពីអ្នកនិពន្ធ ឬម្ចាស់កម្មសិទ្ធិឡើយ ។

ការអនុញ្ញាតដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើនៃមាត្រានេះមិនត្រូវយកមកអនុវត្តចំពោះការផលិតឡើងវិញនូវ :

ក-ស្នាដៃស្ថាបត្យកម្ម មានទម្រង់ជាអាគារ ឬសំណង់ផ្សេងៗ ។

ខ-ការចម្លងទាំងស្រុង ឬភាគសំខាន់ខ្លះនូវសៀវភៅតាមវិធីបោះពុម្ពជាថ្មី និងការចម្លងស្នាដៃតូរ្យតន្ត្រីក្រោមរូបភាពជាអក្សរភ្លេង ។

គ-ការចម្លងទាំងស្រុងឬភាគសំខាន់ខ្លះនូវប្រព័ន្ធទិន្នន័យតាមទម្រង់ឌីជីថល ។

ឃ-កម្មវិធីកុំព្យូទ័រ លើកលែងតែច្បាប់ចម្លងកម្មវិធីដើម្បីរក្សាទុកសម្រាប់ការពារការបាត់បង់ ។

ង-ស្នាដៃណាមួយក្នុងលក្ខណៈដែលការផលិតឡើងវិញធ្វើឱ្យប៉ះពាល់ដល់អាជីវកម្មជាប្រក្រតីនៃស្នាដៃ ឬធ្វើឱ្យខូចខាតដោយមិនសមហេតុផលទៅលើផលប្រយោជន៍ស្របច្បាប់របស់អ្នកនិពន្ធឬម្ចាស់កម្មសិទ្ធិ ។

មាត្រា ២៥.-

អ្នកនិពន្ធមិនអាចធ្វើការហាមឃាត់បានចំពោះ :

ក-ការសម្តែងស្នាដៃជាឯកជនដោយមិនគិតកម្រៃ ជាការសម្តែងក្នុងរង្វង់គ្រួសារឬញាតិមិត្ត ។

ខ-ការរៀបចំទុកក្នុងបណ្ណាល័យនូវសំណៅស្នាដៃណាមួយ ដើម្បីរក្សាទុកឱ្យបានគង់វង្សឬដើម្បីទុកសម្រាប់ធ្វើការស្រាវជ្រាវ ។

គ-ការប្រើប្រាស់ស្នាដៃសម្រាប់ការសិក្សាដោយគ្មានរកប្រាក់កម្រៃ ។

ឃ-ការបកប្រែស្នាដៃពីភាសាខ្មែរទៅជាភាសាជនជាតិភាគតិច ឬបកប្រែពីភាសាជនជាតិភាគតិចមកជាភាសាខ្មែរ ។

ប្រសិនបើមានការបញ្ជាក់យ៉ាងច្បាស់លាស់នូវឈ្មោះរបស់អ្នកនិពន្ធនិងប្រភពនៃស្នាដៃ អ្នកនិពន្ធមិនអាចធ្វើការហាមឃាត់ចំពោះកិច្ចការទាំងឡាយដូចតទៅ :

-ការវិភាគ និងអាគតដ្ឋានខ្លីៗនៃស្នាដៃដែលបញ្ជាក់ពីការរិះគន់ សង្គ្រាមប៉ាកកាគរុកោសល្យ វិទ្យាសាស្ត្រឬព័ត៌មានស្តីពីស្នាដៃនោះ

-ការផ្សាយទស្សនះសារព័ត៌មាន

-ការផ្សព្វផ្សាយទាំងស្រុងឬភាគខ្លះនៃសុន្ទរកថាទាំងឡាយដែលបានថ្លែងជាសាធារណៈក្នុងសារព័ត៌មានឬទូរផ្សាយ

-ការត្រាប់កំប្លែង ការត្រាប់តាមគំរូ ឬគំនូរត្លុកដោយផ្អែកតាមលំនាំដើមនៃស្នាដៃ

-ការចម្លងរូបភាពស្នាដៃសិល្បៈក្រាហ្វិកឬសិល្បៈសូនរូបដែលស្ថិតនៅទីកន្លែងសាធារណៈមួយ លើកលែងតែរូបភាពនោះត្រូវបានចាត់ទុកថាជាកម្មវត្ថុសំខាន់នៃការចម្លងបន្ត ។

**មាត្រា ២៦.–**

អ្នកនិពន្ធដែលបង្កើតស្នាដៃជាខ្សែភាពយន្ត វីដេអូ ល្ខោននិយាយ ប្រលោមលោកអំពីឆាកជីវិតនៃបុគ្គលឬគ្រួសារជាក់លាក់ណាមួយត្រូវបានការអនុញ្ញាតជាមុនពីបុគ្គលសាមីឬពីញាតិពន្ធដែលបានទទួលមរតកសាលសិទ្ធិ ។

**មាត្រា ២៧.–**

ការផលិតឡើងវិញជាបណ្តោះអាសន្ននូវស្នាដៃមួយបាន លុះត្រាតែការផលិតឡើងវិញនោះធ្វើឡើងស្របពេលជាមួយនឹងការប្រើប្រាស់ស្នាដៃដែលបានទទួលការអនុញ្ញាតពីម្ចាស់សិទ្ធិ ។

**មាត្រា ២៨.–**

ដោយមិនគិតពីបទប្បញ្ញត្តិនៃមាត្រា ២១ ច្បាប់នេះអាចអនុញ្ញាតឱ្យស្រង់អាគតដ្ឋានពីស្នាដៃណាមួយជាស្នាដៃដែលបានផ្សព្វផ្សាយត្រឹមត្រូវតាមច្បាប់បញ្ចូលក្នុងស្នាដៃមួយផ្សេងទៀត ដោយពុំចាំបាច់សុំការអនុញ្ញាតពីអ្នកនិពន្ធនិងពុំចាំបាច់បង់ប្រាក់កម្រៃ ។

ការស្រង់អាគតដ្ឋានត្រូវបញ្ជាក់អំពីប្រភពនិងឈ្មោះអ្នកនិពន្ធ បើនៅក្នុងប្រភពនោះមានឈ្មោះអ្នកនិពន្ធច្បាស់លាស់ ។ ការស្រង់អាគតដ្ឋាននេះមិនត្រូវធ្វើឱ្យហួសពីគោលដៅដែលត្រូវបំពេញនោះឡើយ ។

**មាត្រា ២៩.–**

ដោយមិនគិតពីបទប្បញ្ញត្តិក្នុងមាត្រា ២១ ច្បាប់នេះអាចអនុញ្ញាត :

ក-ឱ្យប្រើប្រាស់ស្នាដៃណាមួយដែលបានផ្សព្វផ្សាយត្រឹមត្រូវតាមច្បាប់ដើម្បីបញ្ជាក់ឱ្យបានច្បាស់ក្នុងទំព័រសៀវភៅឬសារព័ត៌មាន ឬតាមរលកវិទ្យុ ឬក្នុងការចាក់ផ្សាយសម្លេង ឬបញ្ចាំងរូបភាពដើម្បីជាប្រយោជន៍ដល់ការសិក្សាដោយពុំចាំបាច់បង់

ប្រាក់កម្រៃ ប៉ុន្តែត្រូវបញ្ជាក់ពីប្រភពនិងឈ្មោះអ្នកនិពន្ធ បើនៅក្នុងប្រភពនោះមានឈ្មោះអ្នកនិពន្ធច្បាស់លាស់ ។

ខ-ឱ្យថតចម្លងបាននូវអត្ថបទដាច់ដោយឡែកនានា អត្ថបទផ្សាយនៅក្នុងទំព័រសារពត៌មាន ឬទស្សនាវដ្តី ឬថតចម្លងបាននូវខ្លឹមសារដកស្រង់ខ្លីៗចេញពីស្នាដៃណាមួយដែលត្រូវបានផ្សាយត្រឹមត្រូវតាមច្បាប់ ។ ការថតចម្លងនេះ ធ្វើឡើងតាមរយៈមធ្យោបាយ បច្ចេកទេសចម្លង ដោយមិនរកប្រាក់ចំណេញខាងពាណិជ្ជកម្មដើម្បីជាប្រយោជន៍ដល់ការបង្រៀនឬដល់ការប្រឡងដែលធ្វើឡើងនៅក្នុងគ្រឹះស្ថានសិក្សានានាសមស្របទៅតាមគោលដៅដែលត្រូវបំពេញ ។ ការថតចម្លងនូវអត្ថបទឬខ្លឹមសារខ្លីៗពុំចាំបាច់បង់ប្រាក់កម្រៃ ប៉ុន្តែត្រូវបញ្ជាក់ពីប្រភពនិងឈ្មោះអ្នកនិពន្ធ ប្រសិនបើនៅក្នុងប្រភពនោះមានឈ្មោះអ្នកនិពន្ធច្បាស់លាស់ ។

## ផ្នែកទី ៥

## រយៈពេលនៃកិច្ចការពារសិទ្ធិបេតិកភណ្ឌ

### មាត្រា ៣០.-

សិទ្ធិបេតិកភណ្ឌត្រូវបានការពារចាប់តាំងពីថ្ងៃដែលបានបង្កើតស្នាដៃ ។ រយៈពេលកិច្ចការពារសិទ្ធិនេះត្រូវប្រព្រឹត្តទៅអស់មួយជីវិតអ្នកនិពន្ធព្រមទាំងប្រព្រឹត្តទៅ ៥០(ហាសិប)ឆ្នាំ ក្រោយថ្ងៃទទួលមរណភាពរបស់អ្នកនិពន្ធ ។

កិច្ចការពារសិទ្ធិបេតិកភណ្ឌលើស្នាដៃសហការប្រព្រឹត្តទៅអស់មួយជីវិតអ្នកនិពន្ធដែលរស់នៅចុងក្រោយគេ ព្រមទាំងប្រព្រឹត្តទៅរយៈពេល ៥០(ហាសិប)ឆ្នាំ ក្រោយថ្ងៃទទួលមរណភាពរបស់អ្នកនិពន្ធចុងក្រោយនេះ ។

### មាត្រា ៣១.-

សិទ្ធិបេតិកភណ្ឌលើស្នាដៃមួយដែលត្រូវបានបោះពុម្ពផ្សាយជាអនាមិកក្តី ឬជារហស្សនាមក្តីត្រូវទទួលបាននូវកិច្ចការពារពីច្បាប់នេះ ក្នុងរយៈពេល ៧៥(ចិតសិបប្រាំ)ឆ្នាំ គិតចាប់ពីដំណាច់ឆ្នាំប្រក្រតីទិននៃឆ្នាំដែលស្នាដៃនោះបានបោះពុម្ពផ្សាយជាលើកដំបូង ដោយមានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិ ។

ប្រសិនបើពុំមានការបោះពុម្ពផ្សាយជាលើកដំបូងក្នុងរយៈពេល ៥០(ហាសិប)ឆ្នាំ បន្ទាប់ពីពេលបង្កើតស្នាដៃនោះ កិច្ចការពាររយៈពេល ១០០(មួយរយ)ឆ្នាំ នឹងត្រូវបានគិតចាប់ពីដំណាច់ឆ្នាំប្រក្រតីទិននៃឆ្នាំដែលស្នាដៃនោះបានបង្កើត ។

បើសិនជាមុនពេលកំណត់នៃកិច្ចការពារពីច្បាប់ អត្តសញ្ញាណអ្នកនិពន្ធត្រូវបានបង្ហាញឱ្យស្គាល់ ឬត្រូវសាធារណជនបានស្គាល់ច្បាស់ឥតសង្ស័យ គឺបទប្បញ្ញត្តិនៃមាត្រា ៣០ ក្នុងច្បាប់នេះត្រូវយកមកអនុវត្ត ។

សិទ្ធិបេតិកភណ្ឌលើស្នាដៃសមូហភាព ឬស្នាដៃសោតទស្សន៍ ឬស្នាដៃបច្ឆាមរណៈត្រូវទទួលបាននូវកិច្ចការពារពីច្បាប់ក្នុងរយៈពេល ៧៥(ចិតសិបប្រាំ)ឆ្នាំ គិតចាប់ពីដំណាច់ឆ្នាំប្រក្រតីទិននៃឆ្នាំដែលស្នាដៃនោះបានផ្សព្វផ្សាយជាលើកដំបូងត្រឹមត្រូវតាមច្បាប់ ។

ប្រសិនបើពុំមានការផ្សព្វផ្សាយក្នុងរយៈពេល ៥០(ហាសិប)ឆ្នាំ បន្ទាប់ពីពេលបង្កើតស្នាដៃនោះ កិច្ចការពាររយៈពេល ១០០(មួយរយ)ឆ្នាំ នឹងត្រូវបានគិតចាប់ពីដំណាច់ឆ្នាំប្រក្រតីទិននៃឆ្នាំដែលស្នាដៃនោះបានបង្កើត ។

## ផ្នែកទី ៦
## ការផ្ទេរសិទ្ធិបេតិកភណ្ឌ

**មាត្រា ៣២.-**

ការផ្ទេរសិទ្ធិលើចំណុចណាមួយដែលមានចែងក្នុងមាត្រា ២១ ក្នុងច្បាប់នេះ មិនមែនជាការផ្ទេរសិទ្ធិលើចំណុចដទៃទៀតឡើយ ។

ប្រសិនបើមានកិច្ចសន្យាចែងអំពីការផ្ទេរ ឬការផ្តល់អាជ្ញាប័ណ្ណលើសិទ្ធិណាមួយដូចមានចែងក្នុងមាត្រានេះ ប្រសិទ្ធិភាពនៃការផ្ទេរឬការផ្តល់នោះត្រូវគោរពតាមល័ក្ខខ័ណ្ឌនៃរបៀបធ្វើអាជីវកម្មដូចមានចែងក្នុងកិច្ចសន្យា ។

**មាត្រា ៣៣.-**

ការគ្រប់គ្រងសិទ្ធិបេតិកភណ្ឌអាចផ្ទេរឱ្យទាយាទរបស់អ្នកនិពន្ធបានដោយមូលហេតុមរណភាពរបស់អ្នកនិពន្ធ ឬអាចប្រគល់ជូនតតីយជនបានដោយយោងតាមបទប្បញ្ញត្តិនៃមរតកសាសន៍ ។

ក្នុងករណីគ្មានអ្នកទទួលមរតកឬគ្មានមរតកសាសន៍ រដ្ឋដែលតំណាងដោយក្រសួងវប្បធម៌និងវិចិត្រសិល្បៈជាអ្នកគ្រប់គ្រងសិទ្ធិនោះ ។

## ផ្នែកទី ៧
## ការធ្វើអាជីវកម្មសិទ្ធិបេតិកភណ្ឌ

**មាត្រា ៣៤.-**

កិច្ចសន្យាទាំងឡាយស្តីពីការធ្វើអាជីវកម្មសិទ្ធិបេតិកភណ្ឌត្រូវធ្វើឡើងដោយលាយលក្ខណ៍អក្សរជាក់លាក់ បើមិនដូច្នោះទេ កិច្ចសន្យានេះនឹងត្រូវចាត់ទុកជាមោឃៈ ។ មានតែអ្នកនិពន្ធឬម្ចាស់សិទ្ធិប៉ុណ្ណោះដែលមានសិទ្ធិលើកនូវហេតុផលដើម្បីស្នើសុំមោឃភាពនៃកិច្ចសន្យា ។

**មាត្រា ៣៥.-**

កិច្ចសន្យានៃការផ្ទេរសិទ្ធិធ្វើអាជីវកម្មរបស់អ្នកនិពន្ធត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ដាច់ដោយឡែកពីគ្នាអំពីកម្រិត ទំហំ គោលដៅ ទីកន្លែងនិងរយៈពេលនៃការផ្ទេរសិទ្ធិនីមួយៗឱ្យបានច្បាស់លាស់ ។

**មាត្រា ៣៦.-**

ក្នុងក្របខ័ណ្ឌនៃការបង្កើតស្នាដៃសមូហភាព អ្នកនិពន្ធម្នាក់ៗអាចធ្វើអាជីវកម្មលើវិភាគទានរបស់ខ្លួនដាច់ដោយឡែកពីគ្នាបាន លើកលែងតែមានបទប្បញ្ញត្តិផ្ទុយ ប៉ុន្តែអ្នកនិពន្ធនោះមិនត្រូវបង្កឱ្យខូចខាតដល់អាជីវកម្មនៃស្នាដៃសមូហភាពនោះឡើយ ។

ចំពោះស្នាដៃសហការ ការធ្វើអាជីវកម្មអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការយល់ព្រមពីសហអ្នកនិពន្ធ ។ នៅពេលសហអ្នកនិពន្ធមិនឯកភាពគ្នា តុលាការជាអ្នកសម្រេច ។

**មាត្រា ៣៧.-**

ការផ្ទេរសិទ្ធិដើម្បីធ្វើអាជីវកម្មលើស្នាដៃរបស់អ្នកនិពន្ធអាចផ្ទេរទាំងស្រុង ឬផ្ទេរជាភាគខ្លះបាន ។ ម្ចាស់សិទ្ធិនឹងទទួលបានកម្រៃពីការផ្ទេរសិទ្ធិនេះ អនុលោមតាមប្រការ

ទាំងឡាយនៃកិច្ចសន្យាផ្ទេរសិទ្ធិនោះ ។

## ផ្នែកទី ៨
## ការតម្កល់ និង ការចុះបញ្ជីនៃស្នាដៃ

**មាត្រា ៣៨.-**

រាល់ស្នាដៃទាំងអស់ត្រូវទទួលបាននូវកិច្ចការពារពីច្បាប់នេះជាស្វ័យប្រវត្តិ ។ អ្នកនិពន្ធឬម្ចាស់សិទ្ធិអាចតម្កល់ទុកស្នាដៃនៅក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។

**មាត្រា ៣៩.-**

ការចុះបញ្ជីអាចធ្វើឡើងបានដោយស្ម័គ្រចិត្តនៅក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។ ការចុះបញ្ជីត្រូវចុះឈ្មោះពិតប្រាកដរបស់អ្នកនិពន្ធ ចុះថ្ងៃ ខែ ឆ្នាំ នៃស្នាដៃដែលបានផ្សព្វផ្សាយជាលើកដំបូង និងចុះថ្ងៃ ខែ ឆ្នាំ នៃការបង្កើតស្នាដៃព្រមទាំងចុះពីសិទ្ធិរបស់អ្នកនិពន្ធ ។

**មាត្រា ៤០.-**

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈត្រូវចេញវិញ្ញាបនប័ត្រចំពោះស្នាដៃដែលបានចុះបញ្ជី ។ អ្នកស្នើសុំចុះបញ្ជីត្រូវបង់កម្រៃទៅតាមប្រកាសរួមរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## ជំពូកទី ៣
## សិទ្ធិប្រហាក់ប្រហែល
## ផ្នែកទី ១
## សិទ្ធិអ្នកសម្តែង

**មាត្រា ៤១.-**

អ្នកសម្តែងមានសិទ្ធិផ្តាច់មុខក្នុងការធ្វើដោយផ្ទាល់ឬអនុញ្ញាត :

ក-ការផ្សាយតាមទូរផ្សាយនិងការផ្សព្វផ្សាយជាសាធារណៈ នូវការសម្តែង

របស់ខ្លួន លើកលែងតែការផ្សាយទាំងនោះបានផ្សាយចេញពីហ្វូណូក្រាមស្តីពីការសម្តែង ដែលបានអនុញ្ញាតពីអ្នកសម្តែង ឬបានផ្សាយឡើងវិញតាមទូរផ្សាយ ឬបានការអនុញ្ញាត ពីអង្គភាពទូរផ្សាយដែលបានផ្សាយមុនគេនូវការសម្តែង ។

ខ-ការថតបញ្ចូលជាហ្វូណូក្រាមនូវការសម្តែងរបស់ខ្លួនដែលមិនទាន់បាន ថតបញ្ចូលហ្វូណូក្រាម ។

គ-ការផលិតឡើងវិញនូវការសម្តែងដែលបានថតបញ្ចូលជាហ្វូណូក្រាម ។

ឃ-ការចែកចាយជាសាធារណៈតាមការលក់ឬការផ្ទេរកម្មសិទ្ធិនូវហ្វូណូ-ក្រាមច្បាប់ដើមដែលអ្នកសម្តែងពុំទាន់បានអនុញ្ញាតឱ្យធ្វើការចែកចាយ ។

ង-ការជាក់ជួលឬការឱ្យខ្ចីជាសាធារណៈនូវហ្វូណូក្រាមច្បាប់ដើម ឬ ហ្វូណូក្រាមច្បាប់ចម្លងស្តីពីការសម្តែង ។

បើគ្មានកិច្ចព្រមព្រៀង ផ្ទុយពីនេះ អ្នកសម្តែងមានសិទ្ធិ :

-អនុញ្ញាតចាក់ផ្សាយតាមអង្គភាពទូរផ្សាយណាមួយ ប៉ុន្តែអង្គភាពទូរផ្សាយ ដទៃទៀតពុំមានសិទ្ធិធ្វើការចាក់ផ្សាយនូវការសម្តែងរបស់ខ្លួនបានទេ

-អនុញ្ញាតចាក់ផ្សាយតាមអង្គភាពទូរផ្សាយណាមួយ ប៉ុន្តែអង្គភាពទូរផ្សាយ នោះពុំមានសិទ្ធិថតបញ្ចូលជាហ្វូណូក្រាមនូវការសម្តែងរបស់ខ្លួនទេ ។

**មាត្រា ៤២.-**

ទោះបីមានការផ្ទេរសិទ្ធិបេតិកភណ្ឌរបស់ខ្លួនហើយក៏ដោយ អ្នកសម្តែងនៅមាន សិទ្ធិតម្រូវឱ្យគេសរសេរឈ្មោះខ្លួនលើការសម្តែងផ្ទាល់ ឬការសម្តែងដែលបានថតទុក លើកលែងតែក្នុងករណីដែលវិធីប្រើប្រាស់នៃការសម្តែងនោះពុំតម្រូវឱ្យមានការសរសេរ ឈ្មោះ ។ អ្នកសម្តែងនៅមានសិទ្ធិជំទាស់គ្រប់រូបភាពនៃការបំផ្លើស ការកាត់តខ្លឹមសារ ខ្វះឬកែប្រែខ្លឹមសារនៃការសម្តែងជាហេតុធ្វើឱ្យខូចកេរ្តិ៍ឈ្មោះអ្នកសម្តែង ។

**មាត្រា ៤៣.-**

អ្នកសម្តែងមិនអាចហាមឃាត់នូវការផលិតឡើងវិញនិងការផ្សព្វផ្សាយជាសាធា-រណៈស្តីពីការសម្តែងរបស់ខ្លួនបានឡើយ បើការសម្តែងនោះមានលក្ខណៈបន្ទាប់បន្សំនៅ ក្នុងសាច់រឿងស្នូលរបស់ឈុត ឬឆ្នាដៃ ឬឯកសារសោតទស្សន៍ ។

## ផ្នែកទី ២
## សិទ្ធិរបស់ផលិតករហ្វូណូក្រាម

**មាត្រា ៤៤.-**

ផលិតករហ្វូណូក្រាមមានសិទ្ធិផ្តាច់មុខក្នុងការថត ឬការផលិតឡើងវិញ ឬការផ្សព្វផ្សាយជាសាធារណៈនូវហ្វូណូក្រាមរបស់ខ្លួន ។

**មាត្រា ៤៥.-**

រាល់ការផលិតឡើងវិញ ការលក់ ការប្តូរ ការជួល ឬការផ្សព្វផ្សាយជាសាធារណៈនូវហ្វូណូក្រាមត្រូវមានការអនុញ្ញាតពីផលិតករហ្វូណូក្រាម ។

ផលិតករហ្វូណូក្រាមមានសិទ្ធិចែកចាយជាសាធារណៈតាមការលក់ ឬការផ្ទេរកម្មសិទ្ធិនូវច្បាប់ដើមឬច្បាប់ចម្លង ក្នុងករណីដែលផលិតករហ្វូណូក្រាមនោះពុំទាន់អនុញ្ញាតឱ្យជនណាម្នាក់ធ្វើការចែកចាយ ។

ផលិតករហ្វូណូក្រាមមានសិទ្ធិនាំចូលនូវច្បាប់ចម្លងនៃហ្វូណូក្រាមរបស់ខ្លួនក្នុងទិសដៅធ្វើការផ្សព្វផ្សាយជាសាធារណៈ ។

## ផ្នែកទី ៣
## សិទ្ធិផលិតករវីដេអូ

**មាត្រា ៤៦.-**

ផលិតករវីដេអូគឺជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានការផ្តួចផ្តើមគំនិតនិងការទទួលខុសត្រូវក្នុងការថតបញ្ចូលតាមបច្ចេកទេសផ្សាយនូវរូបភាពជាឈុតៗដែលមានឬគ្មានសម្លេងដើម្បីផលិតវីដេអូ ។

រាល់ការផលិតឡើងវិញនូវវីដេអូដើម្បីផ្សព្វផ្សាយជាសាធារណៈ លក់ ដូរ ឬជួលចាំបាច់ត្រូវតែមានការអនុញ្ញាតពីផលិតករវីដេអូ ។

ការផ្ទេរសិទ្ធិរបស់ផលិតករវីដេអូដូចមានចែងក្នុងមាត្រានេះ មិនអាចធ្វើឡើងដាច់ដោយឡែកពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិអ្នកសម្តែងដែលបានរួមសហការផលិតជាវីដេអូបានឡើយ ។

## ផ្នែកទី ៤
## សិទ្ធិនៃអង្គភាពទូរផ្សាយ

**មាត្រា ៤៧.-**

អង្គភាពទូរផ្សាយមានស្ថានីយវិទ្យុ ស្ថានីយទូរទស្សន៍និងស្ថានីយទូរទស្សន៍ខ្សែកាប មានសិទ្ធិផ្តាច់មុខក្នុងការធ្វើ ឬអនុញ្ញាតការថតកម្មវិធីផ្សាយ ការផ្សព្វផ្សាយជាសាធារណៈ ការចាក់ផ្សាយឡើងវិញ ការផលិតឡើងវិញ ការចែកចាយ ឬការដាក់ជួលជាលើកដំបូងនូវច្បាប់ចម្លងនៃកម្មវិធីផ្សាយរបស់ស្ថានីយសាមី ។

**មាត្រា ៤៨.-**

ការថតចម្លងនូវកម្មវិធីរបស់អង្គភាពទូរផ្សាយដើម្បីលក់ ជួល ប្តូរ ចាក់ផ្សាយ ឬផ្សព្វផ្សាយជាសាធារណៈនៅទីកន្លែងណាមួយត្រូវមានការអនុញ្ញាតពីអង្គភាពទូរផ្សាយសាមី ។

## ផ្នែកទី ៥
## លាភការ

**មាត្រា ៤៩.-**

ប្រសិនបើហ្វូណូក្រាមបានផលិតក្នុងគោលបំណងពាណិជ្ជកម្ម ឬជាការផលិតឡើងវិញត្រូវបានយកទៅផ្សព្វផ្សាយតាមទូរផ្សាយ ឬផ្សព្វផ្សាយផ្សេងទៀតជាសាធារណៈ ឬសម្តែងជាសាធារណៈ អ្នកសម្តែងនិងផលិតករហ្វូណូក្រាមត្រូវទទួលបាននូវលាភការគ្រប់គ្នាតែមួយលើកគត់ប្រកបដោយសមធម៌ ដែលអ្នកប្រើប្រាស់ត្រូវបង់លាភការនោះជូនអង្គភាពគ្រប់គ្រងសិទ្ធិរួម ។

អង្គភាពគ្រប់គ្រងសិទ្ធិរួមគឺជានីតិបុគ្គលមានភារកិច្ចចាត់ចែងការងារស្តីពីលាភការនេះដែលកំណត់ដោយអនុក្រឹត្យ ។

# ផ្នែកទី ៦
## ការកម្រិតសិទ្ធិ

**មាត្រា ៥០.-**

ដោយមិនគិតដល់បទប្បញ្ញត្តិនៃមាត្រា ៤១ មាត្រា ៤២ មាត្រា ៤៣ មាត្រា ៤៤ មាត្រា ៤៥ មាត្រា ៤៦ មាត្រា ៤៧ និងមាត្រា ៤៨ នៃច្បាប់នេះ សកម្មភាពទាំងឡាយដូចតទៅនេះ ត្រូវអនុញ្ញាតឱ្យអនុវត្តបានដោយពុំចាំបាច់ទទួលការយល់ព្រមពីសិទ្ធិវន្ត និងពុំចាំបាច់បង់ប្រាក់កម្រៃ :

ក-សេចក្តីរាយការណ៍ស្តីពីបច្ចុប្បន្នភាពក្នុងលក្ខខណ្ឌដែលសេចក្តីរាយការណ៍នោះបានដកស្រង់ជាផ្នែកខ្លីៗពីការសម្តែង ឬពីខ្សែមសារហ្វូណូក្រាម ឬពីក្នុងការផ្សាយតាមទូរផ្សាយ ។

ខ-ការថតចម្លងដែលធ្វើឡើងសម្រាប់តែប្រើប្រាស់ក្នុងផ្នែកស្រាវជ្រាវវិទ្យាសាស្ត្រ ។

គ-ការថតចម្លងសម្រាប់បម្រើក្នុងក្របខ័ណ្ឌនៃការសិក្សាលើកលែងតែការសម្តែង ឬហ្វូណូក្រាមដែលផលិតសម្រាប់តែគោលបំណងនៃការសិក្សា ។

ឃ-អាគតដ្ឋានជាសម្រង់ខ្លីៗពីការសម្តែង ឬហ្វូណូក្រាម ឬកម្មវិធីចាក់ផ្សាយតាមទូរផ្សាយសមស្របតាមទម្លាប់ល្អ ដើម្បីប្រើប្រាស់ក្នុងទិសដៅព័ត៌មាន ។

ង-ការប្រើប្រាស់ផ្សេងៗទៀតដែលជាករណីលើកលែង ពិសេសចំពោះស្នាដៃនានាដែលទទួលបាននូវកិច្ចការពារសិទ្ធិអ្នកនិពន្ធដោយអនុលោមតាមច្បាប់នេះ ។

ច-ការចាប់យករូបភាពនិងសម្លេងដើម្បីផ្សព្វផ្សាយបន្តទាំងស្រុង ឬភាគខ្លះដោយអង្គភាពទូរផ្សាយស្តីពីបច្ចុប្បន្នភាពនៃពិធីបុណ្យ អង្គប្រជុំ ឬព្រឹត្តការណ៍នានារបស់ជាតិពីស្ថានីយដើមក្នុងពេលតែមួយ ។

**មាត្រា ៥១.-**

បទប្បញ្ញត្តិនៃមាត្រា ៤១ នៃច្បាប់នេះ មិនត្រូវអនុវត្តនៅពេលណាដែលអ្នកសម្តែងអនុញ្ញាតឱ្យគេថតបញ្ចូលការសម្តែងរបស់ខ្លួនទៅក្នុងហ្វូណូក្រាមមានរូបភាពឬសោតទស្សន៍ ។

**មាត្រា ៥២.-**

បទប្បញ្ញត្តិនៃមាត្រា ៤១ ក្នុងច្បាប់នេះ មិនត្រូវយកទៅអនុវត្តចំពោះអង្គភាពទូរផ្សាយណាមួយដែលធ្វើការថតចម្លងនិងផលិតឡើងវិញដោយមធ្យោបាយផ្ទាល់ខ្លួន ដើម្បីចាក់ផ្សាយក្នុងកម្មវិធីផ្សាយរបស់អង្គភាពទូរផ្សាយនោះ ក្នុងគោលបំណងផ្សាយពាណិជ្ជកម្ម ។

រាល់ការផលិតឡើងវិញនូវស្នាដៃ ឬច្បាប់ចម្លងរូបមានចែងនៅក្នុងកថាខណ្ឌខាងលើនៃមាត្រានេះ ត្រូវបំផ្លាញចោលឱ្យអស់ក្នុងរយៈពេល ៦(ប្រាំមួយ)ខែ បន្ទាប់ពីការផលិត លើកលែងតែករណីត្រូវរក្សាទុកស្នាដៃចម្លងមួយច្បាប់គត់សម្រាប់ជាឯកសារ ។

## ផ្នែកទី ៧
## រយៈពេលនៃកិច្ចការពារ

**មាត្រា ៥៣.-**

១-រយៈពេលនៃកិច្ចការពារអ្នកសម្តែងគឺ ៥០(ហាសិប)ឆ្នាំ គិតចាប់ពីដំណាច់ឆ្នាំប្រក្រតិទិននៃការថតបញ្ចូលក្នុងហ្វូណូក្រាម ឬក្នុងករណីដែលពុំបានថតការសម្តែងបញ្ចូលក្នុងហ្វូណូក្រាម គឺគិតចាប់ពីដំណាច់ឆ្នាំប្រក្រតិទិនដែលការសម្តែងបានប្រព្រឹត្តទៅ ។

២-រយៈពេលនៃកិច្ចការពារផលិតករហ្វូណូក្រាមគឺ ៥០(ហាសិប)ឆ្នាំ គិតពីចាប់ដំណាច់ឆ្នាំប្រក្រតិទិនដែលបានបោះផ្សាយហ្វូណូក្រាម ឬក្នុងករណីពុំបានបោះផ្សាយហ្វូណូក្រាម គឺគិតពីចាប់ដំណាច់ឆ្នាំប្រក្រតិទិន ដែលបានថតសម្លេងបញ្ចូលក្នុងហ្វូណូក្រាម ។

៣-រយៈពេលនៃកិច្ចការពារកម្មវិធីផ្សាយរបស់អង្គភាពទូរផ្សាយ គឺ ៥០(ហាសិប)ឆ្នាំ គិតចាប់ពីដំណាច់ឆ្នាំប្រក្រតិទិនដែលកម្មវិធីបានផ្សាយ ។

## ផ្នែកទី ៨
## ការផ្ទេរសិទ្ធិ

**មាត្រា ៥៤.–**

បទប្បញ្ញត្តិនៃមាត្រា ៣២ មាត្រា ៣៣ និងមាត្រា ៣៤ នៃច្បាប់នេះ ត្រូវយកមកអនុវត្តចំពោះសិទ្ធិអ្នកសម្តែង ផលិតករហ្វូណូក្រាម និងអង្គភាពទូរផ្សាយ ។

## ផ្នែកទី ៩
## ការតម្កល់

**មាត្រា ៥៥.–**

បទប្បញ្ញត្តិនៃមាត្រា ៣៨ មាត្រា ៣៩ និងមាត្រា ៤០ នៃច្បាប់នេះ ត្រូវយកមកអនុវត្តចំពោះសិទ្ធិអ្នកសម្តែង ផលិតករហ្វូណូក្រាម និងអង្គភាពទូរផ្សាយ ។

## ជំពូកទី ៤
## ការគ្រប់គ្រងរួមលើសិទ្ធិនានា

**មាត្រា ៥៦.–**

អ្នកនិពន្ធនិងម្ចាស់សិទ្ធិប្រហាក់ប្រហែលអាចបង្កើតអង្គភាពគ្រប់គ្រងសិទ្ធិរួមដើម្បីការពារនិងគ្រប់គ្រងសិទ្ធិបេតិកភណ្ឌ ។

ការបង្កើតអង្គភាពគ្រប់គ្រងរួមលើសិទ្ធិអ្នកនិពន្ធ អ្នកសម្តែង ផលិតករហ្វូណូក្រាម ឬផលិតករវីដេអូ ត្រូវតែមានការទទួលស្គាល់ពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។

អង្គភាពគ្រប់គ្រងរួមលើសិទ្ធិផ្សាយតាមវិទ្យុ ទូរទស្សន៍ ទូរទស្សន៍ខ្សែកាបនៃអង្គភាពទូរផ្សាយត្រូវមានការទទួលស្គាល់ពីក្រសួងពត៌មាន ។

# ជំពូកទី ៥
# ករណីវិវាទ និង ទោសប្បញ្ញត្តិ

**មាត្រា ៥៧.-**

បុគ្គលណាដែលបានទទួលរង ឬអាចទទួលរងនូវការប៉ះពាល់ដល់សិទ្ធិរបស់ខ្លួនជាអ្នកនិពន្ធក្តី ឬសិទ្ធិប្រហាក់ប្រហែលក្តី បុគ្គលនោះមានសិទ្ធិប្តឹងទៅតុលាការដើម្បី :

ក-ធ្វើការហាមប៉ះពាល់ដល់សិទ្ធិខ្លួន ប្រសិនបើការប៉ះពាល់នោះអាចនឹងកើតមាននៅក្នុងពេលឆាប់ៗខាងមុខ ។

ខ-បង្គាប់ឱ្យចុងចម្លើយឈប់ធ្វើការប៉ះពាល់ដល់សិទ្ធិខ្លួន ប្រសិនបើការប៉ះពាល់បែបនេះនៅតែបន្តសកម្មភាព ។ ដើមចោទអាចទាមទារឱ្យចុងចម្លើយសងជម្ងឺចិត្ត សងការខូចខាតនិងប្រគល់មកវិញនូវវត្ថុតាងមានឧបករណ៍ ឬសម្ភារៈដែលជាប់រឿងហេតុព្រមទាំងប្រគល់នូវប្រាក់ចំណេញដែលបានមកពីអំពើខុសច្បាប់នោះ ។

**មាត្រា ៥៨.-**

តុលាការមានសមត្ថកិច្ចរឹបអូសឬបំផ្លាញចោលនូវវត្ថុតាងមានឧបករណ៍ សម្ភារៈដែលត្រូវបានផលិត បានប្រើប្រាស់ ឬបានដាក់ឱ្យចរាចរដោយខុសច្បាប់ ឬឧបករណ៍សម្រាប់ធ្វើការបំពានដែលឧបករណ៍ឬសម្ភារៈទាំងនោះកំពុងស្ថិតក្នុងការកាន់កាប់របស់ចុងចម្លើយ ឬកំពុងត្រូវបានឃាត់ទុក ។

**មាត្រា ៥៩.-**

តុលាការមានសមត្ថកិច្ចចាត់វិធានការចាំបាច់ជាបណ្តោះអាសន្ន សម្រាប់ធានានូវការរក្សាទុកវត្ថុតាង ដែលផលិតចេញពីការចម្លងខុសច្បាប់នូវស្នាដៃណាមួយ ។

ដើមចោទមានកាតព្វកិច្ចផ្តល់សំណងលើការខូចខាតដែលខ្លួនបានប្រព្រឹត្តទៅលើចុងចម្លើយ ក្នុងករណីបណ្តឹងនោះត្រូវបានតុលាការរកឃើញថាជាបណ្តឹងពុំមានមូលហេតុត្រឹមត្រូវ ។

មាត្រា ៦០.-

ក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ គិតពីថ្ងៃនៃការឃាត់ទុកនូវឧបករណ៍ ឬសម្ភារៈ បុគ្គលជាម្ចាស់ ឬគតិយជនជាអ្នកកាន់កាប់ឧបករណ៍ ឬសម្ភារៈដែលត្រូវបានឃាត់ទុក អាចស្នើសុំទៅតុលាការឱ្យលើកលែងការឃាត់ទុក ឬសម្រេចកម្រិតអនុភាពនៃការឃាត់ទុកនោះ ។

មាត្រា ៦១.-

ការឃាត់ទុកនូវវត្ថុតាង មានឧបករណ៍ឬសម្ភារៈទាំងឡាយណាដោយពុំបានប្តឹងទៅតុលាការក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ គិតពីថ្ងៃឃាត់ទុក ការលើកលែងការឃាត់ទុកតាមសំណើសុំរបស់បុគ្គលជាម្ចាស់ ឬគតិយជនជាអ្នកកាន់កាប់ ជាសមត្ថកិច្ចរបស់តុលាការ ។

មាត្រា ៦២.-

យោងតាមមាត្រា ៦៤ និងមាត្រា ៦៥ នៃច្បាប់នេះ ត្រូវចាត់ទុកជាបទល្មើសដែរ អំពើទាំងឡាយដូចតទៅ :

១-ការផលិត ឬការនាំចូលដើម្បីដាក់លក់ ឬដាក់ជួលនូវឧបករណ៍ ឬគ្រឿងមធ្យោបាយណាមួយដែលធ្វើឡើង ឬយកលំនាំតាមក្នុងគោលបំណងធ្វើឱ្យរាំងស្ទះដំណើរការល្អនៃឧបករណ៍ ឬគ្រឿងមធ្យោបាយទូទៅ ឬកាត់បន្ថយចំនួនការផលិតឡើងវិញនៃស្នាដៃហ្វូណូក្រាម ឬការផ្សាយតាមទូរផ្សាយ ឬធ្វើឱ្យខូចគុណភាពនូវច្បាប់ចម្លង ។

២-ការផលិត ឬការនាំចូលដើម្បីដាក់លក់ ឬដាក់ជួលនូវឧបករណ៍ ឬគ្រឿងមធ្យោបាយណាមួយដែលនាំឱ្យបុគ្គលគ្មានសិទ្ធិទទួលបាននូវកម្មវិធីផ្សាយតាមសញ្ញាលេខកូដដែលផ្សាយតាមទូរផ្សាយ ឬផ្សាយជាសាធារណៈតាមវិធីផ្សេងរួមមានការផ្សាយតាមផ្កាយរណប ។

៣-ការលុបចោលឬការកែប្រែព័ត៌មានស្តីពីរបបសិទ្ធិតាមទម្រង់អេឡិចត្រូនិច ដោយគ្មានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិ ។

៤-ការចែកចាយ ឬការនាំចូលដើម្បីចែកចាយ ការផ្សាយតាមអង្គភាពទូរផ្សាយ ការផ្សាយជាសាធារណៈ ឬការដាក់ជូនសាធារណជននូវស្នាដៃ ឬការសម្តែង

ឬហ្វូណូក្រាម ឬកម្មវិធីផ្សាយនៃអង្គភាពទូរផ្សាយដោយគ្មានការអនុញ្ញាត ហើយអ្នកប្រព្រឹត្តដឹងច្បាស់ថាព័ត៌មានស្តីពីរបបសិទ្ធិតាមទម្រង់អេឡិចត្រូនិចជាព័ត៌មានដែលត្រូវគេលុបចោលឬកែប្រែរួចហើយ ។

ពាក្យថា **"ព័ត៌មានស្តីពីរបបសិទ្ធិ"** មានន័យថា :

-ព័ត៌មានដែលធ្វើឱ្យគេស្គាល់ពីអត្តសញ្ញាណអ្នកនិពន្ធ ភិនភាគស្នាដៃ អត្តសញ្ញាណអ្នកសម្តែង ភិនភាគនៃអ្នកសម្តែង អត្តសញ្ញាណផលិតករហ្វូណូក្រាម ភិនភាគហ្វូណូក្រាម អត្តសញ្ញាណអង្គភាពទូរផ្សាយនិងភិនភាគកម្មវិធីអង្គភាពទូរផ្សាយ

-ព័ត៌មានដែលធ្វើឱ្យគេស្គាល់ពីអត្តសញ្ញាណម្ចាស់កម្មសិទ្ធិ ឬភិនភាគនៃព័ត៌មានស្តីពីលក្ខខណ្ឌនិងបែបបទនៃការប្រើប្រាស់ស្នាដៃនិងផលិតផលផ្សេងទៀត ដូចមានចែងនៅក្នុងច្បាប់នេះ និងស្គាល់ភិនភាគលេខកូដ ឬសញ្ញាលេខកូដ ដែលចែងឱ្យដឹងនូវព័ត៌មានទាំងនោះ ។

## មាត្រា ៦៣.-

តាមការស្នើសុំជាលាយលក្ខណ៍អក្សរពីម្ចាស់សិទ្ធិអ្នកនិពន្ធ ឬម្ចាស់សិទ្ធិប្រហាក់ប្រហែល ក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យ រដ្ឋបាលគយនិងរដ្ឋាករអាចឃាត់ទុកបាននូវទំនិញដែលម្ចាស់សិទ្ធិនោះសំអាងថាជាទំនិញក្លែងបន្លំ ។ រដ្ឋបាលគយនិងរដ្ឋាករត្រូវជូនដំណឹងជាបន្ទាន់ដល់តុលាការមានសមត្ថកិច្ច អាជ្ញាធរមានសមត្ថកិច្ចដើមបណ្តឹង និងអ្នកកាន់កាប់ទំនិញអំពីការឃាត់ទុកនូវទំនិញទាំងនោះ ។

លើកលែងតែមានបទប្បញ្ញត្តិស្តីពីរដ្ឋបាលគយនិងរដ្ឋាករចែងផ្ទុយពីបទប្បញ្ញត្តិនេះ វិធានឃាត់ទុកទំនិញអាចលុបចេញដោយស្របច្បាប់បាន ប្រសិនបើក្នុងរយៈពេល ១០ (ដប់)ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃជូនដំណឹងស្តីពីការឃាត់ទុកទំនិញនោះ អ្នកប្តឹងពុំបានបង្ហាញភស្តុតាងឱ្យបានត្រឹមត្រូវដើម្បីបញ្ជាក់ទៅរដ្ឋបាលគយនិងរដ្ឋាករឱ្យដឹងថាសាមីខ្លួនបាន :

-ស្នើសុំទៅតុលាការចាត់វិធានការរក្សាទុកទំនិញដូចមានចែងក្នុងមាត្រា ៥៩ នៃច្បាប់នេះ

-ប្តឹងទៅតុលាការមានសមត្ថកិច្ចដោយមានភ្ជាប់ជាមួយនូវការធានាគ្រប់គ្រាន់ដើម្បីការពារទុកជាមុននូវការទទួលខុសត្រូវរបស់ខ្លួនដែលអាចកើតមានជាយថា-

ហេតុបាន ។

អ្នកប្តឹងត្រូវតែជួសជុលការខូចខាតដែលបណ្តាលមកពីការឃាត់ទុកទំនិញនោះ ប្រសិនបើបណ្តឹងរបស់ខ្លួនត្រូវបានរកឃើញថាជាបណ្តឹងគ្មានមូលដ្ឋានត្រឹមត្រូវ ។

បទប្បញ្ញត្តិស្តីពីវិធានការតាមមាត់ច្រកព្រំដែននៃច្បាប់ស្តីពី "ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់" ត្រូវយកមកអនុវត្តបន្ថែមក្នុងមាត្រានេះ ។

**មាត្រា ៦៤.–**

ការរំលោភបំពានលើសិទ្ធិអ្នកនិពន្ធដូចមានកំណត់ក្នុងច្បាប់នេះ តាមរយៈការផលិត ការផលិតឡើងវិញ ឬការសម្តែង ឬការផ្សព្វផ្សាយនូវស្នាដៃដោយប្រើមធ្យោបាយបែបណាក៏ដោយ គឺជាបទល្មើសដែលត្រូវទទួលទោសតាមច្បាប់ ។

បទល្មើសនៃការផលិតឬការផលិតឡើងវិញ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០(ប្រាំលាន)រៀល ទៅ ២៥.០០០.០០០(ម្ភៃប្រាំលាន)រៀល ឬ/និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ៦(ប្រាំមួយ)ខែ ដល់ ១២(ដប់ពីរ)ខែ ។ ករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង ។

ការនាំចូលឬនាំចេញនូវផលិតផលបានពីបទល្មើសដែលជាការផលិតឡើងវិញ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០(ពីរលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល ឬ/និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ៦(ប្រាំមួយ)ខែ ដល់ ១២(ដប់ពីរ)ខែ ។ ករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង ។

បទល្មើសនៃការសម្តែង ឬការផ្សព្វផ្សាយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០(មួយលាន)រៀល ទៅ ៥.០០០.០០០(ប្រាំលាន)រៀល ឬ/និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ១(មួយ)ខែ ដល់ ៣(បី)ខែ ។ ករណីបទល្មើសបានប្រព្រឹត្តច្រើនដង ការផ្តន្ទាទោសត្រូវគុណនឹងចំនួននៃការប្រព្រឹត្ត ។ ករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដងនៃទោសពីមុន ។

**មាត្រា ៦៥.–**

ការផលិតឬការផលិតឡើងវិញដោយគ្មានការអនុញ្ញាតពីអ្នកសម្តែង ឬពីផលិតករហ្វូណូក្រាម ឬពីផលិតករវីដេអូ ឬអង្គភាពផ្សព្វផ្សាយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី

៥.០០០.០០០(ប្រាំលាន)រៀល ទៅ ២៥.០០០.០០០(ម្ភៃប្រាំលាន)រៀល ឬ/និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ៦(ប្រាំមួយ)ខែ ដល់ ១២(ដប់ពីរ)ខែ ។ ករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង ។

ការនាំចូលឬនាំចេញនូវហ្វូណូក្រាម កាសែ្សត ឬកាសែ្សតវីដេអូដោយគ្មានការអនុញ្ញាតពីអ្នកសម្តែង ឬផលិតករហ្វូណូក្រាម ឬផលិតករវីដេអូ ឬអង្គភាពទូរផ្សាយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០(ពីរលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល ឬ/និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ១(មួយ)ខែ ដល់ ៣(បី)ខែ ។ ករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង ។

ការចាក់ផ្សាយតាមទូរផ្សាយដោយគ្មានការអនុញ្ញាតពីអ្នកសម្តែង ឬពីផលិតករហ្វូណូក្រាម ឬពីផលិតករវីដេអូ ឬអង្គភាពទូរផ្សាយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០(មួយលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល ឬនិងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ១(មួយ)ខែ ដល់ ៣(បី)ខែ ។ ករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង ។

**មាត្រា ៦៦.-**

គ្រប់ករណីដូចមានចែងក្នុងមាត្រា ៦៤ និងមាត្រា ៦៥ នៃច្បាប់នេះ តុលាការមានសមត្ថកិច្ចចេញសេចក្តីសម្រេចដូចតទៅ :

-រឹបអូសមួយភាគឬទាំងស្រុងនូវប្រាក់ចំណូលបានមកពីបទល្មើសនិងឧបករណ៍ដែលដាក់តាំងដោយឡែកសម្រាប់ការប្រព្រឹត្តទៅនូវបទល្មើសនោះ

-បង្គាប់ឱ្យយកឧបករណ៍ឬសម្ភារៈដែលរឹបអូសទៅប្រគល់ជូនម្ចាស់សិទ្ធិអ្នកនិពន្ធ ឬម្ចាស់សិទ្ធិប្រហាក់ប្រហែលដោយមិនទាន់គិតគូរដល់ការសងសោហ៊ុយជម្ងឺចិត្ត

-បង្គាប់ឱ្យបំផ្លាញចោលនូវសម្ភារៈនិងឧបករណ៍ដែលបានពីការរឹបអូស ។

## ជំពូកទី ៦

## ការអនុវត្តសន្ធិសញ្ញាអន្តរជាតិ

**មាត្រា ៦៧.-**

បទប្បញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញាអន្តរជាតិទាក់ទងនឹងច្បាប់សិទ្ធិអ្នកនិពន្ធនិង

សិទ្ធិប្រហាក់ប្រហែលដែលព្រះរាជាណាចក្រកម្ពុជាជាភាគី ត្រូវយកមកអនុវត្តជាមួយនឹងច្បាប់នេះបាន ។

ក្នុងករណីមានទំនាស់ជាមួយនឹងបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ បទប្បញ្ញត្តិនៃសន្ធិសញ្ញាអន្តរជាតិទាំងនោះ ត្រូវចាត់ទុកជាបទប្បញ្ញត្តិគោល ។

## ជំពូកទី ៧

## អន្តរប្បញ្ញត្តិ

**មាត្រា ៦៨.-**

បន្ទាប់ពីច្បាប់នេះចូលជាធរមាន ក្រសួងវប្បធម៌និងវិចិត្រសិល្បៈត្រូវចេញសេចក្តីប្រកាសអំពីការបញ្ឈប់ជាបន្ទាន់នូវរាល់អាជីវកម្មដែលផ្ទុយនឹងច្បាប់នេះ ។

ក្រោយពីច្បាប់នេះចូលជាធរមាន ៦(ប្រាំមួយ)ខែ ទោសប្បញ្ញត្តិនៃមាត្រា ៦៤ និងមាត្រា ៦៥ ត្រូវយកមកអនុវត្តចំពោះអាជីវកម្មកំពុងមានសកម្មភាពផ្ទុយនឹងច្បាប់នេះ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៦៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៣

**ព្រះហស្តលេខា និង ព្រះរាជលញ្ចករ**

នស/រកម.០៣.០៣.១១៣

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ: ៤៩ ចល

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**
ព្រះហស្តលេខា

នរោត្តម បុប្ផាទេវី

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០០៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សោម គាន់**

# ឧបសម្ព័ន្ធ២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

លេខ...២០ ប្រ.ក....វវស

# ប្រកាស

## ស្តីពី

## ការបញ្ឈប់ជាបន្ទាន់នូវរាល់សកម្មភាព ដែលរំលោភបំពានលើ សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល

### រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស /រកម / ០១៩៦/ ០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យ លេខ ៦២ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស /រកម/០៣០៣/ ០០៨ ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៣ ប្រកាសឱ្យប្រើច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល

<u>**សម្រេច**</u>

<u>**ប្រការ**</u> **១.-**

**ស្នាដៃ** ជាផលិតផលខាងវិស័យ អក្សរសាស្ត្រ វិទ្យាសាស្ត្រ សិល្បៈ ឬតូរ្យតន្ត្រី កើតចេញពីការច្នៃប្រឌិតបង្កើតឡើងដោយគំនិតប្រាជ្ញា ឬមនោសញ្ចេតនា ។

<u>**ប្រការ**</u> **២.-**

**អ្នកនិពន្ធ** ជាជនដែលបង្កើតបានស្នាដៃ ។

សិទ្ធិប្រហាក់ប្រហែល ជាសិទ្ធិអ្នកសំដែង សិទ្ធិផលិតការហ្វូណូក្រាម និងសិទ្ធិអង្គភាពទូរផ្សាយ ។

**អង្គភាពទូរផ្សាយ** គឺស្ថានីយវិទ្យុ ទូរទស្សន៍ ទូរទស្សន៍ខ្សែកាប ឬផ្កាយរណប ។

**ប្រការ ៣.-**

ស្នាដៃទាំងឡាយដែលត្រូវទទួលបានការការពារក្រោមច្បាប់នេះមាន :

ក-សៀវភៅអានគ្រប់ប្រភេទ ឬឯកសារផ្សេងៗទៀតស្តីពីអក្សរសាស្ត្រ សិល្បៈ វិទ្យាសាស្ត្រ និងការអប់រំ ។

ខ-អត្ថបទបាឋកថា សង្កថា ធម្មទេសនា ការការពារខ្លួនដោយនិយាយ ឬដោយសរសេរ និងស្នាដៃផ្សេងៗទៀត ដែលមានប្រភេទដូចគ្នា ។

គ- ស្នាដៃនាដកម្ម ឬនាដកម្ម-តូរ្យតន្ត្រី ។

ឃ- ស្នាដៃរបាំសម័យ ឬយកលំនាំតាមស្នាដៃបុរាណ ឬប្រពៃណី ។

ង- ការសម្តែងសៀក និងការសម្តែងកាយវិការ ។

ច- ការតែងបទភ្លេងដោយមាន ឬគ្មានទំនុកច្រៀង ។

ឆ- ស្នាដៃសោតទស្សន៍ ។

ជ- ស្នាដៃជាផ្ទាំងគំនូរ ផ្ទាំងចម្លាក់ រូបចម្លាក់ ឬស្នាដៃផ្សេងៗទៀតខាងសិល្បៈសូនរូប ឬសិល្បៈអនុវត្ត ។

ឈ- ស្នាដៃថតរូប និងស្នាដៃទាំងឡាយដែលសម្រេចបានដោយសារមានជំនួយបច្ចេកទេសដូចគ្នា នឹងការថតរូប ។

ញ-ស្នាដៃស្ថាបត្យកម្ម ។

ដ-ផែនទី ប្លង់ គំនូសវាស ឬស្នាដៃស្តែងចេញជារូប ដែលទាក់ទងនឹងភូមិសាស្ត្រ ឋានលេខា ឬវិទ្យាសាស្ត្រនានា ។

ឋ-កម្មវិធីកុំព្យូទ័រ និងគម្រោងឯកសារសមោធាន ដែលទាក់ទងទៅនឹងកម្មវិធីទាំងនោះ ។

ឌ- ផលិតផលផ្នែកសិប្បកម្ម តម្បាញ ឬម៉ូតសម្លៀកបំពាក់ផ្សេងៗ ។

**ប្រការ ៤.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានបង្កើតស្នាដៃដូចមានចែងក្នុងប្រការ៣ខាងលើ មានឈ្មោះថាជាម្ចាស់កម្មសិទ្ធិ លើស្នាដៃ ហើយទទួលបាននូវសិទ្ធិធ្វើអាជីវកម្ម និងសិទ្ធិការពារលើស្នាដៃរបស់ខ្លួន ។

**ប្រការ ៥.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានទទួលនូវសិទ្ធិស្របច្បាប់លើស្នាដៃដូចមានចែងក្នុងប្រការ៣ខាងលើ មានឈ្មោះថាជាម្ចាស់កម្មសិទ្ធិលើស្នាដៃហើយទទួលបាននូវសិទ្ធិធ្វើអាជីវកម្ម និងសិទ្ធិការពារលើស្នាដៃនោះ ។

**ប្រការ ៦.-**

ត្រូវបញ្ឈប់ជាបន្ទាន់នូវសកម្មភាពដូចតទៅ ÷

ក-ការផលិត ឬការផលិតឡើងវិញ ឬការផ្សព្វផ្សាយជាសាធារណៈនូវស្នាដៃដោយគ្មានការអនុញ្ញាតពីម្ចាស់

ខ-ការក្លែងបន្លំ ក្នុងការផលិត ឬការផលិតឡើងវិញនូវស្លាកដៃដែលរំលោភបំពានលើម្ចាស់កម្មសិទ្ធិ ។

គ-ការនាំចូលនូវផលិតផលនៃស្លាកដៃពីបរទេសដើម្បីធ្វើអាជីវកម្ម ឬបង្កើតស្លាកដៃបន្តដោយគ្មានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិ ។

ឃ-ការនាំចេញនូវស្លាកដៃ ដើម្បីធ្វើអាជីវកម្មដោយគ្មានការយល់ព្រមពីម្ចាស់កម្មសិទ្ធិ ។

**ប្រការ ៧.-**

ចាប់ពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៣ រាល់អំពើល្មើសដែលរំលោភបំពានលើសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់-ប្រហែល ត្រូវផ្តន្ទាទោសតាមបទបញ្ញត្តិនៃច្បាប់ សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ។

**ប្រការ ៨.-**

ខុទ្ទកាល័យ អធិការដ្ឋាន អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌គ្រប់អង្គភាពចំណុះក្រសួង មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈគ្រប់ខេត្តក្រុង ទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែមិនា ឆ្នាំ ២០០៣

រដ្ឋមន្ត្រី

នរោត្តម - បុប្ផាទេវី

ចម្លងជូន
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទការល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងពត៌មាន
- ក្រសួងឧស្សាហកម្ម
- ក្រសួងយុត្តិធម៌
- គ្រប់ក្រសួង

"ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ៨ "ដើម្បីអនុវត្ត"
- ឯកសារកាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

លេខ: ១១៧ ប្រក.

# ប្រកាស
# ស្ដីពី
# អង្គភាពគ្រប់គ្រងសិទ្ធិរួម

## រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ/នស/រកត/០៩០១៣ចុះថ្ងៃទី២១ខែធ្នូឆ្នាំ២០១៣ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ ប្រកាសឲ្យប្រើច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល
- បានឃើញអនុក្រឹត្យលេខ ២៥អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងគ្រប់គ្រង ទទួលស្គាល់ និងត្រួតពិនិត្យការបង្កើតអង្គភាពគ្រប់គ្រងសិទ្ធិរួមនៅក្នុងព្រះរាជាណាចក្រកម្ពុជា។



ទូរស័ព្ទ / ទូរសារ : 023 218 148 , E-mail : info@mcfa.gov.kh, www.mcfa.gov.kh, ប្រអប់សំបុត្រ 72
មហាវិថីព្រះនរោត្តម លេខ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

**ប្រការ២.-**

ប្រកាសនេះ មានគោលដៅបង្កើតអង្គភាពគ្រប់គ្រងសិទ្ធិរួមដើម្បី÷

- ការពារសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែលនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងនៅបរទេស
- ធានាការធ្វើអាជីវកម្មស្របច្បាប់លើស្នាដៃអ្នកនិពន្ធ និង ម្ចាស់សិទ្ធិប្រហាក់ប្រហែល
- លើកទឹកចិត្តនិងជំរុញការបង្កើតស្នាដៃថ្មីៗ ក្នុងវិស័យអក្សរសាស្ត្រ វិទ្យាសាស្ត្រ សិល្បៈ ឬតូរ្យតន្ត្រី ក្នុងន័យអភិវឌ្ឍវិស័យឧស្សាហកម្មវប្បធម៌
- ចូលរួមលើកកម្ពស់វិស័យសេដ្ឋកិច្ច និងសង្គមកិច្ច
- បំពេញកាតព្វកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជានៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក លើវិស័យកម្មសិទ្ធិបញ្ញា។

**ប្រការ៣.-**

វាក្យសព្ទដែលប្រើក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចតទៅ÷

- អង្គភាពគ្រប់គ្រងសិទ្ធិរួម សំដៅដល់អង្គភាពដែលជាតំណាងឲ្យអ្នកនិពន្ធ ម្ចាស់សិទ្ធិ ឬម្ចាស់សិទ្ធិប្រហាក់ប្រហែល ក្នុងការការពារ និងគ្រប់គ្រងសិទ្ធិបេតិកភណ្ឌ និងសិទ្ធិសីលធម៌
- កិច្ចសន្យាអាជ្ញាបណ្ណ សំដៅដល់កិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សររវាងអ្នកប្រើប្រាស់ស្នាដៃ និងអង្គភាពគ្រប់គ្រងសិទ្ធិរួម
- អ្នកប្រើប្រាស់ស្នាដៃ សំដៅដល់អ្នកដែលប្រើប្រាស់ស្នាដៃ ដើម្បីស្វែងរកផលប្រយោជន៍
- ទីតាំងធ្វើអាជីវកម្មលើស្នាដៃ សំដៅដល់ទីកន្លែងប្រើប្រាស់ស្នាដៃ ឬកន្លែងប្រកបអាជីវកម្មផ្សេងៗ។

**ប្រការ៤.-**

អង្គភាពគ្រប់គ្រងសិទ្ធិរួម បង្កើតឡើងដោយអ្នកនិពន្ធ ឬម្ចាស់សិទ្ធិប្រហាក់ប្រហែលមានសញ្ញាតិខ្មែរ។

អង្គភាពនេះមានមុខងារ តួនាទី កាតព្វកិច្ចការពារនិងគ្រប់គ្រងសិទ្ធិបេតិកភណ្ឌ និងសិទ្ធិសីលធម៌ជំនួសមុខឲ្យសមាជិកខ្លួនចំពោះមុខច្បាប់។

ភារកិច្ចនៃអង្គភាពនេះមានជាអាទិ៍៖

- ផ្តល់កិច្ចសន្យាអាជ្ញាបណ្ណឲ្យប្រើប្រាស់ស្នាដៃ
- ប្រមូលលាភការពីទីតាំងធ្វើអាជីវកម្មលើស្នាដៃសមាជិករបស់ខ្លួន និងបែងចែកលាភការជូនសមាជិកខ្លួនតាមលក្ខន្តិកៈរបស់អង្គភាព

- ដោះស្រាយវិវាទដែលទាក់ទងលើការប្រើប្រាស់ស្នាដៃ
- ការពារស្នាដៃរបស់សមាជិកខ្លួន
- ធ្វើតារាងកំណត់អត្រាតម្លៃនៃការប្រើប្រាស់ស្នាដៃដែលទទួលស្គាល់ដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ធ្វើបញ្ជីគណនេយ្យប្រកបដោយតម្លាភាព
- បង្កើតនីតិវិធី និងយន្តការដើម្បីគ្រប់គ្រង និងតាមដានការប្រើប្រាស់ស្នាដៃ
- ដឹកនាំការងាររដ្ឋបាលប្រចាំថ្ងៃតាមជំនាញនីមួយៗរបស់អង្គភាព
- បង្កើតលក្ខន្តិកៈសម្រាប់អង្គភាពឲ្យសមស្របតាមច្បាប់ និងបទដ្ឋានគតិយុត្តនានានៃព្រះរាជាណាចក្រកម្ពុជា។

រាល់ការធ្វើអាជីវកម្មលើស្នាដៃរបស់សមាជិកខ្លួននៅបរទេស អង្គភាពគ្រប់គ្រងសិទ្ធិរួមត្រូវសហការជាមួយអង្គភាពគ្រប់គ្រងសិទ្ធិរួម ឬអង្គភាពដែលមានប្រភេទប្រហាក់ប្រហែលនៅបរទេស ដើម្បីប្រមូល បែងចែកលាភការ និងការពារផលប្រយោជន៍ផ្សេងៗទៀតជូនសមាជិករបស់ខ្លួន។

**ប្រការ៥**.-

ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពគ្រប់គ្រងសិទ្ធិរួមត្រូវប្រតិបត្តិតាមលក្ខន្តិកៈរបស់ខ្លួន។ ការបង្កើតសាខា ការផ្លាស់ប្តូរទីតាំង ការផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាភិបាល ការកែសម្រួលរចនាសម្ព័ន្ធរបស់អង្គភាពគ្រប់គ្រងសិទ្ធិរួម ត្រូវជូនដំណឹងមកក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

**ប្រការ៦**.-

អង្គភាពគ្រប់គ្រងសិទ្ធិរួមបង្កើតឡើង ដើម្បីគ្រប់គ្រងលើសិទ្ធិមួយ ឬច្រើនដូចខាងក្រោម÷

- សិទ្ធិផលិតឡើងវិញនូវស្នាដៃអក្សរសាស្ត្រ និងស្នាដៃសិល្បៈ
- សិទ្ធិបោះពុម្ពផ្សាយស្នាដៃ
- សិទ្ធិផលិតបន្ត
- សិទ្ធិសម្តែងស្នាដៃនាដកម្ម
- សិទ្ធិផ្សព្វផ្សាយជាសាធារណៈ
- សិទ្ធិចែកចាយជាសាធារណៈ

អង្គភាពគ្រប់គ្រងសិទ្ធិរួមត្រូវចុះបញ្ជីទទួលស្គាល់ជាផ្លូវការពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈដោយភ្ជាប់មកជាមួយនូវលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់អង្គភាព។

**ប្រការ៧.-**

ការដាក់ពាក្យស្នើសុំបង្កើតអង្គភាពគ្រប់គ្រងសិទ្ធិរួម ត្រូវធ្វើនៅនាយកដ្ឋានសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

**ប្រការ៨.-**

រយៈពេលនៃការទទួលស្គាល់ ឬមិនទទួលស្គាល់ការស្នើសុំបង្កើតអង្គភាពគ្រប់គ្រងសិទ្ធិរួម មានរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ។

ក្នុងករណីដែលអ្នកស្នើសុំមិនបានបំពេញគ្រប់លក្ខខណ្ឌនៃការស្នើសុំបង្កើតអង្គភាពគ្រប់គ្រងសិទ្ធិរួម ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកស្នើសុំឱ្យធ្វើការកែតម្រូវក្នុងរយៈពេលយ៉ាងយូរ ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការ។ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សម្រេចទទួលស្គាល់ការបង្កើតអង្គភាពគ្រប់គ្រងសិទ្ធិរួមក្នុងរយៈពេលយ៉ាងយូរ ៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលសំណុំឯកសារកែតម្រូវរួច។

ការទទួលស្គាល់អង្គភាពគ្រប់គ្រងសិទ្ធិរួម មានសុពលភាពរយៈពេល ៥(ប្រាំ)ឆ្នាំ និងអាចបន្តសុពលភាពរយៈពេល២ (ពីរ)ឆ្នាំម្តង។

**ប្រការ៩.-**

អង្គភាពគ្រប់គ្រងសិទ្ធិរួម ត្រូវកំណត់លក្ខខណ្ឌនៃការសុំចូលជាសមាជិកដូចខាងក្រោម÷

អ្នកនិពន្ធ ម្ចាស់សិទ្ធិ ឬម្ចាស់សិទ្ធិប្រហាក់ប្រហែល មានសញ្ជាតិខ្មែរ ឬជនបរទេសដែលមានលំនៅដ្ឋាន ឬការិយាល័យក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានស្នាដៃដាក់តំកល់នៅក្នុងអង្គភាពគ្រប់គ្រងសិទ្ធិរួម។

**ប្រការ១០.-**

ប្រភពថវិការបស់អង្គភាពគ្រប់គ្រងសិទ្ធិរួមមានជាអាទិ៍÷

- ថវិកាពីការប្រមូលលាភការក្នុងការប្រើប្រាស់ស្នាដៃ
- ជំនួយពីសប្បុរសជន ដៃគូអភិវឌ្ឍន៍ ឬរាជរដ្ឋាភិបាលនិង
- ប្រភពថវិកាស្របច្បាប់ផ្សេងៗទៀត។

អង្គភាពគ្រប់គ្រងសិទ្ធិរួមប្រើប្រាស់ប្រភពថវិកាខាងលើ ដើម្បីចំណាយលើការរៀបចំនិងការប្រព្រឹត្តទៅ ឬការចំណាយផ្សេងៗទៀតរបស់អង្គភាពស្របតាមលក្ខន្តិកៈអង្គភាព។

**ប្រការ១១.-**

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលត្រូវការប្រើប្រាស់ស្នាដៃណាមួយរបស់អង្គភាពគ្រប់គ្រងសិទ្ធិរួម ត្រូវសុំការអនុញ្ញាតពីអង្គភាពគ្រប់គ្រងសិទ្ធិរួមនោះ។ អង្គភាពគ្រប់គ្រងសិទ្ធិរួមត្រូវផ្តល់ការអនុញ្ញាតប្រើប្រាស់ស្នាដៃ ប្រសិនបើអ្នកប្រើប្រាស់យល់ព្រមបង់លាភការទៅតាមអត្រាតម្លៃសេវានិងលក្ខខណ្ឌដែលបានកំណត់របស់អង្គភាព។ ការអនុញ្ញាតនេះ ត្រូវធ្វើជាកិច្ចសន្យា

ត្រូវកំណត់ពីប្រភេទនៃការប្រើប្រាស់ស្នាដៃ ចំនួនស្នាដៃ ទីកន្លែង និងពេលវេលាជាដើម។ កិច្ចសន្យាតម្រូវឲ្យអ្នកប្រើប្រាស់ផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរស្តីពីការផ្លាស់ប្តូរទីកន្លែង ឬពេលវេលាមកឲ្យអង្គភាពគ្រប់គ្រងសិទ្ធិរួមជាមុន ដើម្បីធ្វើការពិភាក្សាឡើងវិញ។

ការប្រើប្រាស់ស្នាដៃនៅកន្លែងធ្វើអាជីវកម្ម ត្រូវតែមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអង្គភាពគ្រប់គ្រងសិទ្ធិរួម។ ក្នុងករណីល្មើសម្ចាស់អាជីវកម្មត្រូវទទួលទោសតាមច្បាប់។

**ប្រការ១២.-**

រាល់ករណីវិវាទដែលកើតឡើងរវាងអង្គភាពគ្រប់គ្រងសិទ្ធិរួម ជាមួយសមាជិក ឬជាមួយអ្នកប្រើប្រាស់ស្នាដៃ ភាគីនីមួយៗមានសិទ្ធិស្នើសុំមកក្រសួងវប្បធម៌ និងវិចិត្រសិល្បៈជួយសម្របសម្រួលមុននឹងឈានទៅដល់តុលាការ។

**ប្រការ១៣.-**

អង្គភាពគ្រប់គ្រងសិទ្ធិរួមត្រូវធ្វើរបាយការណ៍ប្រចាំឆមាស និងរៀងរាល់ដំណាច់ឆ្នាំមកក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដើម្បីវាយតម្លៃអំពីសុចរិតភាពការងារ និងតម្លាភាពរបស់អង្គភាព។

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មានតួនាទីត្រួតពិនិត្យរាល់សកម្មភាពគ្រប់អង្គភាពគ្រប់គ្រងសិទ្ធិរួមក្នុងគោលបំណងធានានូវសុក្រឹត្យភាពនៃការអនុវត្តមុខងារ តួនាទី និងកាតព្វកិច្ចរបស់ខ្លួនក្រោមច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល លក្ខន្តិកៈរបស់អង្គភាព និងបទដ្ឋានគតិយុត្តផ្សេងៗក្នុងករណីមានភាពមិនប្រក្រតីណាមួយ។

**ប្រការ១៤.-**

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អាចធ្វើការបញ្ឈប់ការទទួលស្គាល់ ឬធ្វើការផ្អាកជាបណ្តោះអាសន្ននៃដំណើរការប្រព្រឹត្តទៅរបស់អង្គភាពគ្រប់គ្រងសិទ្ធិរួមណាមួយ ក្នុងករណីមានភាពមិនប្រក្រតីកើតឡើងនៅក្នុងអង្គភាព ឬបានអនុវត្តផ្ទុយនឹងបទប្បញ្ញត្តិជាធរមាន។

ដំណើរការប្រព្រឹត្តទៅជាថ្មីឡើងវិញនៃអង្គភាពគ្រប់គ្រងសិទ្ធិរួមបាន លុះត្រាតែការស៊ើបអង្កេតភាពមិនប្រក្រតីដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានបិទបញ្ចប់ និងទទួលបាននូវការអនុញ្ញាតពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈសារជាថ្មី។

អង្គភាពគ្រប់គ្រងសិទ្ធិរួមអាចបញ្ឈប់សកម្មភាពរបស់ខ្លួនបានដោយស្នើសុំមកក្រសួងវប្បធម៌ និងវិចិត្រសិល្បៈដើម្បីពិនិត្យនិងសម្រេច។

សេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាកម្មវត្ថុនៃបណ្តឹងទៅតុលាការ។

**ប្រការ១៥.-**

ជនណាដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៦**.-

នាយកខុទ្ទកាល័យ អធិការ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល គ្រប់ប្រធានអង្គភាពពាក់ព័ន្ធ និងប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្តត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ភឿង-សកុណា**

កន្លែងទទួល:
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
- គ្រប់សាលារាជធានី ខេត្ត
- ដូចប្រការ១៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...៩៩៧...សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ២០១៧

# ប្រកាសរួម
## ស្តីពី
## ការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩២/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ៦៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការគ្រប់គ្រងត្រួតពិនិត្យសិល្បៈភាពយន្ត និងវីដេអូ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- ប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- សារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់
- តាមការចាំបាច់របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ស ម្រេ ច

**ប្រការ ១** :

អនុញ្ញាតឱ្យក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដើម្បីជាគុណប្រយោជន៍ថវិកាជាតិ។

កម្រងសេវាសាធារណៈនេះ មានបញ្ជាក់លម្អិតអំពីតម្លៃសេវា រយៈពេលផ្តល់សេវា និងសុពលភាព ទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយនឹងប្រកាសរួមនេះ។

**ប្រការ ២** :

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវបិទផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវា នូវស្តង់ដារសេវា ក្នុងនោះរួមមាន ៖ តារាងតម្លៃ ទម្រង់ឯកសារ និងនីតិវិធីសម្រាប់ការផ្តល់សេវា ពាក់ព័ន្ធនឹងការប្រមូលចំណូលខាងលើនេះ។

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងជាយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬមានការយកកម្រៃលើសការកំណត់ ឬមានការយឺតយ៉ាវ ជាដើម។

**ប្រការ ៣** :

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានភារកិច្ចប្រមូលចំណូល ទទួលខុសត្រូវប្រាក់ចំណូលដែលប្រមូលបាន និងបង់ប្រាក់ចំណូលចូលថវិកាជាតិ ក្នុងនោះ ត្រូវចុះកិច្ចបញ្ជិកាគណនេយ្យ ស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាថវិកា ព្រមទាំងធ្វើសលាកប័ត្រចំណូល។

**ប្រការ ៤** :

ការបែងចែកភារកិច្ចលើការគ្រប់គ្រង ការប្រមូលចំណូល ពីការផ្តល់សេវាសាធារណៈ រវាងរដ្ឋបាលកណ្តាល នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី ខេត្ត ត្រូវកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវផ្ញើសេចក្តីប្រកាសនេះចំនួន មួយច្បាប់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជូនជ្រាបជាព័ត៌មាន និងសម្រាប់តាមដានការអនុវត្តចំណូល។

**ប្រការ ៥** :

រាល់ការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយ ប្រកាសរួមនេះ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ដែលបានបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្រប តាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ របស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៦** :

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវកំណត់ទីតាំងដាក់លាក់ និងមានមន្ត្រីប្រចាំការដែលមានលក្ខណៈ ជាច្រកចេញចូលតែមួយ នៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលា តាមការកំណត់។

**ប្រការ ៧** :

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវធ្វើរបាយការណ៍ ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ដើម្បី ផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបាន មុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ ៨** :

កម្រងសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសរួមនេះ អាចកែប្រែបាន តាមការ ចាំបាច់តាមរយៈប្រកាសរួម។

**ប្រការ ៩** :

ករណី ការនាំចេញវត្ថុសិល្បៈផលិតថ្មី ឬវត្ថុសិល្បៈចម្លងដូច ដោយគ្មានលិខិតអនុញ្ញាតពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវផាកពិន័យចំនួន ៥ដង នៃតម្លៃសេវាដែលបានកំណត់ក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយ នឹងប្រកាសរួមនេះ។

**ប្រការ ១០** :

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១១** :

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

| | |
|---|---|
| **ឧបនាយករដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី** |
| **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | **ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** |
| **អាន ឈយន់** | **ហឿង-សំអឿន** |

ចម្លងជូន:

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អាជ្ញាធរសេវនកម្មជាតិ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា

«ដើម្បីជូនជ្រាប»

- ដូចប្រការ ១១ «ដើម្បីអនុវត្ត»
- ឯកសារ - កាលប្បវត្តិ

# តារាងឧបសម្ព័ន្ធ

## ភ្ជាប់នឹងប្រកាសរួមលេខ ៩៨៧ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២

## ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| I. ផ្នែកសារមន្ទីរ | | | | |
| ក. | ការលក់សំបុត្រចូលទស្សនាសារមន្ទីរជាតិ | | | |
| | - សម្រាប់ជនជាតិខ្មែរ | 500 | ភ្លាមៗ | 1ថ្ងៃ |
| | - សម្រាប់ជនជាតិបរទេស | 5$ | ភ្លាមៗ | 1ថ្ងៃ |
| ខ. | ការទស្សនាសារមន្ទីរទួលស្លែង | | | |
| | - សម្រាប់ជនជាតិខ្មែរ | អត់គិតថ្លៃ | ភ្លាមៗ | 1ថ្ងៃ |
| | - សម្រាប់ជនជាតិបរទេស | អត់គិតថ្លៃ | ភ្លាមៗ | 1ថ្ងៃ |
| II. ផ្នែកសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល | | | | |
| ក. | ស្នាដៃអក្សរសាស្ត្រ | | | |
| 1 | ផលិតឡើងវិញនូវស្នាដៃវចនានុក្រម (1ចំណងជើង) | 310,000 | 5ថ្ងៃ | |
| 2 | ស្នាដៃវចនានុក្រមផលិតជាកម្មវិធីកុំព្យូទ័រ (1ចំណងជើង) | 410,000 | 5ថ្ងៃ | |
| 3 | ផលិតឡើងវិញនូវស្នាដៃវចនានុក្រមផលិតជាកម្មវិធីកុំព្យូទ័រ(1ចំណងជើង) | 160,000 | 5ថ្ងៃ | |
| 4 | ថតខ្សែភាពយន្ត (1រឿង) | 410,000 | 5ថ្ងៃ | |
| 5 | ថតខ្សែវីដេអូ (1រឿង) | 330,000 | 5ថ្ងៃ | |

| | | | | |
|---|---|---|---|---|
| ខ. | ស្នាដៃដូរ្យតន្ត្រី | | | |
| 1 | ផលិតឡើងវិញនូវតន្ត្រីមានទំនុកច្រៀង ឬគ្មានទំនុកច្រៀង(1បទ) | 30,000 | 5ថ្ងៃ | |
| 2 | ផលិតជាស្នាដៃបន្តនូវតន្ត្រីមានទំនុកច្រៀង ឬគ្មានទំនុកច្រៀង(1បទ) | 35,000 | 5ថ្ងៃ | |
| 3 | សំដែងតន្ត្រីមានទំនុកច្រៀង ឬគ្មានទំនុកច្រៀង(1បទ) | 20,000 | 5ថ្ងៃ | |
| 4 | ដូរ្យតន្ត្រីដើមមានទំនុកច្រៀង ឬគ្មានទំនុកច្រៀងបញ្ចូលប្រព័ន្ធអ៊ីនធើណេត (វេបសាយ) 1បទ | 10,000 | 5ថ្ងៃ | |
| 5 | ដូរ្យតន្ត្រីបន្តមានទំនុកច្រៀងឬគ្មានទំនុកច្រៀងបញ្ចូលប្រព័ន្ធអ៊ីនធើណេត (វេបសាយ) 1បទ | 10,000 | 5ថ្ងៃ | |
| គ. | ស្នាដៃសិល្បៈទស្សនីយភាព | | | |
| 1 | សំដែងមួយរឿង | 110,000 | 5ថ្ងៃ | |
| 2 | សំដែងមួយឈុត | 30,000 | 5ថ្ងៃ | |
| ឃ. | ស្នាដៃសិល្បៈសូន្យរូប | | | |
| 1 | ចម្លាក់បោះពុម្ពព្រះសិរសាព្រះបាទជ័យវរ្ម័នទី7 ខ្នាតតូច ចាប់ពីកំពស់01សម ទៅ 20សម | 30,000 | 5ថ្ងៃ | |
| 2 | ចម្លាក់បោះពុម្ពព្រះសិរសាព្រះបាទជ័យវរ្ម័នទី7 ខ្នាតតូច ចាប់ពីកំពស់21សម ឡើងទៅ | 50,000 | 5ថ្ងៃ | |
| ង. | ចុះបញ្ជីស្នាដៃ | | | |
| 1 | សៀវភៅ, អត្ថបទ, គំនូរ, រូបថត, ផែនទី (1ស្នាដៃ/ច្បាប់) | 20,000 | 5ថ្ងៃ | |
| 2 | ស្ថាបត្យកម្ម (1ស្នាដៃ/ប្លង់) | 60,000 | 5ថ្ងៃ | |
| 3 | ស្នាដៃសិល្បៈសិប្បកម្ម (1ស្នាដៃ/ច្បាប់) | 20,000 | 5ថ្ងៃ | |
| 4 | កម្មវិធីកុំព្យូទ័រ (1ស្នាដៃ/1កម្មវិធី) | 60,000 | 5ថ្ងៃ | |

| | | | | |
|---|---|---|---|---|
| 5 | ស្នាដៃហ្វូណូក្រាម និងសោតទស្សន៍ (1អាល់ប៊ុម/1ឌីស) | 30,000 | 5ថ្ងៃ | |
| 6 | ស្នាដៃឌីជីថល (វេបសាយ) (1កម្មវិធី/1វេបសាយ) | 60,000 | 5ថ្ងៃ | |
| ច. | សេវាផ្តល់លិខិតអនុញ្ញាត | | | |
| 1 | លិខិតអនុញ្ញាតនាំចេញ/នាំចូល(សៀវភៅ, អត្ថបទ) | 60,000 | 5ថ្ងៃ | |
| 2 | លិខិតអនុញ្ញាតនាំចេញ/នាំចូល(ឌីសអុបទិក) | 60,000 | 5ថ្ងៃ | |
| 3 | លិខិតអនុញ្ញាតនាំចេញ/នាំចូល(ឧបករណ៍ថតចម្លង) | 60,000 | 5ថ្ងៃ | |
| 4 | លិខិតអនុញ្ញាតបើកអាជីវកម្មឧបករណ៍ថតចម្លង | 60,000 | 5ថ្ងៃ | |
| 5 | លិខិតអនុញ្ញាតបើកអាជីវកម្មសេវាថតចម្លង | 60,000 | 5ថ្ងៃ | |
| 6 | លិខិតអនុញ្ញាតបោះពុម្ព(សៀវភៅ, អត្ថបទ) | 60,000 | 5ថ្ងៃ | |
| 7 | លិខិតអនុញ្ញាតផលិតឌីសអុបទិក | 60,000 | 10ថ្ងៃ | |
| ឆ. | ការប្រើប្រាស់រូបប្រាសាទបេតិកភ័ណ្ឌដើម្បីធ្វើអាជីវកម្ម | | | |
| 1 | ការប្រើប្រាស់រូបប្រាសាទបេតិកភ័ណ្ឌ(រូបប្រាសាទអង្គរវត្ត, បាយ័ន, ព្រះវិហារ ....) | 110,000 | 5ថ្ងៃ | |
| III. ផ្នែកសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ | | | | |
| ក. | អាជ្ញាប័ណ្ណ | | | |
| ក1. | បើកថ្មី | | | |
| 1 | ផលិតកម្មភាពយន្ត វីដេអូ | 400,000 | 10ថ្ងៃ | 2ឆ្នាំ |
| 2 | ក្រុមហ៊ុននាំចេញ-នាំចូលភាពយន្ត វីដេអូ | 1,000,000 | 10ថ្ងៃ | 2ឆ្នាំ |
| 3 | បន្ទប់បញ្ចូលសម្លេងភាពយន្ត វីដេអូ | 600,000 | 10ថ្ងៃ | 2ឆ្នាំ |
| 4 | បន្ទប់កាត់ត-តម្លើងរូបភាព ភាពយន្ត វីដេអូ | 600,000 | 10ថ្ងៃ | 2ឆ្នាំ |
| 5 | រោងបញ្ចាំងភាពយន្តវីដេអូដែលមានកន្លែងអង្គុយតិចជាង 200កន្លែង | 1,200,000 | 10ថ្ងៃ | 2ឆ្នាំ |

| | | | | |
|---|---|---|---|---|
| 6 | រោងបញ្ចាំងភាពយន្តវីដេអូដែលមានកន្លែងអង្គុយចាប់លើសពី 200កន្លែង | 1,800,000 | 10ថ្ងៃ | 2ឆ្នាំ |
| 7 | ផ្ទេរសិទ្ធិគ្រប់គ្រងអាជីវកម្ម សេវាកម្ម ភាពយន្ត វីដេអូ(បណ្តោះអាសន្ន) | 100,000 | 3ថ្ងៃ | 6ខែ |
| 8 | ផ្ទេរសិទ្ធិគ្រប់គ្រងអាជីវកម្ម សេវាកម្ម ភាពយន្ត វីដេអូ(អចិន្ត្រៃយ៍) | 400,000 | 10ថ្ងៃ | |
| 9 | ប្តូរនាមករណ៍អាជីវកម្ម សេវាកម្ម ភាពយន្ត វីដេអូ | 400,000 | 10ថ្ងៃ | |
| 10 | ប្តូរទីតាំងអាជីវកម្ម សេវាកម្ម ភាពយន្ត វីដេអូ | មិនគិតថ្លៃ | 10ថ្ងៃ | |
| ក2. | បន្តសុពលភាពអាជ្ញាប័ណ្ណ | | | |
| 1 | ផលិតកម្មភាពយន្ត វីដេអូ | 200,000 | 5ថ្ងៃ | 2ឆ្នាំ |
| 2 | ក្រុមហ៊ុននាំចេញ-នាំចូលភាពយន្ត វីដេអូ | 500,000 | 5ថ្ងៃ | 2ឆ្នាំ |
| 3 | បន្ទប់បញ្ចូលសម្លេងភាពយន្ត វីដេអូ | 300,000 | 5ថ្ងៃ | 2ឆ្នាំ |
| 4 | បន្ទប់កាត់ត-តម្លើងរូបភាព ភាពយន្ត វីដេអូ | 300,000 | 5ថ្ងៃ | 2ឆ្នាំ |
| 5 | រោងបញ្ចាំងភាពយន្តវីដេអូដែលមានកន្លែងអង្គុយតិចជាង 200កន្លែង | 600,000 | 5ថ្ងៃ | 2ឆ្នាំ |
| 6 | រោងបញ្ចាំងភាពយន្តវីដេអូដែលមានកន្លែងអង្គុយចាប់ពី 200កន្លែង | 900,000 | 5ថ្ងៃ | 2ឆ្នាំ |
| ខ. | ត្រួតពិនិត្យខ្លឹមសារ | | | |
| ខ1. | អត្ថបទ | | | |
| | 1-ចម្រៀង អត្ថបទនិពន្ធ ឯកសារវីដេអូខ្មែរ | | | |
| 1 | សេវាពិនិត្យខ្លឹមសារអត្ថបទនិពន្ធរឿងពិស្តារសម្រាប់ថតខ្សែភាពយន្ត ឬវីដេអូរឿងខ្នាតវែង | 100,000 | 15ថ្ងៃ | |
| 2 | សេវាពិនិត្យខ្លឹមសារអត្ថបទនិពន្ធរឿងឯកសារសម្រាប់ថតខ្សែភាពយន្ត ឬវីដេអូឯកសារ | 60,000 | 10ថ្ងៃ | |

| | | | | |
|---|---|---|---|---|
| 3 | សេវាពិនិត្យខ្លឹមសារអត្ថបទនិពន្ធរឿងពិស្តារសម្រាប់ថតខ្សែភាពយន្ត ឬវីដេអូរឿងភាគ (មួយភាគបញ្ចាំងយ៉ាងតិច 45នាទី) | 35,000 | 5ថ្ងៃ | |
| 4 | សេវាពិនិត្យខ្លឹមសារអត្ថបទចម្រៀងសម្រាប់ថតខ្សែភាពយន្ត ឬវីដេអូចម្រៀងកាយវិការ ឬខារ៉ាអូខេ | 35,000 | 7ថ្ងៃ | |
| | 2-ប្រភេទផលិតកម្មភាពយន្ត ឬវីដេអូបរទេស | | | |
| 1 | សេវាពិនិត្យខ្លឹមសារអត្ថបទនិពន្ធរឿងពិស្តារសម្រាប់ថតខ្សែភាពយន្ត ឬវីដេអូរឿងខ្នាតវែង | 600,000 | 15ថ្ងៃ | |
| 2 | សេវាពិនិត្យខ្លឹមសារអត្ថបទនិពន្ធរឿងឯកសារសម្រាប់ថតខ្សែភាពយន្ត ឬវីដេអូឯកសារ | 200,000 | 15ថ្ងៃ | |
| 3 | សេវាពិនិត្យខ្លឹមសារអត្ថបទនិពន្ធរឿងពិស្តារសម្រាប់ថតខ្សែភាពយន្ត ឬវីដេអូរឿងភាគ (មួយភាគបញ្ចាំងយ៉ាងតិច45នាទី) | 250,000 | 10ថ្ងៃ | |
| ខ.2 | រូបភាព | | | |
| | 1-ស្នាដៃភាពយន្ត ឬវីដេអូខ្មែរ | | | |
| 1 | ខ្សែភាពយន្ត ឬវីដេអូរឿងខ្នាតវែង | 100,000 | 10ថ្ងៃ | |
| 2 | ខ្សែភាពយន្ត ឬវីដេអូរឿងខ្នាតខ្លី | 60,000 | 7ថ្ងៃ | |
| 3 | ខ្សែភាពយន្ត ឬវីដេអូរឿងខ្នាតវែងរឿងភាគ (1ភាគ) | 30,000 | 7ថ្ងៃ | |
| 4 | ខ្សែភាពយន្ត ឬវីដេអូឯកសារខ្នាតវែង | 50,000 | 7ថ្ងៃ | |
| 5 | ខ្សែភាពយន្ត ឬវីដេអូ ឯកសារខ្នាតខ្លី គំនូរជីវចល តុក្កតា ស្ប៉ត | 25,000 | 7ថ្ងៃ | |
| 6 | ខ្សែភាពយន្ត ឬវីដេអូចម្រៀងកាយវិការ ឬខារ៉ាអូខេមានទម្រង់ជាវីដេអូ ឌីវីឌី (DVD) | 65,000 | 7ថ្ងៃ | |

| | | | | |
|---|---|---|---|---|
| 7 | ខ្សែភាពយន្ត ឬវីដេអូចម្រៀងកាយវិការ ឬខារ៉ាអូខេមានទម្រង់ជាកាសែតវីដេអូ វីស៊ីឌី (VCD) | 40,000 | 7ថ្ងៃ | |
| | 2-ស្នាដៃភាពយន្ត ឬវីដេអូបរទេស (សុំរក្សាពាក្យសន្ទនាភាសាដើម) | | | |
| 1 | ខ្សែភាពយន្ត ឬវីដេអូរឿងខ្នាតវែង | 80,000 | 7ថ្ងៃ | |
| 2 | ខ្សែភាពយន្ត ឬវីដេអូរឿងខ្នាតខ្លី | 50,000 | 7ថ្ងៃ | |
| 3 | ខ្សែភាពយន្ត ឬវីដេអូរឿងខ្នាតវែងរឿងភាគ (1ភាគ) | 30,000 | 7ថ្ងៃ | |
| 4 | ខ្សែភាពយន្ត ឬវីដេអូឯកសារខ្នាតវែង | 50,000 | 7ថ្ងៃ | |
| 5 | ខ្សែភាពយន្ត ឬវីដេអូឯកសារខ្នាតខ្លីគំនូរជីវចល តុក្កតា ស្ប៉ត | 25,000 | 7ថ្ងៃ | |
| 6 | ខ្សែភាពយន្ត ឬវីដេអូចម្រៀងកាយវិការ ឬខារ៉ាអូខេមានទម្រង់ជាវីដេ អូឌីវីឌី (DVD) | 80,000 | 7ថ្ងៃ | |
| 7 | ខ្សែភាពយន្ត ឬវីដេអូចម្រៀងកាយវិការ ឬខារ៉ាអូខេមានទម្រង់ជាកាសែតវីដេអូ វីស៊ីឌី (VCD) | 60,000 | 7ថ្ងៃ | |
| | 3-ស្នាដៃភាពយន្ត ឬវីដេអូបរទេស (សុំបញ្ចូលពាក្យសន្ទនាជាភាសាខ្មែរ) | | | |
| 1 | ខ្សែភាពយន្ត ឬវីដេអូរឿងខ្នាតវែង | 300,000 | 7ថ្ងៃ | |
| 2 | ខ្សែភាពយន្ត ឬវីដេអូរឿងខ្នាតខ្លី | 200,000 | 7ថ្ងៃ | |
| 3 | ខ្សែភាពយន្ត ឬវីដេអូខ្នាតវែងរឿងភាគ (1ភាគ) | 120,000 | 7ថ្ងៃ | |
| 4 | ខ្សែភាពយន្ត ឬវីដេអូឯកសារខ្នាតវែង | 120,000 | 7ថ្ងៃ | |
| 5 | ខ្សែភាពយន្ត ឬវីដេអូឯកសារខ្នាតខ្លី គំនូរជីវចល តុក្កតា ស្ប៉ត | 90,000 | 7ថ្ងៃ | |
| | 4-ស្នាដៃភាពយន្ត ឬវីដេអូបរទេស (សុំបញ្ចូលចំណងជើងជាអក្សរខ្មែរ) | | | |
| 1 | ខ្សែភាពយន្ត ឬវីដេអូរឿងខ្នាតវែង | 120,000 | 7ថ្ងៃ | |
| 2 | ខ្សែភាពយន្ត ឬវីដេអូរឿងខ្នាតខ្លី | 50,000 | 7ថ្ងៃ | |

| | | | | |
|---|---|---|---|---|
| 3 | ខ្សែភាពយន្ត ឬវីដេអូរឿងខ្នាតវែងរឿងភាគ (1ភាគ) | 35,000 | 7ថ្ងៃ | |
| 4 | ខ្សែភាពយន្ត ឬវីដេអូឯកសារខ្នាតវែង | 40,000 | 7ថ្ងៃ | |
| 5 | ខ្សែភាពយន្ត ឬវីដេអូឯកសារខ្នាតខ្លីគំនូរជីវចល តុក្កតា ស្ប៉ត | 25,000 | 7ថ្ងៃ | |
| IV. ផ្សេងៗ | | | | |
| 1 | ការចេញលិខិតអនុញ្ញាតឱ្យប្រគុំតន្ត្រីតាមទីសាធារណៈ | | | |
| | - លក្ខណៈជាតិ | 100,000 | 7ថ្ងៃ | 1លើក |
| | - លក្ខណៈអន្តរជាតិ | 200,000 | 7ថ្ងៃ | 1លើក |
| 2 | ការចេញលិខិតអនុញ្ញាតឱ្យសម្តែងល្ខោនគ្រប់ទម្រង់ (គ្រាន់តែផ្តល់ព័ត៌មានមកមន្ទីរ) | មិនគិតថ្លៃ | 7ថ្ងៃ | 1លើក |
| 3 | ការចេញប័ណ្ណអនុញ្ញាតបើកអាជីវកម្ម ៖ | | | |
| | - តូបលក់ស៊ីឌី វិស៊ីឌី ឌីវីឌី - តូបលក់សៀវភៅ - ហាងកាត់សក់(2-4កៅអី) | 20,000 | 7ថ្ងៃ | 1ឆ្នាំ |
| | - ហាងលក់ជួលកាសែ្សត ស៊ីឌី វិស៊ីឌី ឌីវីឌី - ហាងថតរូប ថតវីដេអូ - ជាងគំនូរ - ហាងកាត់សក់(លើសពី4កៅអី) - ហាងអ៊ុតសក់ កាត់សក់ លម្អក្រចក(2-4កៅអី) | 40,000 | 7ថ្ងៃ | 1ឆ្នាំ |
| | - ហាងអ៊ុតសក់ កាត់សក់ លម្អក្រចក(លើសពី4កៅអី) | 60,000 | 7ថ្ងៃ | 1ឆ្នាំ |
| | - អគារលក់ស៊ីឌី វិស៊ីឌី ឌីវីឌី - អគារផ្តិតរូប ថតរូប ថតវីដេអូ (ស្ទូឌីយោ) - ផលិតស្លាកសញ្ញា - ផលិត លក់ចម្លាក់ពុម្ពស៊ីម៉ង់ - ផលិតលក់ចម្លាក់ម្នាងសិលា - បណ្ណាគារ - សម្ភាងការ (តម្លៃក្រោម 500 ដុល្លារ) | 100,000 | 7ថ្ងៃ | 1ឆ្នាំ |
| | - បណ្ណាគារ (ខ្នាតធំ) - សម្ភាងការ (តម្លៃក្រោម 1000 ដុល្លា) | 200,000 | 7ថ្ងៃ | 1ឆ្នាំ |
| | - សម្ភាងការ (តម្លៃលើស 1000 ដុល្លា) | 400,000 | 7ថ្ងៃ | 1ឆ្នាំ |

| V. ផ្នែកបុរាណវត្ថុ | | | | | |
|---|---|---|---|---|---|
| ក. | ពិនិត្យវត្ថុសិល្បៈនាំចេញទៅបរទេស | ប្រភេទវត្ថុសិល្បៈផលិតថ្មី | ប្រភេទវត្ថុសិល្បៈចម្លងដូច | | |
| 1 | វត្ថុសិល្បៈធ្វើពីឈើ | | | | |
| | - កំពស់ចាប់ពី 01 ទៅ 20សម | 2,000 | 5,000 | 3-5ថ្ងៃ | 1ខែ |
| | - កំពស់ចាប់ពី 21 ទៅ 50សម | 5,000 | 20,000 | | |
| | - កំពស់ចាប់ពី 51 ទៅ 100សម | 8,000 | 30,000 | | |
| | - កំពស់ចាប់ពី 101 ទៅ 150សម | 12,000 | 40,000 | | |
| | - កំពស់ចាប់ពី 151 ទៅ 200សម | 16,000 | 50,000 | | |
| | - កំពស់ចាប់ពី 201សម ឡើងទៅ | 30,000 | 70,000 | | |
| 2 | វត្ថុសិល្បៈធ្វើពីលោហៈ | | | | |
| | - កំពស់ចាប់ពី 01 ទៅ 20សម | 2,000 | 6,000 | 3-5ថ្ងៃ | 1ខែ |
| | - កំពស់ចាប់ពី 21 ទៅ 50សម | 6,000 | 20,000 | | |
| | - កំពស់ចាប់ពី 51 ទៅ 100សម | 8,000 | 30,000 | | |
| | - កំពស់ចាប់ពី 101 ទៅ 150សម | 12,000 | 40,000 | | |
| | - កំពស់ចាប់ពី 151 ទៅ 200សម | 20,000 | 50,000 | | |
| | - កំពស់ចាប់ពី 201សម ឡើងទៅ | 30,000 | 70,000 | | |
| 3 | វត្ថុសិល្បៈធ្វើពីថ្ម | | | | |
| | - កំពស់ចាប់ពី 01 ទៅ 20សម | 3,000 | 10,000 | 3-5ថ្ងៃ | 1ខែ |

| | | | | | |
|---|---|---|---|---|---|
| | - កំពស់ចាប់ពី 21 ទៅ 50សម | 6,000 | 20,000 | | |
| | - កំពស់ចាប់ពី 51 ទៅ 100សម | 10,000 | 30,000 | | |
| | - កំពស់ចាប់ពី 101 ទៅ 150សម | 14,000 | 40,000 | | |
| | - កំពស់ចាប់ពី 151 ទៅ 200សម | 20,000 | 50,000 | | |
| | - កំពស់ចាប់ពី 201សម ឡើងទៅ | 30,000 | 70,000 | | |
| 4 | វត្ថុសិល្បៈធ្វើពីវត្ថុធាតុផ្សេងៗ (ដីដុតក្រណាត់ក្រដាស) | | | | |
| | - កំពស់ចាប់ពី 01 ទៅ 10សម | 2,000 | 6,000 | 3-5ថ្ងៃ | 1ខែ |
| | - កំពស់ចាប់ពី 11 ទៅ 50សម | 4,000 | 15,000 | | |
| | - កំពស់ចាប់ពី 51 ទៅ 100សម | 10,000 | 30,000 | | |
| ខ. | ពិនិត្យវត្ថុសិល្បៈនាំចូលពីបរទេស | | | | |
| 1 | វត្ថុសិល្បៈធ្វើពីឈើ | | | | |
| | - កំពស់ចាប់ពី 01 ទៅ 20សម | 3,000 | | 3-5ថ្ងៃ | 1ខែ |
| | - កំពស់ចាប់ពី 21 ទៅ 50សម | 7,000 | | | |
| | - កំពស់ចាប់ពី 51 ទៅ 100សម | 12,000 | | | |
| | - កំពស់ចាប់ពី 101 ទៅ 150សម | 18,000 | | | |
| | - កំពស់ចាប់ពី 151 ទៅ 200សម | 24,000 | | | |
| | - កំពស់ចាប់ពី 201សម ឡើងទៅ | មិនអនុញ្ញាត | | | |
| 2 | វត្ថុសិល្បៈធ្វើពីលោហៈ | | | | |
| | - កំពស់ចាប់ពី 01 ទៅ 20សម | 3,000 | | 3-5ថ្ងៃ | 1ខែ |
| | - កំពស់ចាប់ពី 21 ទៅ 50សម | 9,000 | | | |

| | | | | | |
|---|---|---|---|---|---|
| | - កំពស់ចាប់ពី 51 ទៅ 100សម | 12,000 | | | |
| | - កំពស់ចាប់ពី 101 ទៅ 150សម | 18,000 | | | |
| | - កំពស់ចាប់ពី 151 ទៅ 200សម | 30,000 | | | |
| | - កំពស់ចាប់ពី 201សម ឡើងទៅ | មិនអនុញ្ញាត | | | |
| 3 | វត្ថុសិល្បៈធ្វើពីថ្ម | | | | |
| | - កំពស់ចាប់ពី 01 ទៅ 20សម | 45,000 | | 3-5ថ្ងៃ | 1ខែ |
| | - កំពស់ចាប់ពី 21 ទៅ 50សម | 9,000 | | | |
| | - កំពស់ចាប់ពី 51 ទៅ 100សម | 15,000 | | | |
| | - កំពស់ចាប់ពី 101 ទៅ 150សម | 21,000 | | | |
| | - កំពស់ចាប់ពី 151 ទៅ 200សម | 30,000 | | | |
| | - កំពស់ចាប់ពី 201សម ឡើងទៅ | មិនអនុញ្ញាត | | | |
| 4 | វត្ថុសិល្បៈធ្វើពីវត្ថុធាតុផ្សេងៗ (ដីដុត ក្រណាត់ ក្រដាស) | | | | |
| | - កំពស់ចាប់ពី 01 ទៅ 10សម | 3,000 | | 3-5ថ្ងៃ | 1ខែ |
| | - កំពស់ចាប់ពី 11 ទៅ 50សម | 6,000 | | | |
| | - កំពស់ចាប់ពី 51 ទៅ 100សម | 15,000 | | | |

**បញ្ជាក់:**

តម្លៃសេវាពិនិត្យវត្ថុសិល្បៈនាំចេញទៅបរទេស អនុវត្តចំពោះការនាំចេញវត្ថុសិល្បៈតាមរយៈក្រុមហ៊ុនដឹកជញ្ជូន (យន្តហោះ កប៉ាល់ រថយន្ត ឬប៉ុស្តិ៍ប្រៃសណីយ៍) និងមិនអនុវត្តចំពោះភ្ញៀវដែលយកវត្ថុសិល្បៈផលិតថ្មីតាមខ្លួន(យួរដៃ) ប៉ុន្តែតម្រូវឱ្យមានវិក័យប័ត្រ(ឈ្មោះហាង លេខទូរស័ព្ទ និងអាស័យដ្ឋានទីកន្លែងលក់វត្ថុសិល្បៈ) បង្ហាញដល់សមត្ថកិច្ចក្នុងករណីមានការទាមទារពិនិត្យ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល

# វិញ្ញាបនបត្រចុះបញ្ជីស្នាដៃសិទ្ធិអ្នកនិពន្ធ

ស.៧

**លេខចុះបញ្ជី N° : ® ន.ស.ស ៣៦៨/១៩**

**កាលបរិច្ឆេទចុះបញ្ជី** : ២០ មិថុនា ២០១៩
**ចំណងជើងស្នាដៃ** : **កម្មវិធីត្រួតពិនិត្យអក្ខរាវិរុទ្ធខ្មែរតាមប្រព័ន្ធឌីជីថល**
**ប្រភេទស្នាដៃ** : កម្មវិធីកុំព្យូទ័រ
**កាលបរិច្ឆេទនៃការបង្កើតស្នាដៃ** : ១១ មីនា ២០១៩
**ការផ្សព្វផ្សាយជាសាធារណៈ** : ពុំទាន់បានផ្សព្វផ្សាយ
**ម្ចាស់កម្មសិទ្ធិ** : **សមាគមអ្នកនិពន្ធខ្មែរ**
**អាសយដ្ឋាន** : វត្តបុទុមវតី សង្កាត់ចតុមុខ ខណ្ឌដូនពេញ ព្រះរាជាណាចក្រកម្ពុជា។

យោងតាមច្បាប់សិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល មាត្រា១៨ ដល់ មាត្រា២២ ម្ចាស់សិទ្ធិអ្នកនិពន្ធ មានសិទ្ធិផ្តាច់មុខលើ សិទ្ធិសីលធម៌ និងសិទ្ធិបេតិកភណ្ឌ និងមាត្រា៣៨ដល់មាត្រា៤០ រាល់ស្នាដៃទាំងអស់ អនុលោមតាមច្បាប់នេះត្រូវបានការពារដោយស្វ័យប្រវត្តិ ហើយការចុះបញ្ជីនេះគឺធ្វើឡើងដោយស្ម័គ្រចិត្ត។

ដើម្បីជាសក្ខីភាព ខ្ញុំបាទសូមចុះហត្ថលេខានៅថ្ងៃនេះ។

ថ្ងៃ សុក្រ ១២កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ មិថុនា ឆ្នាំ២០១៩

**ប្រធាននាយកដ្ឋាន**

ស៊ឹម សត្ថា